

# ពេលក្រៀលវិលវិញ និង ភាពពិសិដ្ឋអស្ចារ្យ

# WHEN THE SARUS CRANES COME and THE MIRACLES

ព្រះតេជគុណ ទៀន យីវ
Ven. Huyen Dieu



ចំពោះអាត្មាភាពវិញ ភាពពិសិដ្ឋអស្ចារ្យ គឺជាការដែលយើងបានរកឃើញសេចក្ដីសុខសាន្តយ៉ាងពិតប្រាកដនៅក្នុងជីវិតនេះ គឺការប្រែក្លាយចំណេះដឹង ព្រមទាំងសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធរបស់ខ្លួនក្លាយទៅជាផលប្រយោជន៍សម្រាប់សត្វលោក ។

នេះគឺជាទស្សនវិស័យយ៉ាងសាមញ្ញសំរាប់ជីវិតដែលអាត្មាភាពបានរកឃើញ ហើយមានជំនឿថា អ្នកណាមួយយកទៅអនុវត្តក្នុងជីវិតរបស់ខ្លួន គឺគេនឹងទទួលបានលទ្ធផលយ៉ាងល្អប្រសើរជាពុំខាន។

**ហ្វៀន យីវ**

*But for me, a miracle consists in finding peace and happiness right in this world, transforming your knowledge and sincere love into profit for the sake of all beings and bringing peace to everyone.*

*This is a very simple living philosophy I have discovered and I strongly believe anyone who put it in practice will get good results.*

**HUYEN DIEU**

ម.ព.ឯ.ក AIDOC
Code: 229-020
Date:
Donated by:

# ពេលក្រៀលវិលវិញ និង ភាពពិសិដ្ឋអស្ចារ្យ

# *WHEN THE SARUS CRANES COME and THE MIRACLES*


អ្នកនិពន្ធ : **ព្រះតេជគុណ ទៀន យីវ**
Author : Ven. Huyen Dieu

បកប្រែដោយ : លោក **សែម ផល្លា**
Translated by : Mr. Sem Phalla

អក្ខរាវិរុទ្ធដោយ : លោក **ជួរ គារី**
ប្រធានផ្នែកខេមរនីយកម្មវចនានុក្រម និង
បកប្រែភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៛៧

ទីស្ដីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិតសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

# អារម្ភកថា

សៀវភៅ " **ពេលក្រៀវលទិលទិញ** " បានបង្ហាញឡើងនូវសុឆន្ទៈយ៉ាងមោះមុត និងឧត្តមគតិដ៏ថ្លៃថ្លារបស់ព្រះតេជគុណ **ទៀន យីវ** (Huyen Dieu) ដែលលោកបានជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីកសាងព្រះវិហារ និងបំភ្លឺនូវសារៈប្រយោជន៍របស់ព្រះពុទ្ធសាសនា ទាំងពីរនិកាយគឺ និកាយមហាយាន និងនិកាយថេរវាទ នៅលុម្ពិនីវ័ន្តប្រទេសនេប៉ាល ដែលជាកន្លែងចាប់បដិសន្ធិរបស់ព្រះពុទ្ធសាសនា ព្រះតេជគុណមិនត្រឹមតែសម្ដែងចេញនូវសាមគ្គីភាព រវាងព្រះពុទ្ធសាសនាទាំងពីរនិកាយប៉ុណ្ណោះទេ ប៉ុន្តែលោកថែមទាំងបាន បង្ហាញនូវសេចក្ដីមេត្តាស្រឡាញ់ធម្មជាតិ បរិស្ថាន ពិសេសគឺសត្វក្រៀល ដែលបានមកជ្រកកោននៅតំបន់លុម្ពិនីវ័ន្តនេះតែម្ដង។

សៀវភៅនេះពិតមែនតែមើលទៅឃើញថា សាមញ្ញប៉ុន្តែក៏ជាសៀវភៅមួយអាចផ្ដល់ពុទ្ធិអប់រំ មនុស្សតាមដំណើរងាយៗក្នុងជីវិតពិត ។

ដោយខ្ញុំយល់ឃើញនូវចរិតលក្ខណៈអប់រំផ្លូវធម៌ ចរិតចេះស្គាល់ខ្លួនឯង "អត្តាហិអត្តនោនាថោ" ចរិត្តជាតិតាមសកម្មភាពជាក់ស្ដែងរបស់អ្នកនិពន្ធ ដូចច្នេះហើយទើប ខ្ញុំសូមធ្វើការកោតសរសើរនិងវាយតម្លៃខ្ពស់ទៅលើស្នាដៃនេះ ហើយសូមឱ្យមិត្តអ្នកអានពិចារណាផងចុះ អាចដើម្បីជាជាប្រយោជន៍ដល់ខ្លួនឯង ដល់អ្នកដទៃ និងដល់សង្គមជាតិយើងផងដែរ ។

ភ្នំពេញ ថ្ងៃទី..២៦..ខែ..សា. ឆ្នាំ ២០០៩
**ប្រធានរាជបណ្ឌិតសភាកម្ពុជា**

បណ្ឌិត **ខ្លូត ធីតា**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រ 531 ភ្នំពេញ កម្ពុជា
Tel/Fax : (855) 23 890 180 E-mail : arc_racademy@yahoo.com P.O. Box 531 Phnom Penh, Cambodia.

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**The Cabinet of Council of Ministers** **Royal Academy of Cambodia**

## Letter of Appreciation

The book " When The Sarus Cranes come..." has shown the undefeated goodwill and the great ideal of Venerable Huyen Dieu who had overcome all obstacles to build up the Buddhist pagoda and light up the vital meaning of Buddhism including the two Sects : The Mahayana and Theravada at Lumbini – Nepal which was the original place of Buddhism. The Venerable not only expresses the consolidation between the two Sects of Buddhism but also display the great compassion of loving nature and environment especially, the Sarus Cranes coming to refuge at the area of Lumbini.

This book has an normal pattern as others but it consists of a profound Buddhist education toward human through the real daily lives.

As I myself, understand the character of Dhamma education, self-awareness "Self- direction" and the character of the nation through the activities of the author, I would like to express my appreciation and highly value this work. By this opportunity, I appeal to all readers to consider this work as the benefits for yourself, for others and for our nation.

Phnom Penh 26th October 2009

**Royal Academy of Cambodia**
**President**
**H.E.Dr. Khlot Thyda**

# អារម្ភបទអំពីការបោះពុម្ពផ្សាយ

ក្នុងដំណើរធម្មយាត្រាទៅកាន់ទីកន្លែងដ៏ពិសិដ្ឋ និងជាទីសក្ការៈបូជាទាំងបួននៃព្រះសម្មាសម្ពុទ្ធនៃយើង គឺកន្លែងដែលព្រះអង្គបានចាប់បដិសន្ធិនៅ**លុម្ពិនីវ័ន្ត** នាប្រទេស**នេប៉ាល់** កន្លែងព្រះអង្គបានត្រាស់ដឹងនៅ**ពុទ្ធគយា** នាប្រទេសឥណ្ឌា ព្រះអង្គបានសំដែងព្រះធម្មចក្រជាលើកដំបូងនៅ **សារនាថ** នាក្រុង**ពារាណសី** និងកន្លែងព្រះអង្គបានចូលបរិនិព្វាននៅឯក្រុង**កុសិនារា** ក្នុងប្រទេស**ឥណ្ឌា** ដដែលនោះ យើងខ្ញុំមាននិស្ស័យនិងភ័ព្វសំណាងយ៉ាងល្អប្រសើរដោយបានជួបជាមួយនឹងព្រះតេជគុណ **វៀន យីវ (Huyen Dieu)** ហើយព្រះអង្គបានដឹកនាំយើងខ្ញុំ ក្នុងដំណើរធម្មយាត្រានេះដោយផ្ទាល់។

ព្រះតេជគុណជាអាណិកជនវៀតណាមនៅប្រទេស**បារាំង** ព្រះអង្គជាបណ្ឌិតសាស្ត្រចារ្យខាងផ្នែកសេដ្ឋកិច្ចសង្គម ហើយបានទៅបង្ហាត់បង្រៀននៅតាមប្រទេសជាច្រើនដូចជា: ប្រទេសអាមេរិក កាណាដា អូស្ត្រាលី អង់គ្លេស ជប៉ុន ។ល។ ព្រះតេជគុណជាអ្នកឈានមុខដំបូងបង្អស់ក្នុងការកសាងព្រះវិហារ នៃពុទ្ធសាសនានៅប្រទេស**នេប៉ាល់** ជាអ្នកសម្របសម្រួលជម្លោះក្នុងប្រទេសនេប៉ាល់ និងនាំមកនូវសន្តិភាពសម្រាប់ប្រទេសនេះ (សូមមើលសៀវភៅ "សន្តិភាពនេប៉ាល់ក្នុងវង្វង់ដៃ Nepal Peace in Hand" របស់ព្រះតេជគុណ)។ និយាយរួមព្រះតេជគុណមានបំណងប្រាថ្នាបំផុសផ្សព្វផ្សាយព្រះពុទ្ធសាសនានៅប្រទេស**ឥណ្ឌា**និង**នេប៉ាល់** ដែលប្រជាជនទីនោះភាគច្រើន

ជាង៩០% បានប្រកាន់យកសាសនាផ្សេងៗ ដូចជាសាសនាហិណ្ឌូ សាសនាឥស្លាម ។ល។និង។ល។

សៀវភៅ **"ពេលត្រៀលវិលវិញ"** ជាស្នាដៃមួយក្នុងកម្រងស្នាដៃនិពន្ធរបស់ព្រះតេជគុណ ដែលបានបង្ហាញឡើងនូវការខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីការអភិវឌ្ឍពុទ្ធសាសនា ដាស់តឿនក្រើនរំឭកដល់អ្នកទាំងឡាយក្នុងការស្រឡាញ់ពិភពធម្មជាតិ ជីវិតសត្វលោក និងគំរូកុសលកម្មមួយចំនួន ដែលព្រះតេជគុណបានប្រតិបត្តិតាមមគ្គព្រះពោធិសត្វនៃពុទ្ធសាសនាមហាយាន។

យើងខ្ញុំសូមអនុញ្ញាត ធ្វើការបកប្រែស្នាដៃនេះមកជាភាសាខ្មែរ ដើម្បីមិត្តអ្នកអានមានឱកាសស្វែងយល់អំពីដំណើរប្រតិបត្តិធម៌មួយចំនួន នៃផ្នែកនានារបស់ពុទ្ធសាសនាលើពិភពលោក។

ការខិតខំប្រឹងប្រែងដ៏តូចមួយនេះ អាចនឹងប្រទះនូវការខុសឆ្គងមួយចំនួនក្នុងការបកប្រែកែសម្រួល ខ្ញុំសូមគោរពលំអោនកាយសូមសេចក្តីខន្តីអភ័យទោសពីមិត្តអ្នកអានទាំងឡាយ អំពីការខុសឆ្គងដែលអាចមានក្នុងស្នាដៃបកប្រែនេះ។

អានិសង្សណា ដែលខ្ញុំអាចទទួលបានពីការបកប្រែនិងបោះពុម្ពផ្សាយសៀវភៅនេះ សូមអនុមោទនាជូនចំពោះអ្នកទាំងឡាយ សូមឱ្យបានសំរេចនូវព្រះធម៌គ្រប់ៗគ្នា ។

ភ្នំពេញ ថ្ងៃទី១ ខែតុលា ២០០៩

**សែម ផល្លា**

# អារម្ភកថាអ្នកនិពន្ធ

នៅក្នុងជីវិតរបស់មនុស្ស ភាពចម្លែកអស្ចារ្យបានកើតមានឡើងម្តងម្កាល ដែលយើងកម្រនឹងបានជួបប្រទះនឹងភ្នែកណាស់។ ជាធម្មតាភាពពិសិដ្ឋអស្ចារ្យ បានកើតចេញពីការងារជាក់ស្តែង ដែលយើងបានធ្វើសម្រាប់សេចក្តីសុខដល់អ្នកដទៃ។

ប្រសិនបើអ្នកណាក៏មានឆន្ទៈ ខិតខំប្រកបអំពើល្អក្នុងមួយថ្ងៃ ឬមួយសប្តាហ៍ ឬមួយខែនោះ គេច្បាស់ជានឹងទទួលបានផលដ៏ល្អប្រសើរ ដែលពុំអាចនឹងប៉ាន់ស្មានបានឡើយ។ ម្ល៉ោះហើយ ក្នុងរយៈពេលណាមួយនោះគេនឹងយល់ឃើញថា ជីវិតរបស់ខ្លួនមានការផ្លាស់ប្តូរយ៉ាងល្អប្រសើរជាពុំខាន។

ប៉ុន្តែយើងមិនត្រូវរង់ចាំប្រកបតែការងារណា ដែលអាចហុចផលមកអោយភ្លាមៗនោះបានឡើយ។ ចូរយកការឧបមាមួយថា មានថ្ងៃមួយយើងកំពុងធ្វើដំណើរតាមផ្លូវ ស្រាប់តែប្រទះឃើញក្តារមួយកំណាត់មានដែកគោលច្រែះចាប់ជាប់នៅលើនោះ ដែលអាចបណ្តាលអោយអ្នកធ្វើដំណើរជាន់មុតជើងជាពុំខាន។ ចំពោះហេតុការណ៍នេះ បើសិនជាយើងខិតខំបង្អាក់ដំណើរបន្តិច ហើយរើសយកក្តារមួយបន្ទះនោះចោលនៅកន្លែងសមគួរ គឺអំពើនេះហើយ នឹងបានជួយដល់អ្នកដទៃអោយរួចផុតពីគ្រោះថ្នាក់ផងដែរ។ ផ្ទុយទៅវិញ បើសិនជាយើងពុំបានរើសយកក្តារនោះចោលទេ ហើយស្រាប់

តែមានអ្នកធ្វើដំណើរណាមួយ បានដើរជាន់ដែកគោលដែលជាប់នឹងបន្ទះក្តារនោះបណ្តាលអោយមានរបួស ដោយសារការខ្វះខាតចំណេះដឹងទូទៅ ជនរងគ្រោះនោះក៏អាចត្រូវបាត់បង់ជីវិតដោយជំងឺតេតាណូស បន្សល់ទុកនូវក្រុមគ្រួសាររបស់គាត់ ដែលមានប្រពន្ធនិងកូនជាច្រើននាក់គ្មានទីពំនឹងទៀតឡើយ ម្យ៉ាងទៀតក្មេងៗដែលខ្វះការថែរក្សាអប់រំអោយបានពេញលេញនោះ នៅពេលធំឡើងគេនឹងក្លាយទៅជាបញ្ហាមួយយ៉ាងធំ ដែលសង្គមជាតិត្រូវការដោះស្រាយយ៉ាងលំបាកជាពុំខាន។

ជាការពិតណាស់ បញ្ហានេះគ្រាន់តែស្ថិតនៅលើអាកប្បកិរិយារបស់អ្នកធ្វើដំណើរដែលគាត់ព្រមបង្អាក់ដំណើររបស់ខ្លួន ដើម្បីរើសដែកគោលយកទៅចោលតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះហើយ នៅពេលដែលយើងជួបប្រទះនូវឱកាសល្អ សម្រាប់ធ្វើបុណ្យនោះ គួរតែកុំរំលងចោលទាល់តែសោះ។ នេះក៏ជាទស្សនវិស័យមួយ ក្នុងការរស់នៅយ៉ាងសកម្មដែលខ្លួនអាត្មាភាពផ្ទាល់ ធ្លាប់មានបទពិសោធន៍ជាច្រើន។ ឧទាហរណ៍ជាក់ស្តែងគឺមានរឿងសត្វ Sarus Crane ដូចតទៅនេះ :

នៅគ្រាដំបូង ដែលអាត្មាភាពបានស្នាក់នៅ**លុម្ពិនីវ័ន្ត** (Lumbini) នៃប្រទេស**នេប៉ាល់** ដែលជាតំបន់មួយយ៉ាងស្រស់បំព្រងស្ថិត នៅឯជើង**ភ្នំហិមពាន្ត** (Himalaya) ដែលថែងចាំងដោយព្រិលស គ្របដណ្តប់លើជួរភ្នំទាំងនោះ គឺទីនេះហើយជាកន្លែងដែលព្រះសម្មាសម្ពុទ្ធ បានចាប់បដិសន្ធិ

ឡើងអស់រយៈពេលជាង២៦០០ឆ្នាំកន្លងមក។ នៅទីនេះ អាត្មាភាពមាន សំណាងរកឃើញនូវសត្វក្រៀលក្រហម Sarus Crane យ៉ាងស្អាតអស្ចារ្យ កម្រនឹងបានជួប។ វាជាសត្វបក្សីមួយប្រភេទដែលមនុស្ស និងសត្វសាហាវ កំពុងតែគំរាមកំហែងដល់ជីវិតរបស់ពួកវា។ ហេតុនេះ អាត្មាភាពបាន ចាប់ផ្តើមស្វែងយល់ និងខិតខំការពារជីវិតរបស់ពួកវា។

ដំបូងឡើយមានសត្វក្រៀលក្រហមមួយគូ មករស់នៅក្នុងបរិវេណ ព្រះវិហារ **"វៀតណាមហ្វិកវ៉ុកទី"** (ពុទ្ធារាមវៀតណាម)។ រយៈពេលជាង១០ឆ្នាំ កន្លងមក ហ្វូងសត្វនេះបានកើនចំនួនទៅដល់៤៤ក្បាល ហើយបានរស់នៅជុំវិញ បរិវេណនៃឧទ្យាន**លុម្ពិនីវ័ន្ត**។ ដោយសារ ការខិតខំការពារសត្វក្រៀលក្រហម នេះ បានជាអាត្មាភាពមានឱកាសរស់នៅយ៉ាងស្និតស្មួតនិងល្អប្រសើរ ជាមួយនឹងធម្មជាតិ។

ប៉ុន្តែរឿងរ៉ាវពុំទាន់បញ្ចប់នៅត្រឹមនេះទេ ទង្វើតូចតាចប្រកបដោយ កុសលកម្មនេះ បាននាំមកនូវរឿងចម្លែកផ្សេងៗជាច្រើន ដែលអាត្មាភាព នឹងជំណាលប្រាប់ពុទ្ធបរិស័ទ និង មិត្តអ្នកអាននៅក្នុងសៀវភៅនេះ។ អាត្មាភាពមានជំនឿជឿជាក់យ៉ាងមុតមាំថា ប្រសិនបើយើងប្រកាន់ខ្ជាប់នូវ បំណងប្រាថ្នា ប្រព្រឹត្តតែអំពើកុសលនោះ យើងនឹងបានប្រទះជួបនូវ កុសលផល និងនិមិត្តល្អៗអស្ចារ្យជាច្រើនក្នុងជីវិតនេះជាពុំខាន។ នេះក៏ជា ចំណុចពិសិដ្ឋអស្ចារ្យ ដែលខ្លួនអាត្មាភាពផ្ទាល់បានទទួលយក និងមាន

បទពិសោធន៍អនុវត្តជាក់ស្តែងក្នុងជាតិនេះ ហើយអាត្មាភាពមានបំណងផ្សព្វផ្សាយ ចែករំលែកបទពិសោធន៍ទាំងនេះជូនដល់ពុទ្ធបរិស័ទ និងមិត្តអ្នកអានទាំងឡាយអោយបានជ្រាប។

**ហ៊ុយ៉ែន ឌីវ**
***Huyen Dieu***

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាពសូមសំដែងនូវសេចក្តីដឹងគុណចំពោះ

- ទឹកដីវៀតណាម ជាទីកំណើតរបស់អាត្មាភាព
- លោកឪពុក អ្នកម្តាយ
- គ្រូបាធ្យាយទាំងឡាយ ដែលបានបង្ហាត់បង្រៀននូវសិល្បវិធីដល់អាត្មាភាពសម្រាប់ភាពជោគជ័យ និងសេចក្តីសុខក្សេមក្សាន្តក្នុងជីវិតនេះ។
- បណ្តាប្រទេសដែលបានផ្តល់ឱកាសដល់អាត្មាភាព សម្រាប់ការស្នាក់អាស្រ័យប្រកបការងារសំរេចបាននូវបំណងប្រាថ្នា ធ្វើបុណ្យកុសលក្នុងជាតិនេះ
- មិត្តភក្តិ ញាតិញោម និងសិស្សទាំងឡាយដែលបានជួយឧបត្ថម្ភដល់អាត្មាភាព ក្នុងការងារជាកុសលកម្ម។
- ជាចុងក្រោយបង្អស់ គឺសូមថ្លែងអំណរគុណ ចំពោះសត្វក្រៀលដែលបានផ្តល់ឱកាសដល់អាត្មាភាព សម្រាប់រស់នៅយ៉ាងស្និទ្ធស្នាលនឹងធម្មជាតិ និងបានសំរេចបន្ថែមនូវការងារជាប្រយោជន៍ដល់មនុស្សលោក។

**ទៀន យឹវ**

# ព្រះវិហារអន្តរជាតិដំបូងបង្អស់នៅនគរព្រះ

ថ្វីត្បិតតែ ជីវិតអាត្មាភាពមួយភាគធំធ្លាប់បានរស់នៅឯបរទេស ប៉ុន្តែចិត្ត និងអារម្មណ៍អាត្មាភាព តែងតែឆ្ពោះទៅរកមាតុប្រទេសរបស់ខ្លួនព្រមទាំងមានបំណងប្រាថ្នា ស្វែងរកឱកាសជួយដល់ប្រទេសជាតិ ដើម្បីតបស្នងសងគុណដល់ប្រទេស ដែលជាទីកំណើតរបស់អាត្មាភាព និងដើម្បីនឹករំឭកដល់គុណូបការៈនៃលោកឪពុក អ្នកម្តាយ គ្រូបាធ្យាយ និងមិត្តភក្តិទាំងឡាយ។ នេះគឺជាមូលហេតុ ដែលញ៉ាំងអោយអាត្មាភាពមានឆន្ទៈយ៉ាងមុតមាំ ប្រមូលអស់កម្លាំងកាយចិត្ត ដើម្បីកសាងនូវព្រះវិហារ**ហ្វឹករ៉ុកទី** ដែលជាព្រះវិហារវៀតណាមដំបូងបង្អស់ ស្ថិតនៅលើនគរព្រះ នាប្រទេស**ឥណ្ឌា**។

ជាការធម្មតា គេតែងតែយកចិត្តទុកដាក់ដល់កិច្ចការអ្វីមួយដែលជាទីស្រលាញ់គាប់ចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ពេលវេលាភាគច្រើនគឺសម្រាប់តែការប្រកបការងារប្រចាំថ្ងៃ ចំពោះអាត្មាភាព ការស្រាវជ្រាវរៀនសូត្របន្ថែម ការធ្វើទស្សនៈកិច្ច ការថ្វាយបង្គំនៅទីកន្លែងជាទីសក្ការៈ និងការសាងបុណ្យកុសលនោះ គឺជាចំណង់ចំណូលចិត្តនៃអាត្មាភាព។

ដោយសារកុសលផលបុណ្យដែលអាត្មាភាពបានទទួលនោះ អាត្មាភាពមានសំណាង បានកសាងនូវព្រះវិហារទីពីរនៅប្រទេស**នេប៉ាល់** ដែល

មានឈ្មោះថា **វៀតណាមហ្វីកវ៉ុកទី** (ព្រះវិហារជាតិវៀតណាម) នៅឯ **លុម្ពិនីវ័ន្ត**នៃព្រះរាជាណាចក្រ**នេប៉ាល់** ជាកន្លែងសក្ការៈដ៏ពិសិដ្ឋដែលសៀវភៅជាច្រើនបានសរសេររំឭកដល់ទីនេះ។

ដែនដីនេះកាលពីដើមឡើយ គឺជាមហានគរនៃ**ព្រះបាទសុទ្ធោទនៈ** ហើយទីនេះក៏ជាទីប្រសូតនៃ**ព្រះរាជបុត្រាសិទ្ធត្ថ** ដែលស្ថិតនៅក្នុងសក្យវង្ស កាលពីពេលជិត២៦០០ឆ្នាំកន្លងទៅ។

នៅក្នុងកំណត់ត្រារបស់លោកគ្រូ **ថាំង ចេង** ជាអ្នកធ្វើធម្មយាត្រាជនជាតិចិនដ៏ល្បីល្បាញ បានបង្ហាញអោយយើងដឹងថា ព្រះរាជាណាចក្រនេះគឺជាតំបន់មួយ ដែលមានផ្ទៃដីលាតសន្ធឹងប្រមាណ ១,៨៨០គីឡូម៉ែត្រ ស្ថិតនៅក្នុងតំបន់តេរ៉ាយ ក្រោមជើង**ភ្នំហិមពាន្ត**ដ៏ធំមហិមា។ នៅក្នុងឆ្នាំ ៥៦៣ មុនគ្រិស្តសករាជ ដោយទទួលយកព្រះរាជានុញ្ញាតពីព្រះរាជិនី **ព្រះនាងមាយាទេវី** បានយាងព្រះរាជដំណើរចាកចេញ ពីព្រះរាជវាំងឆ្ពោះទៅកាន់ស្រុកកំណើតរបស់ខ្លួន ដែលស្ថិតនៅក្រុង**ទេវទហៈ** ដើម្បីប្រសូតព្រះរាជបុត្រជាលើកដំបូងបង្អស់តាមប្រពៃណីរបស់ខ្លួន។ នៅពេលព្រះនាងបានយាងព្រះរាជដំណើរចាកចេញពីរាជធានីប្រមាណ ២៥គីឡូម៉ែត្រ ដោយកំពុងឆ្លងកាត់សួនឧទ្យានមួយក្នុងភូមិ**លុម្ពិនីវ័ន្ត** ព្រះនាងក៏ស្រាប់តែប្រសូត **ព្រះរាជបុត្រាសិទ្ធត្ថ** នៅក្រោមដើមសាលព្រឹក្សមួយក្នុងសួនឧទ្យាននេះ។

នៅឆ្នាំ២៥០ មុនគ្រិស្តសករាជ **ព្រះបាទអសោក** រាជាធិរាជព្រមទាំង

បរិវារហែហម បានយាងព្រះរាជដំណើរធម្មយាត្រាមកកាន់ទីកន្លែងដ៏ពិសិដ្ឋនេះ ហើយក៏បានបញ្ចុះសសរសិលាចារឹកមួយយ៉ាងធំ ដើម្បីឧទ្ទិសចំណាំដល់ទីនេះ។ អស់រយៈពេលជាច្រើនសតវត្សក្រោយមក ជាអកុសលដោយសារភាពចលាចលខាងនយោបាយ និងការប៉ះទង្គិចខាងសាសនា បណ្តាលអោយមនុស្សម្នា បំភ្លេចចោលនូវទីកន្លែងពិសិដ្ឋជាទីសក្ការៈនេះ។

ថ្ងៃមួយ នាដើមនិទាឃរដូវឆ្នាំ១៩៦៩ អាត្មាភាពបានធ្វើដំណើរធម្មយាត្រាមកដល់**លុម្ពិនីវ័ន្ត**នេះ ពេលដែលបានមកឃើញទិដ្ឋភាពជាក់ស្តែងជាទីសក្ការៈនេះ អាត្មាភាពមានការតក់ស្លុត និងរន្ធត់ចិត្តយ៉ាងខ្លាំង ដោយឃើញកន្លែងជុំវិញសសរសិលាចារឹកកត់ត្រា និងឧទ្ទិសដល់ទីប្រសូតរបស់ព្រះសម្មាសម្ពុទ្ធនោះ ត្រូវបានពង្រាយលាមករបស់មនុស្សពាសពេញ អាត្មាភាពបានដើរជុំវិញទីនេះដោយក្តីក្តុកក្តួល និងទុក្ខព្រួយក្នុងចិត្តព្រមទាំងបានបួងសួងថា "ខ្ញុំព្រះករុណា សូមព្រះអង្គមេត្តាជួយដល់ខ្ញុំព្រះករុណាអោយបានឃើញទីកន្លែងនេះបានរស់រានឡើងវិញ និងមានការរីកចម្រើននៅមុនពេលខ្ញុំព្រះករុណាលាចាកលោកនេះ ប្រសិនបើទីសក្ការៈនេះជាទីប្រសូតរបស់ព្រះអង្គពិតមែននោះ"។

ចាប់ពីពេលនោះមក អាត្មាភាពបានចងចាំ និងយកចិត្តទុកដាក់រំឭកដល់បញ្ហានេះជានិច្ច នៅក្នុងពេលសំដែងបកស្រាយព្រះ ធម៌ ដល់ពួកបរិស័ទ ឬនៅក្នុងពេលបង្រៀនពួកសិស្សមហាវិទ្យាល័យ ផ្នែកប្រវត្តិសាស្ត្រអាស៊ីនិង

ទំនាក់ទំនងអន្តជាតិ អាត្មាភាពតែងតែបានបកស្រាយនិងធ្វើការប្រៀបធៀប យ៉ាងដូច្នេះថា **លុម្ពិនីវ័ន្ត**មានសារៈសំខាន់ ចំពោះព្រះពុទ្ធសាសនាដូចគ្នានឹង ទីសក្ការៈមេក្កា(Mecca)ចំពោះសាសនាឥស្លាម វិមានវ៉ាទិកង់(Vaticang) ចំពោះសាសនាកាតូលិក បេណារេ(Benares)ចំពោះសាសនាហិណ្ឌូ ឬ ក្រុងហេរូសាឡិម(Jerusalem)ចំពោះសាសនាពួកហ្សីហ្វផងដែរ។ ទោះបី យ៉ាងណាក៏ដោយ នៅពេលនោះ**លុម្ពិនីវ័ន្ត**ត្រូវបានគេបោះបង់ចោលគួរអោយ អាណោចអាធ័ម។

កូនសិស្សរបស់អាត្មាភាពមួយចំនួន ដែលបានបម្រើការងារនៅតាម អង្គការអន្តរជាតិនានា បានយកចិត្តទុកដាក់ដល់ការខ្វល់ខ្វាយរបស់អាត្មាភាព ហើយពួកគេបាន ប្រមូលកម្លាំងចលនាយ៉ាងស្ងាត់ស្ងៀមអស់រយៈពេលជាង ១០ឆ្នាំ ដើម្បីជួយសង្គ្រោះដល់**លុម្ពិនីវ័ន្ត**ដ៏ពិសិដ្ឋនេះ។ ការខិតខំប្រឹងប្រែង អស់ពីដួងចិត្តនេះ ត្រូវបានធ្វើឡើងរហូតដល់ឆ្នាំ១៩៩៣ ទើបបានចេញជា លទ្ធផលដូចតទៅ : ព្រះមហាក្សត្រ **ប៊ីរ៉េង់ជ្រា** ព្រមទាំងរាជរដ្ឋាភិបាលនៃ ប្រទេសនេប៉ាល់ បានយល់ព្រមប្រទានដីមួយកន្លែងនៅ**លុម្ពិនីវ័ន្ត**ដល់រូបអាត្មាភាព ដើម្បីរៀបចំសាងសង់ ព្រះវិហារវៀតណាមជាលើកទី២របស់អាត្មាភាព ប៉ុន្តែនេះ គឺជាព្រះវិហារអន្តរជាតិលើកដំបូងបង្អស់នៅលើទីកន្លែងប្រសូត របស់ព្រះសម្មាសម្ពុទ្ធនៃយើង។

¤¤¤¤¤

# សេចក្តីសម្រេចចិត្តមួយយ៉ាងផ្សេងទៀត

នៅឆ្នាំ១៩៨៧ អាត្មាភាពបានចាប់ផ្តើមប្រមូលអស់កម្លាំងកាយចិត្តសម្រាប់ការសាងសង់ព្រះវិហារវៀតណាមមួយនៅ**ពុទ្ធគយា** នៃប្រទេស**ឥណ្ឌា**។ នេះគឺជាព្រះវិហារវៀតណាមដំបូងបង្អស់ ដែលបានសាងសង់នៅលើដែនដីនគរព្រះ ហើយអាត្មាភាពក៏បានចាត់ទុកថាអំពើនេះ គឺជាការដឹងគុណចំពោះព្រះអង្គ ព្រមទាំងជាអំណោយខាងផ្លូវចិត្តជូនចំពោះមាតុប្រទេសនៃអាត្មាភាពផងដែរ។ ប៉ុន្តែនៅពេលចាប់ផ្តើមកិច្ចការសាងសង់នេះ ទើបអាត្មាភាពយល់ច្បាស់ថា យើងកំពុងជួបប្រទះនូវការលំបាកគ្រប់បែបយ៉ាង។

**ពុទ្ធគយា** ជាកន្លែងមួយស្ថិតនៅក្នុង**ក្រុងគយា** នៃ**រដ្ឋប៊ីហារ**ប្រទេស**ឥណ្ឌា**។ អាត្មាភាពបានស្គាល់មនុស្សម្នាជាច្រើននៅទីនេះ ពីថ្នាក់ដឹកនាំអាជ្ញាធរដែនដីរហូតដល់មន្ត្រីរាជការនៅមជ្ឈិម ពួកគេតែងតែជួយដល់អាត្មាភាពជានិច្ច។ ប៉ុន្តែ ការរំខានក៏បានកើតមានឡើងក្នុងទំនាក់ទំនងជាមួយពួកគេផងដែរ នៅពេលពួកគេមកសួរសុខទុក្ខអាត្មាភាព ដោយបាននាំមកជាមួយនូវភ្នាក់ងារសន្តិសុខ និងប៉ូលិសជាច្រើន ដែលរំខានដោយអចេតនាដល់ជីវិតរស់នៅយ៉ាងស្ងៀមស្ងាត់របស់អាត្មាភាព។ ម្យ៉ាងទៀត ដោយសារមនោសញ្ចេតនា និងការងារទំនាក់ទំនងជាមួយគ្នា មានថ្ងៃខ្លះ អាត្មាភាពត្រូវបានអញ្ជើញចូលរួមទទួលទានអាហារពេលព្រឹក ជាមួយមន្ត្រីរាជការចំនួន

ប្រាំពីររូប នៅតាមទីកន្លែងខុសៗគ្នាទាំងប្រាំពីរ។ ក្រៅពីនេះ អាត្មាភាពក៏ត្រូវចូលរួមពិធីលៀងភោជនាហារជាច្រើន ដែលនាំអោយរំខានដល់ពេលវេលាសាងសង់វត្តអារាមរបស់អាត្មាភាព។ ដោយហេតុនេះហើយ អាត្មាភាពបានផ្ចង់ស្មារតី ចម្រើនសេចក្តីភាវនា និងបួងសួងដូចតទៅ : "ខ្ញុំព្រះករុណាសូមអារាធនា ព្រះពុទ្ធទាំងឡាយ ព្រះពោធិសត្វ មហានាគរាជ សេនាការពារព្រះធម៌ ព្រមទាំងបារមីវត្ថុស័ក្តិសិទ្ធិទាំងឡាយនៃមាតុប្រទេស សូមអោយមានអ្នកណាម្នាក់មកជំនួសខ្ញុំព្រះករុណា ដើម្បីគេចូលរួមពិធីជប់លៀងយ៉ាងច្រើនដូចនេះទៅ ព្រោះខ្ញុំព្រះករុណាបានមកដល់ទីនេះ គឺដើម្បីតែសាងសង់វត្តសម្រាប់ព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ប៉ុន្តែដោយសារមានគេរាប់អានជាច្រើនហើយបានអញ្ជើញខ្ញុំព្រះករុណាចូលរួមពិធីជាច្រើន រហូតទៅដល់ខ្ញុំព្រះករុណាពុំអាចទទួលយកតទៅទៀតបានឡើយ"។

ភាពចម្លែកអស្ចារ្យ បានកើតមានឡើងរយៈពេលពីរបីខែក្រោយមកនោះ គឺព្រះតេជគុណ**អ៊ូប៉ាភ៉ា** បាននិមន្តមកគង់នៅទីនេះដើម្បីប្រតិបត្តិធម៌ ហើយក៏យល់ព្រមដោយក្តីរីករាយ ចំពោះការចូលរួមពិធីនានាជំនួសអាត្មាភាព។ (លោកបានទទួលមហាបរិញ្ញាបត្រខាងពុទ្ធសាសនា ហើយលោកក៏ជាព្រះសង្ឃដ៏ល្បីល្បាញមួយអង្គខាងវិស័យអប់រំនៅប្រទេសភូមាផងដែរ)។

មួយឆ្នាំកន្លះក្រោយមក មានព្រះសង្ឃមួយអង្គទៀតបាននិមន្តមកដល់ទីនេះ គឺព្រះតេជគុណ **អ៊ូនីនេនដា** លោកក៏យល់ព្រមជំនួសអាត្មាភាព

ចូលរួមពិធីនានា ដែលកាន់តែកើនឡើងជាញឹកញាប់ ហេតុនេះទើបធ្វើអោយអាត្មាភាពមានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងាររបស់ខ្លួន។ (ព្រះតេជគុណអ៊ូនីនេនដា ជាបណ្ឌិតផ្នែកប្រវត្តិសាស្ត្រ បច្ចុប្បន្នជានាយករងនៃសាកលវិទ្យាល័យពុទ្ធសាសនា**រ៉ងហ្គោន** នៅប្រទេស**ភូមា**)។ តាមទំនៀមទម្លាប់នៅទីនេះ ភ្ញៀវដែលត្រូវបានអញ្ជើញចូលរួមពិធីនានានោះ មិនត្រឹមតែបានទទួលទានអាហារវិសេសវិសាល ប្រាក់ និងវត្ថុអនុស្សាវរីយ៍មួយចំនួនប៉ុណ្ណោះទេ គេថែមទាំងទទួលបាននូវសំបុត្រយន្តហោះដើម្បីទៅទស្សនៈកិច្ចនៅកន្លែងផ្សេងៗផងដែរ។

ដោយសារគុណូបការៈរបស់លោកទាំងពីរអង្គនេះហើយ ទើបបានជាអាត្មាភាពអាចមានឱកាសចៀសវាងការចូលរួមកិច្ចការទំនាក់ទំនងសង្គមទាំងនេះដើម្បីប្រមូលផ្តុំពេលវេលា និងកម្លាំងសម្រាប់ការសាងសង់វត្តដែលកំពុងបានដំណើរការជាបណ្តើរៗហើយនោះ។ អាត្មាភាពពិតជាកោតសរសើរចំពោះលោកសង្ឃទាំងពីរអង្គ ដែលមានសេចក្តីក្លាហានទទួលយកនូវសំណូមពរជំនួសអាត្មាភាពចូលរួមកិច្ចការសង្គមទាំងនោះ។ ម្ល៉ោះហើយ ឱកាសមួយបានកើតមានឡើងយ៉ាងចៃដន្យ ដែលនាំអោយអាត្មាភាពបានទៅដល់ប្រទេស**នេប៉ាល់**។ នោះគឺនៅពេលព្រឹកព្រលឹមនាថ្ងៃមួយអាត្មាភាពកំពុងត្រៀមខ្លួនចេញទៅក្រៅដើម្បីពិនិត្យមើលកិច្ចការសាងសង់ ស្រាប់តែបានឮសំឡេងស៊ីរ៉ែនយ៉ាងកងរំពង។ រថយន្តប៉ូលិសមួយ

បានបើកចូលទៅក្នុងព្រះវិហារ និងមានរថយន្តមួយចំនួនទៀតបរតាមក្រោយ។ អាត្មាភាពបានដើរចេញទៅទទួលស្វាគមន៍ ភ្ញៀវដោយគិតក្នុងចិត្តថា ប្រហែល ជាមានក្រុមមន្ត្រីសំខាន់ណាមួយមកសួរសុខទុក្ខដល់ ព្រះវិហាររបស់អាត្មាភាពហើយមើលទៅ!។ អាត្មាភាពមានការភ្ញាក់ផ្អើលពិតមែន ពីព្រោះភ្ញៀវទាំងនោះ គឺជាកូនសិស្សរបស់អាត្មាភាពដែលអាត្មាភាពធ្លាប់ បានបង្ហាត់បង្រៀនព្រះធម៌ដល់ពួកគេ កាលពីរបីឆ្នាំមុន ហើយពួកគេក៏ជា អ្នកបានចូលរួមវិភាគទានដើមដំបូងបង្អស់ សម្រាប់ការសាងសង់ព្រះវិហារ វៀតណាមនៅទីនេះ។ ក្នុងចំណោមភ្ញៀវទាំងនេះ គឺមានទាំងមេបញ្ជាការ ប៉ូលីស**រដ្ឋបីហារ** និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការរដ្ឋាភិបាល**ឥណ្ឌា**ផងដែរ។ នេះគឺជាមូលហេតុដែលក្រុមនេះត្រូវបាន ហែហមដោយពួកប៉ូលីសយ៉ាងច្រើន កុះករដូច្នេះឯង។

ចំណែកឯអាត្មាភាពវិញ គឺមានការងឿងឆ្ងល់យ៉ាងខ្លាំង ដោយសារ វត្តមានយ៉ាងចៃដន្យរបស់បងប្អូនញាតិធម៌នៃអាត្មាភាព នៅក្នុងចំណោម ភ្ញៀវយ៉ាងច្រើនកុះករបែបនេះ ព្រោះពួកគាត់ តែងតែជូនដំណឹងដល់ អាត្មាភាពទុកជាមុន នៅពេលណាចង់មកសាកសួរសុខទុក្ខដល់អាត្មាភាព។ ដោយយល់ឃើញនូវការងឿងឆ្ងល់របស់អាត្មាភាព បានជាបងប្អូនញាតិធម៌ ពន្យល់បកស្រាយដូចតទៅ ៖

"សូមថ្វាយបង្គំព្រះតេជគុណ ពួកខ្ញុំព្រះករុណាបានមកដល់ថ្ងៃនេះ

ដោយមានការប្រញាប់ប្រញាល់ពេក ទើបពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ជំរាបជូនដំណឹងជាមុនបានឡើយ"។

បន្ទាប់មកពួកគេបានសុំការអនុញ្ញាតពីអាត្មាភាព ចូលទៅក្នុងសាលធំមួយនៃព្រះវិហារ ដើម្បីធ្វើការគោរពថ្វាយបង្គំចំពោះព្រះពុទ្ធបដិមា។ នៅពេលកំពុងពិសាតែជុំគ្នា មានអ្នកតំណាងក្រុមម្នាក់ឈរឡើងរួចពោលយ៉ាងឱឡារិកថា : "សូមថ្វាយបង្គំព្រះតេជគុណ បំណងប្រាថ្នារបស់ព្រះតេជគុណត្រូវបានក្លាយទៅជាការពិតហើយ"។ អាត្មាភាពបានសួរវិញថា : "ការពិតអាត្មាភាពមានប្រាថ្នាច្រើនណាស់ តើបងប្អូនចង់និយាយអំពីប្រាថ្នាមួយណាហ្នឹង?"។ គាត់ក៏បានជំរាបជូនអាត្មាភាពវិញយ៉ាងដូច្នេះថា : "ព្រះតេជគុណរយៈពេលជាង១០ឆ្នាំមុន នៅពេលព្រះតេជគុណបានដឹកនាំក្រុមយើងខ្ញុំធ្វើដំណើរធម្មយាត្រាទៅកាន់**លុម្ពិនីវ័ន្ត** ដែលជាទីប្រសូតនៃព្រះសម្មាសម្ពុទ្ធនោះ ព្រះតេជគុណធ្លាប់មានសង្ឃដីកាថា ព្រះអង្គមានក្ដីសុបិន្តយ៉ាងធំបំផុតគឺបានមើលឃើញ**លុម្ពិនីវ័ន្ត** មានការរីកចម្រើនសមសួន និងតួនាទីជាប្រវត្តិសាស្ត្រដ៏អស្ចារ្យ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងមកពួកខ្ញុំព្រះករុណាបានបំពេញការងារនេះយ៉ាងស្ងៀមស្ងាត់ រហូតទទួលបានលទ្ធផលនៅពេលនេះ គឺព្រះមហាក្សត្រ **ប៊ីរ៉េង់ដ្រា** (Birendra) និងនាយករដ្ឋមន្ត្រី **ខេ.ប្រាសាត** (K.Prasad) នៃរាជរដ្ឋាភិបាលនេប៉ាល់ បានយល់ព្រមប្រទានដីមួយកន្លែងនៅ**លុម្ពិនីវ័ន្ត**ជល់ព្រះតេជគុណហើយណា៎។ ព្រះមហាក្សត្រ ក៏បានប្រទាន

យន្តហោះមួយជើងសំរាប់ដឹកពួកខ្ញុំមកកាន់ពុទ្ធគយា ដើម្បីនិមន្តព្រះតេជគុណទៅទទួលយកដីនៅប្រទេស**នេប៉ាល់**"។

នៅក្នុងជីវិតរបស់យើង មានរឿងខ្លះកើតមានឡើងហួសពីការស្មាន នឹងសេចក្តីប្រាថ្នារបស់ខ្លួន ពេលនោះហើយ ដែលយើងមានការស្ទាក់ស្ទើរ ពុំដឹងជាត្រូវឆ្លើយតបយ៉ាងដូចម្តេចដែរ។ នេះពិតជាស្ថានភាពនៃអាត្មាភាព នៅពេលនោះមែន។ ដោយពុំដឹងច្បាស់ថា ត្រូវធ្វើយ៉ាងណានៅពេលបានស្តាប់សេចក្តីជូនដំណឹងនេះ អាត្មាភាពក៏ខំពន្យារពេលសម្រេចចិត្តដោយបានពោលថា : "ឥឡូវនេះ អាត្មាភាពគិតថាយើងគួរតែនាំគ្នាទៅគោរពបូជានៅក្រោមដើមសាលព្រឹក្ស ដែលព្រះអង្គទ្រង់បានទទួលការត្រាស់ដឹងនៅទីនោះ រីឯអាត្មាភាពវិញ គឺត្រូវចូលទៅក្នុងព្រះវិហារ ដើម្បីបួងសួងដល់ព្រះអង្គអោយមានការរម្ងាប់ចិត្ត ហើយធ្វើសមាធិដើម្បីមើលឃើញថា ការងារនេះជាការល្អដែរឬទេ"។

ការពិត អាត្មាភាពមានបំណងចាកចេញពីព្រះវិហារ នៅពេលដែលពួកគេនាំគ្នាទៅកាន់ដើមពោធិព្រឹក្ស។ អាត្មាភាព ចង់បាននៅស្ងប់ស្ងាត់តែម្នាក់ឯង ដើម្បីពិចារណាទៅលើកិច្ចការទាំងពួង។ កិច្ចការសាងសង់ព្រះវិហារនៅ**ពុទ្ធគយា**នេះ ទើបតែសម្រេចបានពាក់កណ្តាល រីឯការងារនានាដែលនឹងត្រូវធ្វើនោះនៅសេសសល់យ៉ាងច្រើននៅនឹងកន្លែង។ តើអាត្មាភាពត្រូវបោះបង់ចោលកិច្ចការទាំងនេះ ដើម្បីទៅកាន់**លុម្ពិនីវ័ន្ត**យ៉ាងដូចម្តេចកើត?

ប៉ុន្តែបងប្អូនញាតិញោមនៅតែតាមអាត្មាភាពជាប់ ហើយពោលថា : ពួកគេបានទៅគោរពបូជាចំពោះដើមពោធិព្រឹក្សរួចហើយ មុនពេលពួកគេបានមកដល់ទីនេះ។ អាត្មាភាពរឹតតែមានការស្ទាក់ស្ទើរ ដោយពុំដឹងថាត្រូវធ្វើដូចម្ដេចឡើយ។ ពួកគេបានខិតខំបញ្ចុះបញ្ចូលអាត្មាភាពថា : "ព្រះតេជគុណកិច្ចការនេះប្រញាប់ណាស់ សូមព្រះអង្គមេត្តាត្រៀមរៀបចំចាកចេញជាមួយពួកខ្ញុំព្រះករុណាភ្លាមទៅ ព្រោះឱកាសដ៏ល្អនេះមិនអាចមានជាលើកទីពីរឡើយ។ អ្វីៗគឺត្រូវបានរៀបចំហើយជាស្រេចនៅប្រទេស**នេប៉ាល់** ពួកគេកំពុងរង់ចាំទទួលស្វាគមន៍ព្រះតេជគុណនៅទីនោះ។ ព្រះតេជគុណពុំអាចបដិសេធការនិមន្តនេះបានឡើយ"។ ពួកគេបានអង្វរករអាត្មាភាពយ៉ាងទទូចម្ល៉ោះហើយ អាត្មាភាពបានយល់ព្រមដោយសារពំនោលមួយថា : "សូមព្រះតេជគុណកុំភ្លេចថា ព្រះសក្យមុនីបានប្រសូតឡើងតែម្ដងគត់ទេ ព្រះអង្គ!"។ អាត្មាភាពស្ទើរតែ គ្មានពេលគ្រប់គ្រាន់សម្រាប់វិលត្រឡប់មកកាន់បន្ទប់របស់អាត្មាភាព ដើម្បីរៀបចំស្បង់ចីវរ និងរបស់ខ្លះដាក់ចូលទៅក្នុងថង់យាម រួចហើយក៏ប្រញាប់ប្រញាល់ឡើងរថយន្តជាមួយនឹងញាតិញោមទាំងនោះ។ ពេលពួកគេបានមកដល់ព្រះវិហាររហូតដល់នាំគ្នាឡើងលើរថយន្តនោះ គឺមានរយៈពេលត្រឹមតែមួយម៉ោងគត់ប៉ុណ្ណោះ រឿងទាំងឡាយបានកើតមានឡើងក្នុងមួយរំពេចនេះ មិនខុសអ្វីពី "ការចាប់ពង្រត់" ឡើយ។

អាកាសយានដ្ឋាន**គយា** ស្ថិតនៅចម្ងាយ១២គីឡូម៉ែត្រពីក្រុង**ពុទ្ធគយា**។

អាកាសយានដ្ឋាននេះ ទើបនឹងបានសម្ពោធនៅពេលថ្មីៗហើយយន្តហោះដែលមកទទួលអាត្មាភាព គឺជាយន្តហោះបរទេសដំបូងបង្អស់ដែលបានចុះចតនៅទីនេះ។

ក្រោយរយៈពេលម្ភៃនាទីបន្ទាប់ពីបានចាកចេញពី**ពុទ្ធគយា** យន្តហោះដែលអាត្មាភាពធ្វើដំណើរ បានហោះតាមបណ្តោយជួរ**ភ្នំហិមពាន្ត**។ កាលពីមុនមកទេសភាពភ្នំព្រិល និង ភាពវិសេសវិសាលអស្ចារ្យនៃជួរ**ភ្នំហិមពាន្ត**នោះតែងតែបានទាក់ទាញអារម្មណ៍របស់អាត្មាភាពពុំដាច់ឡើយ។ ប៉ុន្តែនៅពេលនេះអាត្មាភាពពុំបានយកចិត្តទុកដាក់សំឡឹងមើលជួរភ្នំ ដែលជាប់គ្នាយ៉ាងរជីកក្រោមពន្លឺចែងចាំង យ៉ាងត្រចះត្រចង់នៃព្រះអាទិត្យសោះ ព្រោះអាត្មាភាពមានអារម្មណ៍ពុំស្ងប់ឡើយ។ អាត្មាភាពមានការព្រួយបារម្ភ ព្រមទាំងមានការមួម៉ៅ ចំពោះបងប្អូនញាតិញោមទាំងនេះផង ព្រោះពួកគេបាននាំអោយអាត្មាភាពស្ថិតនៅក្នុងស្ថានភាពមួយយ៉ាងលំបាក ដោយអាត្មាភាពពុំបានត្រៀមទុកជាមុនបន្តិចណាសោះឡើយ។

ក្រោយមក ពួកគេបានជំរាបដល់អាត្មាភាពថា : "ព្រះតេជគុណ នេះជាលើកដំបូងហើយ ដែលពួកខ្ញុំព្រះករុណាបានឃើញ ព្រះតេជគុណកើតបន្លាពោធិ"។ (នេះគឺ ជាពាក្យកំប្លែងរបស់បងប្អូនជាមួយនឹងអាត្មាភាពដែលមានអត្ថន័យថា "មួម៉ៅ" ព្រោះយើងទាំងអស់គ្នា សុទ្ធតែបានដឹងថាដើមពោធិពុំមានបន្លាទេ)។

អាត្មាភាពច្បាស់ជាមានការអាក់អន់ចិត្តពិតមែន ប៉ុន្តែពុំដឹងជាត្រូវធ្វើយ៉ាងដូចម្តេចឡើយ ក្រៅពីបញ្ចេញសំឡេងគ្រហែម ដើម្បីអោយគេដឹងថាអាត្មាភាពមានការមួម៉ៅពុំសប្បាយចិត្តសោះ។ អាត្មាភាពកំពុងរង់ចាំឱកាសល្អណាមួយ ដែលអាចយកជាមូលហេតុសម្រាប់អោយពួកគេវិលត្រឡប់មកកាន់**ពុទ្ធគយា**វិញ។ បើសិនជាពួកគេបានប្រព្រឹត្ត ឬពោលពាក្យអ្វីមួយពុំបានសមរម្យទេនោះ វាក៏អាចក្លាយទៅជាមូលហេតុគ្រាប់គ្រាន់ សម្រាប់អោយអាត្មាភាពបង្ខំពួកគេអោយវិលត្រឡប់ទៅវិញបាន។ ប៉ុន្តែ ពួកគេនៅរក្សាភាពស្ងៀមស្ងាត់ ដោយបានយល់ច្បាស់នូវគំនិតរបស់អាត្មាភាព។

ភាពមួម៉ៅក្នុងចិត្តរបស់អាត្មាភាព ពុំទាន់បានរំសាយអស់នៅឡើយនៅពេលដែលយន្តហោះបានចុះចតនៅឯអាកាសយានដ្ឋានអន្តរជាតិ**កដ្ឋមណ្ឌុ**។ នៅពេលទ្វារយន្តហោះបានបើកឡើង គឺអាត្មាភាពឃើញកម្រាលព្រំពណ៌ក្រហម ដែលត្រូវបានគេក្រាលទុករួចជាស្រេចហាក់បីដូចជាត្រៀមរង់ចាំទទួលស្វាគមន៍ភ្ញៀវរបស់រដ្ឋអ្វីចឹង។ ដោយយល់ថា ការត្រៀមទាំងអស់នេះ គឺសម្រាប់តែទទួលបងប្អូនប៉ុន្មាននាក់នោះ បានជាអាត្មាភាពប្រញាប់ប្រញាល់ជៀសកន្លែង សម្រាប់បងប្អូននោះដើរចេញទៅមុន។ ប៉ុន្តែបងប្អូនបានពោលថា ការត្រៀមរៀបចំនេះ គឺសម្រាប់ទទួលអាត្មាភាពហ្នឹងហើយ ការនេះរឹតតែនាំអោយអាត្មាភាព មានភាពរួញរាក្រែងរអែងកាន់តែខ្លាំងឡើង។ មន្ត្រីជាន់ខ្ពស់របស់ប្រទេស**នេប៉ាល់** កំពុងតែរង់ចាំទទួលអាត្មាភាព

នៅជើងជណ្តើរយន្តហោះ។ ក្នុងចំណោមនោះ អាត្មាភាពអាចមើលឃើញ រដ្ឋមន្ត្រីក្រសួងវប្បធម៌ ជាអ្នកដែលអាត្មាភាពធ្លាប់បានស្នើសុំជួបពិភាក្សាការងារ ប៉ុន្តែសំណើនោះត្រូវបានគេបដិសេធចោល។ ដោយពុំអាចគេចខ្លួនបានទៀតនោះ អាត្មាភាពក៏សំរេចចិត្តដឹកនាំគណៈប្រតិភូរបស់អាត្មាភាពចុះចេញពីយន្តហោះយ៉ាងក្លាហាន។ ក្រុមញាតិញោម និងអាត្មាភាពបានទទួលកម្រងផ្កាគ្រប់ៗគ្នា តាមទំនៀមទម្លាប់របស់ប្រទេស**នេប៉ាល់**។ បន្ទាប់មកគឺមានពិធីស្វាគមន៍ភ្ញៀវតាមរបៀបពិធីការយ៉ាងសមរម្យ។ លោក **ម៉ីសែល** កាលពីមុនគឺជាកូនសិស្សបារាំងរបស់អាត្មាភាព ហើយបច្ចុប្បន្ននេះជាសមាជិកនៃអង្គការយូណេសស្កូ(UNESCO) ខាងកម្មវិធីផ្លាស់ប្តូរវប្បធម៌ បានខ្សឹបដាក់ត្រចៀករបស់អាត្មាភាព នៅពេលឈរពីក្រោយខ្នងអាត្មាភាព ដោយមានសេចក្តីដូចតទៅ : "សូមថ្វាយបង្គំព្រះតេជគុណ មើលទៅព្រះតេជគុណពិតជាមានភាពសង្ហាមែនពិត ប៉ុន្តែជើងខោរបស់ព្រះតេជគុណ គឺមួយវែងមួយខ្លី"។ អាត្មាភាពបានងាកមើលចុះក្រោម វាពិតដូចគាត់ប្រាប់មែន។ ប្រហែលនេះ មកពីពេលអាត្មាភាពមានការធុញថប់នៅលើយន្តហោះ ទើបបណ្តាលអោយយកដៃមូលជើងខោម្ខាងឡើងដោយអចេតនាហើយមើល់ទៅ!។ ក្រោយពីពិធីស្វាគមន៍ជាផ្លូវការបានចប់រួចរាល់ហើយ ភាគីទាំងពីរបានអង្គុយចុះ ហើយចាប់ផ្តើមប្រជុំការងារដោយស្ថិតនៅក្នុងបរិយាកាសសេរី និងរីករាយក្រៃលែង បណ្តាលអោយកង្វល់ទាំងឡាយរបស់អាត្មាភាពរំសាយ

បាត់ដោយពុំដឹងខ្លួនឡើយ។ ប៉ុន្តែនៅចុងបញ្ចប់នៃពិធីជួបប្រជុំនោះ អាត្មាភាព បានទទួលនូវអារម្មណ៍តានតឹងជាថ្មីម្តងទៀត នៅពេលគណៈកម្មាធិការទទួល ភ្ញៀវរបស់ប្រទេសនេប៉ាល់បានប្រកាសថា :

"ព្រះមហាក្សត្រ ព្រមទាំងឯកឧត្តមនាយករដ្ឋមន្ត្រី សូមនិមន្តព្រះតេជគុណ គង់នៅក្នុងគេហដ្ឋានសម្រាប់ភ្ញៀវរបស់រដ្ឋ"។ "អត់ទេ! សូមអរគុណលោក ច្រើនណាស់។ នេះគឺមិនមែនសម្រាប់អាត្មាភាពទេ។ អាត្មាភាព គឺគ្រាន់តែ ជាមនុស្សសាមញ្ញម្នាក់ ហើយអាត្មាភាពចង់បានការស្នាក់នៅកន្លែងផ្សេង មិត្តញាតិរបស់អាត្មាភាពទាំងនេះ សុទ្ធតែជាអ្នកធ្វើការនៅតាមអង្គការ អន្តរជាតិនានា ហេតុនេះពួកគេគួរតែស័ក្តិសមជាភ្ញៀវរបស់រដ្ឋាភិបាលសម្រាប់ ការស្នាក់នៅទីនោះ។ អាត្មាភាពនឹងមានការទាក់ទងគ្នាតាមរយៈទូរស័ព្ទ យ៉ាងងាយស្រួលទេណ៎"។ នេះជាការឆ្លើយតបរបស់អាត្មាភាពទៅកាន់ ពួកគេ។

ភាគីនេប៉ាល់ពុំបានយល់ព្រមនឹងអាត្មាភាពទេ រីឯអាត្មាភាពវិញក៏ដូចគ្នា ដែរ។ ចុងក្រោយបង្អស់មានការសម្រុះសម្រួលមួយ គឺអាត្មាភាពត្រូវបាន គេរៀបចំអោយស្នាក់នៅសណ្ឋាគារ**យ៉ាក់យ៉ាទី** ជាសណ្ឋាគារលំដាប់ផ្កាយ ប្រាំយ៉ាងល្បីឈ្មោះមួយនៅទីក្រុង**កដ្ឋមណ្ឌុ** ដែលគេតែងតែប្រើជាពិសេស សម្រាប់ភ្ញៀវរបស់រដ្ឋាភិបាល**នេប៉ាល់**។ សណ្ឋាគារនេះមានសេវាកម្មយ៉ាង

ពិសេស ហើយភ្ញៀវដែលទទួលបានការស្នាក់នៅទីនេះ តែងតែត្រូវបានគេយាមកាមយ៉ាងហ្មត់ចត់។

បញ្ហាស្នាក់អាស្រ័យ ត្រូវបានដោះស្រាយរួចពុំយូរប៉ុន្មានឡើយ ក៏ស្រាប់តែបញ្ហាមួយផ្សេងទៀតបានកើតមានឡើង គឺពេលដែលបងប្អូនញាតិញោមបានជំរាបថា : "ព្រះមហាក្សត្រ បានសព្វព្រះរាជទ័យនិមន្តព្រះតេជគុណអោយចូលគាល់ព្រះអង្គដោយផ្ទាល់ នាវេលាពេលរសៀលថ្ងៃស្អែកនេះ។ បន្ទាប់មកនឹងមានពិធីមួយ ដែលព្រះតេជគុណត្រូវទទួលយកឯកសារកាន់កាប់ដីធ្លីជាផ្លូវការ។ អ្នកតំណាងនៃទីភ្នាក់ងារសារពត៌មាននានា ក៏ត្រូវបានអញ្ជើញចូលរួមនៅក្នុងពិធីនេះដែរ"។

ពេលបានស្តាប់ពាក្យទាំងអស់នេះ អាត្មាភាពរឹតតែមានការព្រួយបារម្ភក្នុងចិត្ត ព្រោះតែហេតុការណ៍ទាំងនេះ បានក្លាយទៅជារឿងសំខាន់ពិតមែនហើយ ប៉ុន្តែនេះក៏ជាគំនិតរបស់បងប្អូនញាតិញោមទាំងប៉ុន្មាននាក់ហ្នឹងដែរ។ ពួកគេចង់អោយព្រឹត្តិការណ៍នេះ បានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈសារពត៌មានក្នុងស្រុក និងសារពត៌មានអន្តរជាតិនានា។ បងប្អូនទាំងនេះបានជឿជាក់ថា ការធ្វើបែបនេះនឹងនាំអោយសហគមន៍ពុទ្ធសាសនាលើពិភពលោកយកចិត្តទុកដាក់ដល់ការថែរក្សា និងការអភិវឌ្ឍ**លុម្ពិនីវ័ន្ត** ដែលជាទីសក្ការៈបូជាជាពុំខាន។ អាត្មាភាព មានការយល់ផ្សេងពីគំនិតបែបនេះទៅវិញ ដោយបានពន្យល់ប្រាប់បងប្អូនញាតិញោមថា : "អាត្មាភាព

ចង់អោយយើងទាំងអស់គ្នាដំណើរការយ៉ាងស្ងាត់ស្ងៀម រួចហើយចាំផ្សព្វផ្សាយទៅអោយគេដឹងព្រគ្រប់គ្នា២ នៅពេលដែលការងារត្រូវបានបញ្ចប់យ៉ាងសព្វគ្រប់។ យើងអាចនឹងប្រទះជួបនូវឧបសគ្គមួយចំនួននៅពេលខាងមុខ ប្រសិនបើពេលនេះយើងនាំគ្នាផ្សព្វផ្សាយលាន់ឮហើយ នៅពេលដែលពុំអាចឆ្លងកាត់ការលំបាកបានទេនោះ យើងពិតជាមានការអាម៉ាស់យ៉ាងខ្លាំងព្រមទាំងអាចក្លាយទៅជាអ្នកភូតភរផងដែរ"។

យើងទាំងអស់គ្នាបានធ្វើការពិភាក្សា និងជជែកគ្នាយ៉ាងតានតឹងអស់រយៈពេលជាងបីម៉ោង ដោយពុំអាចឈានទៅដល់ការសម្របសម្រួលគ្នាបានឡើយ។ ជាចុងក្រោយ អាត្មាភាពបានលើកឡើងនូវសំណូមពរមួយដូចតទៅ : "អាត្មាភាពយល់ព្រមជួបជាមួយនឹងព្រះមហាក្សត្រ ប៉ុន្តែការចុះហត្ថលេខាលើឯកសាររវាងអាត្មាភាព និងអ្នកតំណាងរដ្ឋាភិបាលនេប៉ាល់នោះគឺមិនត្រូវមានវត្តមានរបស់អ្នកសារពត៌មានចូលរួមទេណា៎"។

ទីបញ្ចប់ ពួកគេក៏បានយល់ព្រមតាមសំណើរបស់អាត្មាភាព។ ថ្ងៃបន្ទាប់មក ក្រោយពេលបានចុះហត្ថលេខាជាមួយគ្នារួចហើយ អាត្មាភាពត្រូវបានគេរៀបចំអោយជិះយន្តហោះពិសេសមួយ ឆ្ពោះទៅកាន់**លុម្ពិនីវ័ន្ត**ដើម្បីជ្រើសរើសយកផ្ទៃដីសម្រាប់ការសាងសង់ព្រះវិហារ។ ថ្វីត្បិតតែ អាត្មាភាពបានធ្វើដំណើរមកកាន់**លុម្ពិនីវ័ន្ត**ជាច្រើនលើកហើយក៏ដោយ ប៉ុន្តែពេលនេះអាត្មាភាពបែរជាមានចិត្តសប្បាយរីករាយយ៉ាងខ្លាំងព្រោះ នេះជាលើកទីមួយ

ហើយ ដែលអាត្មាភាពបានជិះយន្តហោះគយគន់មើលទេសភាពនៃទីប្រសូត យ៉ាងពិសិដ្ឋរបស់ព្រះសម្មាសម្ពុទ្ធ ជាទីសក្ការៈនៃយើង។

អាត្មាភាពបានពោលទៅកាន់អ្នកបើកបរយន្តហោះ ទាំងក្ដីរំជើបរំជួលក្នុងចិត្តថា : "តើលោកអាចទូរស័ព្ទទៅសួរថ្នាក់ដឹកនាំរបស់លោកថា គេអាចផ្ដល់អោយអាត្មាភាពនូវផ្ទៃដីទាំងមូលនៅខាងក្រោមនេះបានទេ? អាត្មាភាពអាចនឹងប្រែក្លាយ**លុម្ពិនីវ័ន្ត**នេះ អោយទៅជាសួនឧទ្យានកម្រិតអន្តរជាតិបានណា៎។ អ្នកបើកបរយន្តហោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលបានយល់នូវគំនិតរបស់អាត្មាភាព រួចបានពោលតបវិញថា : "សូមថ្វាយបង្គំព្រះតេជគុណពួកយើងខ្ញុំ បានទទួលបញ្ជាអោយជួយសម្រួលដល់ព្រះតេជគុណ ក្នុងការស្វែងរកផ្ទៃដីមិនអោយលើសពីពីរហិកតាឡើយ"។ ការពិតគឺ អាត្មាភាពគ្រាន់តែចង់បង្ហាញឡើងនូវចំណង់នៃការចង់បាន ដោយសារការរំជួលចិត្ត ដែលពុំអាចទប់បានតែប៉ុណ្ណោះ សម្រាប់ផ្ទៃដីពីរហិកតានោះ ក៏បានធ្វើអោយអាត្មាភាពមានចិត្តរីករាយណាស់ទៅហើយ។ អាត្មាភាពបានប្រាប់ទៅអ្នកបើកបរយន្តហោះនោះ ហោះបន្ទាបចុះរួចក្រឡឹងជាច្រើនជុំនៅលើតំបន់នោះ ដើម្បីអាត្មាភាពអាចពិនិត្យមើលអោយបានកាន់តែច្បាស់លាស់។ ចុងក្រោយអាត្មាភាពបានសម្រេចចិត្ត រើសយកបល្ល័ង្កដីនៅជិតទីប្រសូតដ៏ពិសិដ្ឋនៃព្រះសម្មាសម្ពុទ្ធជាទីសក្ការៈ។ អាត្មាភាពបានគិតឃើញថា ទៅអនាគតពុទ្ធបរិស័ទដែលស្នាក់នៅវត្តនេះនឹងមានការងាយស្រួល ក្នុងការធ្វើដំណើរ

ទៅកាន់ទីប្រសូតយ៉ាងពិសិដ្ឋនៃព្រះអង្គ ដើម្បីសំដែងការគោរពបូជាចំពោះព្រះអង្គ។ បន្ទាប់មកអ្នកបើកបយន្តហោះ បានទូរស័ព្ទទៅអោយមេបញ្ជាការរបស់ខ្លួន ដើម្បីជំរាបជូនថា ប្លង់ដីនោះត្រូវបានជ្រើសរើស និងបានកត់ចំណាំនៅលើផែនទីរួចស្រេចហើយ។ គាត់ក៏បានចុះចតយន្តហោះនៅឯអាកាសយានដ្ឋាន**ហ្វាយរ៉ាហារ៉ា** នៃក្រុង**លុម្ពិនីវ័ន្ត**។ បន្ទាប់មកទៀតអាត្មាភាពបានជិះលើរថយន្តហ្ស៊ីបមួយ ដើម្បីទៅមើលដីដែលបានជ្រើសរើសរួចហើយនោះ។ ពេលមកដល់កន្លែងជាក់ស្តែង គឺអាត្មាភាពមានអារម្មណ៍អស់សង្ឃឹម និងព្រួយចិត្តដោយពុំអាចបញ្ចេញវាចាអ្វីបានទៀតឡើយ ព្រោះបានឃើញច្បាស់ថា ប្លង់ដីដែលអាត្មាភាពបានជ្រើសរើសយ៉ាងប្រយ័ត្នប្រយែងនោះ គឺជាតំបន់មួយដែលពោរពេញទៅដោយបឹងបួ និងត្រពាំងទឹក! អាត្មាភាពបានដើរទៅដើរមក ដោយបញ្ចេញនូវអាការយ៉ាងអស់សង្ឃឹម។ ពេលនេះអាត្មាភាព មានគំនិតចង់សំណូមពរអោយគេអនុញ្ញាតជ្រើសរើសយកប្លង់ដីមួយផ្សេងពីនេះ ប៉ុន្តែពុំហ៊ានឡើយ ព្រោះបាននឹកឃើញថាអ្នកបើកបរយន្តហោះនេះបានរាយការណ៍ទៅគណៈកម្មាធិការផ្តល់ដីធ្លី និងឯកសារសំខាន់ៗមួយចំនួន ប្រហែលជាត្រូវបានរៀបចំរួចស្រេចទៅហើយ។ ដោយបានឃើញទឹកមុខព្រួយបារម្ភរបស់អាត្មាភាព អ្នកបើកយន្តហោះក៏បានមកក្បែរអាត្មាភាព រួចបន្លឺថា : "ព្រះតេជគុណ បានជ្រើសរើសយកដីមួយប្លង់នេះពិតជាល្អមែន!"។ អាត្មាភាពមានការងឿងឆ្ងល់ និងចង់ដឹងអោយកាន់

តែច្បាស់ ទើបសួរបញ្ជាក់វិញថា "វាល្អយ៉ាងម្ដេចទៅ?"។ "នៅទីនេះមានទឹកច្រើន នេះគឺជាសញ្ញាប្រាប់អោយដឹងថា ព្រះវិហារវៀតណាមដែលនឹងត្រូវបានសាងសង់នៅទីនេះ ច្បាស់ជាមានឱកាសល្អប្រសើរសម្រាប់ការអភិវឌ្ឍជាពុំខាន"។

ក្រោយពីបានស្ដាប់នូវពាក្យពេចន៍ទាំងនេះ អាត្មាភាពបែរជាមានការសប្បាយចិត្តមួយរំពេច ហើយក៏បោះបង់ចោលគំនិតសុំផ្លាស់ប្ដូរទីកន្លែងដែលជាគំនិតមួយអាចនឹងជួបប្រទះនូវភាពស្មុគស្មាញជាច្រើន។

នៅពេលបានទទួលយកប្លង់ដីរួចហើយ យើងត្រូវតែចាប់ផ្ដើមសាងសង់ព្រះវិហារអោយកាន់តែឆាប់កាន់តែល្អ ដូចសំណូមពររបស់បងប្អូនញាតិញោមបានលើកឡើងថា : យើងត្រូវតែចាប់ផ្ដើមការសាងសង់ព្រះវិហារកាន់តែឆាប់កាន់តែល្អ ព្រោះតែដីដែលទុកចោលយូរដោយគ្មានការប្រើប្រាស់នោះនឹងត្រូវរដ្ឋាភិបាល**នេប៉ាល់**ដកហូតយកទៅវិញជាពុំខាន"។ ប៉ុន្តែបញ្ហាដ៏ធំបំផុត គឺបញ្ហាថវិកាបានមកពីណា? បងប្អូនបានធ្វើការអះអាងជាមួយអាត្មាភាពថា : "សូមព្រះតេជគុណកុំព្រួយ ពួកខ្ញុំព្រះករុណាសន្យា ថានឹងរកវិធីដោះស្រាយជូននៅពេលវិលត្រឡប់ទៅប្រទេសវិញ។ យើងខ្ញុំនឹងផ្ញើថវិកាជូនព្រះតេជគុណ ក្នុងរយៈពេលពីរខែទៀត"។ ដោយយល់ឃើញនូវការស្ទាក់ស្ទើររបស់អាត្មាភាព បងប្អូនបានបន្តយោបល់ទៀតថា : "សូមព្រះតេជគុណ មេត្តាត្រៀមរៀបចំពិធីបញ្ចុះសីមាសម្រាប់ការសាងសង់

ព្រះវិហារផងចុះ ហើយព្រះតេជគុណគួរអញ្ជើញតំណាងគ្រប់ស្ថានទូត និង តំណាងនៃរដ្ឋាភិបាលនៅមជ្ឈិម ដើម្បីចូលរួមនៅក្នុងពិធីនេះ។ នេះគឺជា វិធីមួយដែលប្រាប់អោយគេដឹងឮគ្រប់គ្នាថា យើងបានចាប់ផ្តើមដំណើរការ សាងសង់ជាផ្លូវការហើយណា៎!"។

អាត្មាភាពបានយល់ព្រមតាមគំនិតរបស់ពួកគេ ហើយក៏បានសំណូមពរ អោយបងប្អូនបែងចែកការងារជាមួយនឹងអាត្មាភាព : "ល្អណាស់! អាត្មាភាព នឹងធ្វើជាប្រធាននៃការរៀបចំពិធីនេះចុះ ប៉ុន្តែសូមបងប្អូនមេត្តាធ្វើលិខិត អញ្ជើញទៅអោយស្ថានទូតនានា អ្នកតំណាងរដ្ឋាភិបាលនៅមជ្ឈិម និង មូលដ្ឋាន ព្រមទាំងអ្នកតំណាងនៃអង្គការសាសនាមួយចំនួនផង បានដែរ ឬទេ?"។

នៅពេលនោះ តំបន់នេះ ត្រូវបានគ្របដណ្តប់ទៅដោយដើមឈើធំៗ និងគុម្ពោតក្រាស់ៗជាច្រើន។ បឹងត្រពាំង ក៏មានច្រើនណាស់ដែរ ម្យ៉ាងទៀត ផ្លូវថ្នល់ពុំទាន់បានក្រាលកៅស៊ូនៅឡើយ។ ធាតុអាកាសរឹតតែពុំអំណោយ ផលទាល់តែសោះ មេឃភ្លៀងជាប់រជឹកជាច្រើនថ្ងៃមកហើយ ឯពេលវេលា សម្រាប់ធ្វើពិធី ក៏បានឈានមកកាន់តែជិតណាស់ដែរ។ អាត្មាភាពមានការ ព្រួយបារម្ភដោយគិតថា បើសិនជាភ្លៀងជាប់រហូតទៅដល់ថ្ងៃរៀបចំពិធី បុកគ្រឹះនោះ គឺអាត្មាភាពច្បាស់ជាពុំអាចរៀបចំពិធីសែនព្រេនបួងសួងតាម ទំនៀមទម្លាប់បានឡើយ។ ដោយការព្រួយចិត្តខ្លាំងពេក អាត្មាភាពបានអុច

ធូបបីសរសៃរួចបួងសួងថា : "យើងខ្ញុំទាំងអស់គ្នា មានចិត្តបរិសុទ្ធចង់សាងសង់ព្រះវិហារមួយនៅលើដែនដីដ៏ពិសិដ្ឋនេះ សូមក្រាបថ្វាយបង្គំគ្រប់ព្រះអង្គព្រះពោធិសត្វ ទេវនាគព្រមទាំងទេវរាជថែរក្សាព្រះធម៌ សូមមេត្តាករុណាប្រទានធាតុអាកាសល្អប្រសើរដល់យើងខ្ញុំ ដើម្បីងាយស្រួលដល់ការរៀបចំប្រព្រឹត្តពិធីបុកគ្រឹះដោយអនុគ្រោះផង ព្រះអង្គ!"។

ជាការចម្លែកអស្ចារ្យណាស់ សេចក្តីបួងសួងរបស់អាត្មាភាព ពិតជាស័ក្តិសិទ្ធិមែន ព្រោះមេឃមានពន្លឺថ្ងៃជាប់ពីរបីថ្ងៃ នៅមុនពេលពួកយើងខ្ញុំចាប់ផ្តើមធ្វើពិធី។ ថ្ងៃរៀបចំពិធីបុកគ្រឹះក៏ជាថ្ងៃល្អដែរ ដោយសារផ្ទៃដីស្ងួតគ្មានដក់ទឹកភ្លៀងទៀតឡើយ។

អាត្មាភាពមានជំនឿយ៉ាងខ្លាំងទៅលើឥទ្ធិពលដ៏ល្អប្រសើរ ដែលបានមកពីវត្តមានរបស់អ្នកមានសីល ចូលរួមនៅក្នុងពិធីសាងសង់អ្វីមួយជាពុំខាន។ គុណបុណ្យរបស់ពួកគាត់ នឹងជួយដល់យើងយ៉ាងច្រើនមហិមា។ អាស្រ័យហេតុនេះហើយ អាត្មាភាពផ្ទាល់បានទៅអញ្ជើញព្រះតេជគុណ**អ៊ូយ៉ានេនដា** ជាព្រះសង្ឃប្រកបដោយសីលយ៉ាងឧត្តុង្គឧត្តម (លោកគឺជាលោកសង្ឃបាមោក្ខ) មកធ្វើជាអ្នកដឹកនាំពិធីបុកគ្រឹះនេះ។ លោកគឺជា ព្រះចៅអធិការវត្តភូមា និងជាប្រធានក្រុមប្រឹក្សាព្រះពុទ្ធសាសនាពិភពលោក ប្រចាំក្រុង**ពុទ្ធគយា**។ អាត្មាភាពក៏បានអញ្ជើញលោកសង្ឃល្បីៗជាច្រើនអង្គ ដែលមានសញ្ជាតិខុសៗគ្នាមកសូត្រមន្តគាថា ក្នុងពិធីបុកគ្រឹះនេះផងដែរ។ លោកគ្រូ

របស់អាត្មាភាពធ្លាប់បានប្រាប់អាត្មាភាពថា តាមទំនៀមទម្លាប់នៅពេលចាប់ផ្តើមសាងសង់សំណង់អ្វីមួយ គឺយើងត្រូវដើរប្រទក្សិណសូត្រមន្តជុំវិញសំណង់នោះពីបីដល់ប្រាំពីរដងកុំខាន។ បញ្ហាគឺទីតាំងនៃសំណង់ត្រូវបានព័ទ្ធជុំវិញដោយថ្លុកត្រពាំងទឹកបានសេចក្តីថា យើងត្រូវដើរលុយទឹកជាពុំខាន។ អាត្មាភាពបានត្រៀមខ្លួនជាស្រេច ប៉ុន្តែលោកសង្ឃផ្សេងៗទៀតគួរធ្វើយ៉ាងដូចម្តេចទៅ? អាត្មាភាពបានអង្វរសុំថា : "សូមថ្វាយបង្គំព្រះតេជគុណសូមមេត្តាជួយដល់ខ្ញុំព្រះករុណាផង សូមព្រះតេជគុណយល់ព្រមដើរលុយទឹកជុំវិញប្លង់សំណង់អោយបានគ្រប់បីដងផង"។ ប៉ុន្តែព្រះតេជគុណទាំងនោះបានបដិសេធសំណើនេះ។ លោកសង្ឃបាមោក្ខបានលើកសំណើមួយ : "អាត្មាភាពយល់ឃើញថា យើងអាចយកឫស្សីបួនដើមមកដោតនៅបួនជ្រុងនៃប្លង់ដី រួចយកខ្សែអំបោះចងព័ទ្ធតាមជ្រុងទាំងបួននោះ[១]។ បើសិនជាលោកកាន់ក្បាលអំបោះម្ខាងហើយសូត្រមន្តគាថា គឺវាបានផ្សាយទៅតាមខ្សែសីមាទាំងមូលជាពុំខាន។ លទ្ធផលនេះមិនខុសពីការដើរប្រទក្សិណជុំវិញប្លង់ដីដែរណា៎"។

ថ្វីត្បិតតែ សំណើនេះហាក់ដូចជាសមហេតុសមផលក្តី អាត្មាភាពនៅតែមានការខ្វល់ខ្វាយ ព្រោះបារម្ភក្រែងលោមានសត្វស្លាបណាមួយហោះឆ្លងកាត់បណ្តាលអោយដាច់ខ្សែសីមា។ បើដូចនេះមែន វាគឺជានិមិត្តអាក្រក់

[១] ពិធីព័ទ្ធសីមា។

ជាពុំខាន។ ហេតុនេះ បានជាអាត្មាភាពខិតខំអង្វរជាថ្មីម្តងទៀត។ ចុងក្រោយ ព្រះតេជគុណបានបញ្ចប់បញ្ហា ដោយបញ្ចេញសង្ឃដីកាថា : "សូមព្រះតេជគុណមេត្តាអភ័យទោសផង ព្រះតេជគុណស្លៀកខោ[១] ជាការងាយស្រួលទេណា៎ ប៉ុន្តែពួកអាត្មាភាព គឺគ្រងស្បង់ចីវរធ្វើម្តេចនឹងដើរលុយទឹកទៅកើត?"។

ពេលនេះអាត្មាភាពត្រូវតែបង្ខំចិត្ត ធ្វើតាមសំណើរបស់លោក។ យើងទាំងអស់គ្នាបានគង់នៅលើថ្នល់សូត្រមន្ត ពុំអាចដើរប្រទក្សិណដូចបំណងឡើយ។ អាត្មាភាពមានចិត្តខ្វល់ខ្វាយ តែពុំអាចធ្វើអ្វីផ្សេងក្រៅពីនេះបានឡើយ។ ប៉ុន្តែនៅពេលអាត្មាភាព បានសូត្រមន្តបញ្ចប់មួយវគ្គ ស្រាប់តែភាពអស្ចារ្យមួយបានកើតមានឡើង គឺមានអ្នកស្រុកនេប៉ាល់ម្នាក់បានជិះដំរីសន្សឹម១មកពីទិសខាងត្បូង តម្រង់មករកកន្លែងប្រារព្ធពិធី។ អាត្មាភាពបានក្រោកឡើងក្នុងមួយរំពេច រួចសួរទៅហ្មដំរីថា : អ្នកធ្វើដំណើរទៅណា? គាត់ជំរាបជូនថា : គាត់បរដំរីចូលធ្វើការក្នុងព្រៃ ហើយក៏បានឃើញមនុស្សម្នាជាច្រើននៅទីនេះ ក៏តម្រង់មកមើលមួយភ្លែត។ អាត្មាភាពបានសួរបន្តទៀតថា តើអ្នកអាចអោយពួកអាត្មាភាព ឡើងជិះដំរីបរជុំវិញផ្ទៃដីនេះពីរបីជុំបានដែរឬទេ? គាត់ក៏សប្បាយចិត្ត យល់ព្រមតាមសំណើរបស់អាត្មាភាព។

បន្ទាប់មកប្រធានដឹកនាំពិធីបុណ្យ បានឡើងគង់នៅលើខ្នងដំរីយ៉ាងសង្ហា។ សត្វដំរី ក៏បានបរទៅយ៉ាងស្វាហាប់ក្នុងសំឡេងសូត្រមន្តសាចុះសា

---

[១] លោកសង្ឃខាងមហាយាន គឺស្លៀកខោ។

ឡើងពុំដាច់ឡើយ។ អាត្មាភាពមានការរំភើបចិត្តយ៉ាងខ្លាំង ចំពោះបរិយាកាសនេះ។ ការដែលញ៉ាំងអោយអាត្មាភាព មានការភ្ញាក់ផ្អើលបំផុត គឺបងប្អូនជនជាតិនេប៉ាល់មួយចំនួន ដែលចូលរួមនៅក្នុងពិធីបុណ្យនេះ ស្រាប់តែបញ្ចេញសំឡេងយំខ្សឹបខ្សួល អាត្មាភាពមានការងឿងឆ្ងល់យ៉ាងខ្លាំង ដោយគិតថា : អាត្មាភាពកំពុងមានចិត្តរីករាយក្រៃលែង ហេតុអ្វីពួកគេបែរទៅជាស្រក់ទឹកភ្នែកបែបនេះ។ ក្រោយមកទើបអាត្មាភាពបានដឹងថា ប្រជាជននៅតំបន់នេះមានជំនឿថា ហេតុការណ៍ដែលកើតមានឡើងនោះ គឺជាភាពពិសិដ្ឋអស្ចារ្យមួយ។ ពួកគេបានជំរាបថា "ព្រះតេជគុណ វត្តមានរបស់សត្វដំរីនៅក្នុងពិធីបុណ្យនេះ គឺជានិមិត្តមួយយ៉ាងល្អប្រសើរ។ កាលពីមុនព្រះមហាក្សត្រយានី **ព្រះនាងមាយាទេវី** បានយល់សុបិន្តឃើញសត្វដំរីមួយហើយពុំយូរប៉ុន្មានឡើយ គឺព្រះនាងទ្រង់មានព្រះគភ៌ រួចបានប្រសូត**ព្រះរាជបុត្រាសិទ្ធត្ថ**។

ពេលនេះ សត្វដំរីបានមកដល់ក្នុងពេលកំពុងប្រារព្ធពិធីហេតុការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចការសាងសង់របស់ព្រះតេជគុណនឹងទទួលបានជោគជ័យយ៉ាងពេញលេញ ជាពុំខានឡើយ"។

ពាក្យពេចន៍ទាំងនេះ បានបណ្តាលអោយអាត្មាភាពមានការសប្បាយចិត្តពិតមែន។ ក្រោយពេលលោកសង្ឃបានបញ្ចប់នូវការសូត្រមន្តរួចហើយ ហ្មដំរីក៏បានមកអង្វរសុំអោយអាត្មាភាព ឡើងគង់លើខ្នងដំរីជាមួយនឹងគាត់

ជាថ្មីម្តងទៀត។ អាត្មាភាពពុំអាចបដិសេធបាន នូវសំណើរបស់គាត់បាន ឡើយ។ សត្វដំរីបានដើរឆ្ពោះទៅទិសត្បូង បន្សល់ទុកពីខាងក្រោយនូវ ទេសភាព**ភ្នំហិមពាន្ត** គ្របដណ្តប់ដោយព្រិលសចែងចាំង បង្ហាញនូវ សម្រស់ធម្មជាតិយ៉ាងល្អប្រណីត ក្រោមពន្លឺព្រះសូរិយានាពេលព្រឹកព្រលឹម។ អាត្មាភាពបានគយគន់សំឡឹងមើលសម្រស់ធម្មជាតិដ៏អស្ចារ្យ ដោយក្តីរំភើប ចិត្តយ៉ាងជ្រាលជ្រៅ ចំពោះហេតុការណ៍ដ៏ពិសិដ្ឋអស្ចារ្យដែលកើតមានឡើង ទាំងអម្បាលម៉ាន។ បេះដូងរបស់អាត្មាភាព ពោរពេញទៅដោយក្តីសប្បាយ រីករាយឥតឧបមាឡើយ។

នៅពេលគង់នៅលើខ្នងដំរី អាត្មាភាពបាន សូត្រនូវព្រះសូត្រ សមន្តមុគ្គហៈ[១] និងព្រះបរិត្ត។ ការចម្លែកមួយ គឺហ្មដំរីបានដឹកអាត្មាភាព ទៅជុំវិញប្លង់ដី សម្រាប់ការកសាងព្រះវិហារវៀតណាម មិនមែនតែមួយជុំ ប៉ុណ្ណោះទេ គឺឡើងដល់ទៅបីជុំឯណោះ។ អ្វីដែលកាន់តែចម្លែកជាងនេះ ទៅទៀត គឺហ្មដំរីមិនព្រមឈប់ ក្រោយពេលបរដំរីជុំវិញផ្ទៃដីបានបីជុំរួច ហើយនោះទេ គាត់បែរជាតម្រង់ឆ្ពោះទៅរកសសរសិលារបស់**ស្តេចអសោក** តែម្តង។ អាត្មាភាពមានការរំភើបចិត្តយ៉ាងក្រៃលែង ចំពោះហេតុការណ៍ ទាំងពួងដែលបានកើតមានឡើងផ្ទួនៗគ្នា នាំអោយអាត្មាភាពឈានដល់ការ សម្រេចចិត្តមួយយ៉ាងអង់អាច គឺនៅពេលអាត្មាភាពបានមកដល់ទីកន្លែងប្រសូត

[១] គឺជាវគ្គមួយនៅក្នុងព្រះគម្ពីរបុញ្ញរិកៈនៃពុទ្ធសាសនាមហាយាន។

នៃព្រះអង្គ អាត្មាភាពបានក្រាបថ្វាយបង្គំ និងបួងសួងដូចតទៅ ៖
"សូមក្រាបថ្វាយបង្គំព្រះអង្គជាទីសក្ការៈ ខ្ញុំព្រះករុណាបានប្រទះឃើញនូវហេតុការណ៍ទាំងឡាយយ៉ាងអស្ចារ្យ ហេតុនេះខ្ញុំព្រះករុណាសូមសច្ចាស្នាក់នៅទីនេះ ដើម្បីការសាងសង់ព្រះវិហារវៀតណាម ជាព្រះវិហារអន្តរជាតិដំបូងបង្អស់ ដែលស្ថិតនៅទីកន្លែងប្រសូតនៃព្រះអង្គ" ។

ដើម្បីសំដែងនូវការដឹងគុណចំពោះហ្មជីវី អាត្មាភាពបានផ្តល់ប្រាក់ជូនគាត់ចំនួន៥០០រូពី (ប្រហាក់ប្រហែលនឹង១០ដុល្លារអាមេរិចកាំង) ជាចំនួនប្រាក់មិនតិចឡើយ បើប្រៀបទៅនឹងថ្លៃពលកម្មប្រចាំថ្ងៃសម្រាប់អ្នកស្រុកនៅទីនេះ ប៉ុន្តែគាត់បានបដិសេធមិនទទួលយកលុយនេះ។ អំពើនេះ រឹតតែនាំអោយអាត្មាភាព មានជំនឿលើភាពពិសិដ្ឋអស្ចារ្យថែមទៀត។

បន្ទាប់មក អាត្មាភាពបានវិលត្រឡប់មកកន្លែងប្រារព្ធពិធីបុណ្យ មនុស្សម្នាកំពុងពិសាអាហារថ្ងៃត្រង់ រីឯអាត្មាភាពពុំមានអារម្មណ៍ចង់ឆាន់ចង្ហាន់ឡើយ ព្រោះចិត្តពោរពេញទៅដោយការសប្បាយរំភើបឥតឧបមា ។ នៅពេលបងប្អូនញាតិញោមបានបញ្ចប់អាហារថ្ងៃត្រង់ ហើយត្រៀមនឹងចាកចេញនោះ អាត្មាភាពបានក្រោកឈរឡើង ព្រមទាំងបានប្រកាសយ៉ាងឱឡារិកថា ៖ "អាត្មាភាពបានសម្រេចចិត្តស្នាក់នៅទីនេះ" ។ នេះគឺជាសេចក្តីប្រកាសមួយដែលពួកគេពុំអាចជឿបាន ។ ក្រោយពេលបានស្តាប់អាត្មាភាពពោលរួច លោកសង្ឃទាំងអស់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយសារពួក

លោកមានការព្រួយបារម្ភអំពី ភាពឯកោស្នាក់នៅតែម្នាក់ឯងរបស់អាត្មាភាព ហើយភាពប្រឈមមុខនឹងការលំបាក ព្រមទាំងបញ្ហានានា ដែលអាចកើតមានឡើងក្នុងស្ថានភាពស្ងប់ស្ងាត់ពោរពេញ ដោយគ្រោះថ្នាក់បែបនេះជាពុំខាន។

អាត្មាភាព បានបញ្ជាក់អះអាង ជាមួយពួកលោកជាថ្មីម្តងទៀតថា : "សូមអស់លោក កុំមានការព្រួយបារម្ភដល់អាត្មាភាព។ អាត្មាភាពនឹងរៀបចំដំឡើងតង់មួយជាជម្រកនៅទីនេះ"។

**ព្រះសង្ឃបាមោក្ខ** (Superior Monk) បានមានសង្ឃដីកាមុនគេបង្អស់ : "លោកប្តេជ្ញាចិត្តស្នាក់នៅទីនេះ ប៉ុន្តែលោកមានដឹងច្បាស់ថា ខ្លួនលោកបានភ្ជាប់ប្រាក់មកជាមួយប៉ុន្មានដែរឬទេ?"។

អាត្មាភាពបានពិនិត្យមើលក្នុងថង់យាមយ៉ាងសព្វគ្រប់ រួចរកឃើញប្រាក់នៅសល់ត្រឹម ៦០ដុល្លារអាមេរិក មនុស្សម្នាបានយល់ឃើញថា ចំនួនប្រាក់បន្តិចបន្តួចនេះ សម្រាប់ការស្នាក់នៅទីកន្លែង ដូចវាលរហោឋាននេះពិតជាការមិនគប្បីប្រព្រឹត្តទៅកើតឡើយ។ អាស្រ័យហេតុនេះហើយ ពួកគាត់ខិតខំបញ្ចុះបញ្ចូល និងលួងលោមអាត្មាភាពអស់រយៈពេលប្រមាណពីរម៉ោង អោយបំភ្លេចចោលនូវគំនិតស្នាក់នៅទីនេះម្នាក់ឯង ហើយចូលរួមដំណើរជាមួយពួកគេ វិលត្រឡប់ទៅកាន់**ពុទ្ធគយា**វិញ។ អ្នកខ្លះបានសន្យាជាមួយអាត្មាភាពថា គេនឹងវិលមកកាន់ទីនេះ ជាមួយអាត្មាភាពរយៈពេល

ពីរបីខែក្រោយមក ដើម្បីជួយអាត្មាភាពក្នុងការសាងសង់ព្រះវិហារ បើសិនជាអាត្មាភាព បានយល់ព្រមធ្វើដំណើរចាកចេញពីទីនេះជាមួយពួកគេ។ ពួកគាត់បានពោលថា ពួកគាត់នឹងត្រៀមរៀបចំយ៉ាងសព្វគ្រប់សម្រាប់ការសាងសង់នាពេលនោះ។ ទោះបីយ៉ាងណាក៏ដោយ អាត្មាភាពបានបដិសេធដោយពុំមានការផ្លាស់ប្តូរគំនិតរបស់ខ្លួនឡើយ។

អាត្មាភាពមានការជឿជាក់ទៅលើភាពពិសិដ្ឋ ដែលនឹងកើតមានឡើង ហេតុនេះហើយក៏បានប្តេជ្ញាចិត្តស្នាក់នៅទីនេះ និងពុំអាចធ្វើអ្វីផ្សេងក្រៅពីការសម្រេចចិត្តនេះឡើយ។ ពួកលោកទាំងអស់ មានការអស់សង្ឃឹមយ៉ាងខ្លាំងចំពោះការសម្រេចចិត្តប្រកបដោយក្តីផ្សងព្រេងរបស់អាត្មាភាព។ ប្រហែលជាមកពីការព្រួយបារម្ភ និងអាណិតអាសូរយ៉ាងខ្លាំងចំពោះអាត្មាភាព បានជាពួកលោកចូលរួមគ្នាសូត្រនូវមហាមង្គលសុត្ត ដើម្បីជូនពរជាផលសម្រេចដល់បំណងប្រាថ្នារបស់អាត្មាភាព។ ព្រះតេជគុណ **អ៊ូប៉ាវ៉ាភា** ព្រះតេជគុណ **ណាន់ដា** និងលោក **អ៊ូធន់តាភា** បានរំឭកដល់អាត្មាភាពយ៉ាងហ្មត់ចត់ថា អាត្មាភាពត្រូវតែមានការប្រយ័ត្នប្រយែងមែនទែន ព្រោះនៅទីនេះមានសត្វពស់មានពិសជាច្រើន។ ពួកលោកក៏បានប្រាប់រំឭកអំពី សត្វសាហាវដែលម្តងម្កាលចេញមកពីដងព្រៃនៅជុំវិញនេះ ដើម្បីស្វែងរកចំណីអាហារ។ អាត្មាភាពពិតជាមានការរំភើបចិត្ត ព្រមទាំងដឹងគុណចំពោះសណ្តានចិត្ត និងការស្រលាញ់រាប់អានរបស់ពួកលោកមកលើអាត្មាភាព។

ទោះបីជាយ៉ាងណាក៏ដោយ គ្មានអ្នកណាមួយ ដែលអាចដឹងថា អាត្មាភាពមានទ្រព្យសម្បត្តិ ប្រកបដោយតម្លៃដែលពុំអាចកាត់ថ្លៃបាន នោះគឺបំណងប្រាថ្នាយ៉ាងមោះមុត ការប្តេជ្ញាចិត្ត និងជំនឿដាច់ខាតទៅលើភាពពិសិដ្ឋអស្ចារ្យ ដែលនឹងកើតមានឡើងជាពុំខាន។ សេចក្តីទាំងអម្បាលនេះបានជួយដល់អាត្មាភាព ឆ្លងផុតពីកង្វល់អំពីការខ្វះខាតនូវរបស់របរជាចាំបាច់ព្រមទាំងប្រាក់កាសផងដែរ។ ដោយហេតុនេះហើយ បានជាអាត្មាភាពមានអារម្មណ៍ធូរស្រាល គ្មានចិត្តខ្វល់ខ្វាយបន្តិចណាសោះអំពីគ្រោះថ្នាក់ ឬឧបសគ្គជាច្រើន ដែលកំពុងរង់ចាំអាត្មាភាពនៅពេលខាងមុខនោះឡើយ។ បំណងប្រាថ្នារបស់អាត្មាភាពនាពេលនេះ គឺមិនស្ថិតនៅត្រឹមការសាងសង់ព្រះវិហារវៀតណាមមួយនៅលើនគរព្រះតែប៉ុណ្ណោះទេ គឺថែមទាំងចង់ពង្រីកកិច្ចការបម្រើដល់ព្រះពុទ្ធសាសនា អោយកាន់តែបានទូលំទូលាយថែមទៀត។ ការនេះប្រៀបដូចនឹងសូរសំឡេងស្របគ្នា បានអោយស្នូរកាន់តែលាន់ឮដល់ត្រចៀកមនុស្សម្នាគ្រប់ៗគ្នា ជាក់ស្តែងគឺសាស្ត្រាចារ្យ **អាសាវ៉ាមសក្យ** បានពោលនៅក្នុងសេចក្តីថ្លែងការណ៍ ក្នុងពិធីបុកគ្រឹះដូចតទៅ :

"ដោយបានឆ្លងកាត់រាល់ឧបសគ្គ និងការលំបាកទាំងឡាយក្នុងកិច្ចការសាងសង់ព្រះវិហារអន្តរជាតិជាលើកដំបូងបង្អស់ នៅលើដែនដីពិសិដ្ឋជាទីចាប់បដិសន្ធិនៃព្រះសម្មាសម្ពុទ្ធនៃយើង គឺព្រះវិហារវៀតណាមនេះហើយ ដែលបានបើកឡើងនូវ ទំព័រមាសក្នុងប្រវត្តិសាស្ត្រ នៃព្រះពុទ្ធសាសនា

ពិភពលោក។ នេះគឺជាមោទនភាពនៃយើងទាំងអស់គ្នា។ យើងខ្ញុំសូមអំពាវនាវសហព័ន្ធពុទ្ធសាសនា**នេប៉ាល់** ព្រមទាំងប្រទេសដទៃទៀតលើពិភពលោក សូមអោយយកតាមគំរូនៃព្រះវិហារវៀតណាម ដើម្បីរួបរួមគ្នាក្នុងបុព្វហេតុការពារ និងអភិវឌ្ឍន៍**លុម្ពិនីវ័ន្ត**”។

ឆឆឆ៚៚៚

# ការស្ថាបនាតំបន់សហព័ន្ធព្រះវិហារអន្តរជាតិ

ការស្ថាបនាព្រះវិហារវៀតណាមនៅឯ**លុម្ពិនីវ័ន្ត** បាននាំអោយអាត្មាភាពមានការលំបាកឥតគណនា ទាំងខាងផ្លូវកាយ និងផ្លូវចិត្ត។

ថ្វីត្បិតតែ អាត្មាភាពជាអ្នកឈានមុខគេ ក្នុងការស្ថាបនាសាងសង់ក៏ដោយព្រះវិហារវៀតណាមនេះ ត្រូវការរយៈពេលជាងដប់ឆ្នាំ ទើបអាចបញ្ចប់ការស្ថាបនាយ៉ាងពេញលេញបាន ដោយការចំណាយថវិកាពីការបង្ហាត់បង្រៀនរបស់អាត្មាភាព ព្រមទាំងថវិកាជាបច្ច័យរបស់ពុទ្ធបរិស័ទលើពិភពលោក។ ក្នុងពេលនោះការសាងសង់ព្រះវិហារផ្សេងៗ ត្រូវបានប្រព្រឹត្តឡើងក្នុងរយៈពេលយ៉ាងខ្លីតែប៉ុណ្ណោះ ដោយសារមានការឧបត្ថម្ភគាំទ្រខាងថវិកាពីរដ្ឋាភិបាលនៃប្រទេសរបស់គេ។ ទោះបីជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាបញ្ហាពេលវេលាប៉ុណ្ណោះ អាត្មាភាពនៅតែមានជំនឿទៅលើការសាងសង់ព្រះវិហាររបស់ខ្លួនថា វាពិតជាត្រូវបានបញ្ចប់ ដោយភាពពិសិដ្ឋអស្ចារ្យជាពុំខាន។

នៅគ្រាដំបូង ក្រៅពីការគិតដល់ភាពលំបាកខាងថវិកា នៅមានបញ្ហាធំមួយផ្សេងទៀត នោះគឺទោះបីអាត្មាភាពមានលុយគ្រប់គ្រាន់ សម្រាប់សាងសង់ព្រះវិហារមួយយ៉ាងស្កឹមស្កៃយ៉ាងណាក៏ដោយ អ្នកស្រុកដែលប្រកបដោយ

គំនិតជ្រុលនិយម មានបំណងមិនល្អនោះ នឹងបង្កឧបសគ្គគ្រប់បែបយ៉ាង ដើម្បីញាំងអោយអាត្មាភាពទ្រាំទ្រអត់ធ្មត់ពុំបានរួចចាកចេញពីទីនេះតែម្តង។

ការនឹកឃើញនូវបញ្ហានេះ បណ្តាលអោយអាត្មាភាពមានចិត្តខ្វល់ខ្វាយ មិនធូរស្រាលសោះឡើយ។ អាត្មាភាពបានប្រតិបត្តិខ្លួនយ៉ាងភ្ជាប់ខ្ជួនជាប្រចាំ នូវការសូត្រមន្ត សូត្រព្រះបរិត្តគាថា សូត្រព្រះពុទ្ធនាម ព្រមទាំងចម្រើនសមាធិប្រកបដោយសេចក្តីសង្ឃឹមថា នឹងរកឃើញនូវដំណោះស្រាយតែមួយគត់សម្រាប់ការការពារ និងអភិវឌ្ឍន៍**លុម្ពិនីវ័ន្ត**អោយបានជោគជ័យ។ ម្ល៉ោះហើយនៅទីបញ្ចប់ អាត្មាភាពក៏បានរកឃើញដំណោះស្រាយនេះ។

រហូតដល់ថ្ងៃនេះ អាត្មាភាពនៅចងចាំយ៉ាងច្បាស់ថា នោះគឺជារាត្រីព្រះចន្ទពេញបូណ៌មី នាខែតុលា ឆ្នាំ១៩៩៣។ ក្រោយពេលសូត្រមន្តព្រះបរិត្តគាថា ព្រះពុទ្ធនាមព្រមទាំងចម្រើនសមាធិរួចហើយ ស្រាប់តែអាត្មាភាពបានរកឃើញនូវគំនិតមួយ គឺយើងត្រូវការកសាងតំបន់អន្តរជាតិមួយសម្រាប់សហព័ន្ធព្រះវិហារនៃពុទ្ធសាសនានៅលើដែនដីនេះ។ ការនេះទាមទារអោយអាត្មាភាព ត្រូវតែធ្វើការបញ្ចុះបញ្ចូលប្រទេសនីមួយៗកសាងព្រះវិហាររបស់ខ្លួននៅលើដែនដីនេះ ការសាងសង់ព្រះវិហារផ្ទាល់ខ្លួនរបស់គេនោះ មានសារៈសំខាន់ក្រៃលែងសម្រាប់ប្រទេសជាតិរបស់គេ ម្យ៉ាងទៀត ទីកន្លែងជាទីសក្ការៈនេះ នឹងត្រូវបានការពារយ៉ាងល្អប្រសើរជាពុំខាន។ ជាការងាយស្រួលណាស់ ប្រសិនបើសំណង់មួយបានទទួលថវិកាសាងសង់ពីប្រទេស

របស់គេផ្ទាល់ គឺប្រាកដជាវាត្រូវបានសម្រេចយ៉ាងឆាប់រហ័ស ហើយព្រះវិហារនោះ ក៏ត្រូវបានថែទាំយ៉ាងល្អប្រសើរដែរ។

ដោយសារវត្តមាន នៃព្រះវិហាររបស់ខ្លួននៅ**លុម្ពិនីវ័ន្ត** ប្រទេសនីមួយៗ ព្រមទាំងប្រជាជនរបស់គេច្បាស់ជា មានការយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅដល់តំបន់ដ៏ពិសិដ្ឋនេះជាពុំខាន។

អាស្រ័យហេតុនេះហើយ អាត្មាភាពបានចាប់ផ្ដើមបង្កើតជាបន្ទាន់នូវ "គណៈកម្មាធិការអ្នកនាំសារអន្តរជាតិ" ក្នុងនោះរួមមាន សមាជិកដែលបានជ្រើសរើសពីអង្គការអន្តរជាតិនានា សម្រាប់ដឹកនាំយុទ្ធនាការនៅតាមប្រទេសជាច្រើន។ ពួកគេទាំងអស់មានប្រាថ្នាដូចគ្នា អំពីការអភិវឌ្ឍ**លុម្ពិនីវ័ន្ត**។ ដោយឡែក អាត្មាភាពបានខិតខំទំនាក់ទំនងអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីបញ្ចុះបញ្ចូលរដ្ឋាភិបាល និងអង្គការពុទ្ធសាសនានានាលើពិភពលោក អោយគេបានចូលរួមប្រាស្រ័យនៅក្នុងគម្រោងកម្មវិធីនេះ។

បន្ទាប់ពីការខិតខំប្រឹងប្រែង សម្រេចគោលដៅដោយឥតនឿយហត់អស់រយៈពេលជាច្រើនឆ្នាំកន្លងមក គឺមកទល់នឹងពេលនេះយើងបានទទួលនូវលទ្ធផលហួសពីការស្មាន សរុបគឺមានគម្រោងសាងសង់ព្រះវិហារចំនួន១៩ និងមូលដ្ឋានវប្បធម៌របស់ប្រទេសនានា ដែលត្រូវបានដំណើរការស្ថាបនានៅ**លុម្ពិនីវ័ន្ត**។

ជប៉ុនបានស្ថាបនារួចជាស្រេចនូវចេតិយសន្តិភាពដ៏មហិមា ហើយ

បច្ចុប្បន្នកំពុងដំណើរការនូវបណ្ណាល័យមួយ ព្រមទាំងសារមន្ទីរប្រកបដោយកម្រិតអន្តរជាតិ។ រដ្ឋាភិបាល និងប្រជាជនភូមាបានស្ថាបនារួចនូវសំណង់ចេតិយមួយយ៉ាងធំ ព្រមទាំងព្រះវិហារ ដែលមានទំហំធំបង្គួរផងដែរ។ រាជវង្សថៃ ព្រមទាំងរាជរដ្ឋាភិបាល និងប្រជាជនថៃកំពុងដំណើរការសាងសង់ព្រះវិហារមួយយ៉ាងស្កឹមស្កៃ។ រដ្ឋាភិបាលចិន និងសមាគមពុទ្ធសាសនាចិន បានបញ្ចប់យ៉ាងឆាប់រហ័ស នូវសំណង់ព្រះវិហារមួយយ៉ាងល្អប្រណីតតាមបែបបទនៃ**ព្រះវិហារសាវលិញ** ដោយមានទីតាំងនៅជាប់នឹងព្រះវិហារវៀតណាម។ រដ្ឋាភិបាល និងប្រជាជន**សេរីលង្កា**កំពុងសាងសង់ព្រះវិហារមួយយ៉ាងធំ រីឯប្រទេសកូរ៉េវិញ គឺគេមានគម្រោងកម្មវិធីប្រកបដោយទ្រង់ទ្រាយធំ នោះគឺការសាងសង់ព្រះវិហារមួយយ៉ាងធំមហិមា មានសាលធំមួយ ដែលអាចផ្ទុកមនុស្សចំនួនប្រមាណបួនពាន់នាក់។

សមាគមពុទ្ធសាសនានៃប្រទេស**អាល្លឺម៉ង់ បារាំង**។ល។ កំពុងតែខិតខំសាងសង់ព្រះវិហាររបស់ខ្លួនដែរ។ នៅពេលថ្មីៗនេះ **ប្រធានាធិបតី ម៉ុងហ្គោល** និង**ព្រះរាជិនីប្រទេសប៊ូតង់** បានយាងមកកាន់ប្រទេស**នេប៉ាល់**ហើយបានស្នើសុំប្លង់ដី នៅក្បែរព្រះវិហារវៀតណាម ដើម្បីសម្រាប់ការសាងសង់ព្រះវិហាររបស់ប្រទេសខ្លួន។

អាត្មាភាពក៏មានបំណងមួយ គឺនៅពេលអនាគតខាងមុខនេះ អាត្មាភាពនឹងខិតខំបញ្ចុះបញ្ចូល**សហរដ្ឋអាមេរិក** និងប្រទេស**រុស្សី** សូមអោយគេ

កសាងព្រះវិហាររបស់ខ្លួននៅលើដែនដី**លុម្ពិនីវ័ន្ត**នេះ។ យើងគួរតេជរុញឧបត្ថម្ភគាំទ្រដល់បណ្តាប្រទេសមហាអំណាច ដែលធ្លាប់បានផ្តល់មធ្យោបាយយោធាដល់សង្គ្រាមវៀតណាមកាលពីមុន អោយគេចូលរួមកសាងព្រះវិហាររបស់គេនៅលើដែនដីដ៏ពិសិដ្ឋនេះ។

អាត្មាភាពបាននឹកឃើញ នៅពេលប្រារព្ធពិធីបុកគ្រឹះ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣ ( គឺថ្ងៃទី៨ ខែសីហា ឆ្នាំរការ-គិតតាមចន្ទគតិ ) ដើម្បីការចាប់ផ្តើមសាងសង់ព្រះវិហារអន្តរជាតិ ជាលើកដំបូងបង្អស់នៅក្នុង**លុម្ពិនីវ័ន្ត** គឺពេលនោះហើយ តំបន់នេះពោរពេញទៅដោយត្រពាំង បឹងបួ ពុំទាន់មានផ្លូវគមនាគមន៍សមស្រប ថែមទាំងខ្វះខាតមធ្យោបាយ សម្រាប់ការរស់នៅតាមសម័យបច្ចុប្បន្ន ដូចជាទឹក និងភ្លើងអគ្គិសនីផងដែរ។

រយៈពេលដប់ឆ្នាំកន្លងទៅ គឺជារយៈពេលដែលពោរពេញទៅដោយបញ្ហាជាច្រើនឥតគណនា ទាមទារនូវការប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តជាពិសេស គឺបញ្ហាលំបាកក្នុងការធ្វើដំណើរទៅកាន់ប្រទេសនានា ដើម្បីគេយល់ព្រមចូលរួម នៅក្នុងចលនាកសាងព្រះវិហាររៀងៗខ្លួន។ ឥឡូវនេះពេលក្រឡេកមើលសមិទ្ធផល ទាំងឡាយដែលត្រូវបានសម្រេចហើយនោះ អាត្មាភាពមានសេចក្តីត្រេកអរជាអតិបរមា។ បច្ចុប្បន្ននេះ**លុម្ពិនីវ័ន្ត** មានភាពងាយស្រួលមួយចំនួន គឺត្រូវបានបំពាក់ដោយបណ្តាញភ្លើងអគ្គិសនី ទឹកម៉ាស៊ីន ខ្សែទូរស័ព្ទក្នុងនិងក្រៅប្រទេស ថែមទាំងមានទូរស័ព្ទដៃ និង

អ៊ីនធីណិតទៀតផង។ ប្រព័ន្ធផ្លូវគមនាគមន៍ ក៏បានលាតសន្ធឹងទៅកាន់ព្រះវិហារ ដែលមានទីតាំងឆ្ងាយៗពីគ្នានៅក្នុងតំបន់ផងដែរ។ គម្រោងសាងសង់ព្រះវិហាររបស់ប្រទេសផ្សេងៗ ក៏បាននាំមកនូវការងារចំនួនរាប់ពាន់សម្រាប់កម្មកបរទេស និងកម្មករក្នុងស្រុក ម្យ៉ាងទៀតសេវាកម្មដែលមានការពាក់ព័ន្ធនោះ ក៏មានសន្ទុះខ្លាំងក្លា នាំមកនូវភាពអ៊ូអរសម្បូរសប្បាយសម្រាប់តំបន់នៅជុំវិញផងដែរ។

នេះគឺជាភាពអស្ចារ្យយ៉ាងពិតប្រាកដ ដែលបានញ៉ាំងអោយព្រះរាជា **ប៊ីរ៉េង់ជ្រា** នៅពេលព្រះអង្គគង់ព្រះជន្មនៅឡើយនោះ មានការភ្ញាក់ព្រះទ័យព្រមទាំងនាយករដ្ឋមន្ត្រីជាច្រើនជំនាន់ ក៏ធ្លាប់មានការភ្ញាក់ផ្អើល នៅពេលពួកគាត់បានយាងអញ្ជើញមក មើលឃើញដោយផ្ទាល់នូវការវិវឌ្ឍរីកចម្រើនយ៉ាងអស្ចារ្យនៃ**លុម្ពិនីវ័ន្ត**។ នេះពិតជាមោទនភាព ព្រមទាំងជាកុសលផលបុណ្យរបស់ប្រជាជាតិយើង ដែលជាលើកដំបូងក្នុងប្រវត្តិសាស្ត្រជនជាតិវៀតណាម បានរួមចំណែកក្នុងការបង្កើតសហព័ន្ធព្រះវិហារនៃពុទ្ធសាសនាអន្តរជាតិនៅលើតំបន់ពិសិដ្ឋមួយ ដែលពិភពលោកបានទទួលស្គាល់ថាជាបេតិកភណ្ឌវប្បធម៌ពិភពលោក។

ហេតុនេះហើយក្នុងចំណោមទីតាំងជាទីសក្ការៈទាំងបួនរបស់ពុទ្ធសាសនាព្រះវិហារវៀតណាមបានមានវត្តមាននៅពីរកន្លែង គឺនៅ**ពុទ្ធគយា**នៃប្រទេស**ឥណ្ឌា** និង**លុម្ពិនីវ័ន្ត** នៃព្រះរាជាណាចក្រ**នេប៉ាល់**។

# ទីណាសុខសាន្ត បក្សាបក្សីមកស្នាក់អាស្រ័យ

ពេលស្នាក់នៅដំបូងនៅ**លុម្ពិនីវ័ន្ត** អាត្មាភាពមានការចាប់អារម្មណ៍នៅទីនេះ ពុំមានសត្វបក្សាបក្សីច្រើនឡើយ។ ពេលព្រឹកព្រលឹមនាឆ្នាំទីពីរ អាត្មាភាព កំពុងបោះជំហានចេញពីជម្រកបណ្តោះអាសន្ន ក៏ស្រាប់តែមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយប្រទះឃើញនូវសត្វមួយគូ ដែលមានកម្ពស់ចម្លែកឈរចំពោះមុខអាត្មាភាព។ អាត្មាភាពមានកម្ពស់១.៦៨ម៉ែត្រ តែសត្វស្លាបទាំងគូនេះ បែរជាខ្ពស់ជាងអាត្មាភាពទៅទៀត!។

អាត្មាភាពមានការភិតភ័យមែនពិត នៅពេលជួបប្រទះសត្វស្លាបទាំងនេះដោយងឿងឆ្ងល់ក្នុងចិត្តថា សត្វនេះប្រហែលជាពួកខ្មោចបិសាចប្រែរូបមកលងបន្លាចអាត្មាភាពហើយមើលទៅ! គិតដូចនេះរួច អាត្មាភាពក៏រត់បកចូលទៅក្នុងតង់យ៉ាងលឿនស្លេវ ហើយឆក់យកដំបងឈើមួយដើមសម្រាប់ការពារខ្លួន នៅពេលណាដែលពួកសត្វនេះ ចាប់ផ្តើមវាយលុកអាត្មាភាព។ នៅពេលដឹងច្បាស់ថា អាត្មាភាពប្រាកដជាមានសុវត្ថិភាពពិតមែន ទើបអាត្មាភាពអើតមើលចេញទៅក្រៅ។ អាត្មាភាពធ្លាប់ធ្វើដំណើរគោចរទៅដល់កន្លែងជាច្រើនលើលោកនេះ និងបានអានសៀវភៅជាច្រើន ព្រមទាំងបានជួបសត្វបក្សាបក្សីស្អាតៗកម្ររកបាន ប៉ុន្តែអាត្មាភាពពុំដែលបានជួបប្រទះប្រភេទសត្វស្លាបណាមួយ ដែលមានរូបរាងខ្ពស់ស្រឡះយ៉ាងស្អាតប្រណីត

ដូចសត្វមួយគូនេះឡើយ។ អាត្មាភាព ក៏ស្រមៃឃើញនូវរឿងនិទានអំពីសត្វឥន្ទ្រីយក្សស៊ីសាច់មនុស្ស តែនេះគឺជារឿងព្រេងតែប៉ុណ្ណោះ។ នៅពេលពិនិត្យមើលអោយបានច្បាស់ គឺសត្វស្លាបទាំងពីរនេះមានរោមស្លាបពណ៌ប្រផេះ ហើយរោមកមានរង្វង់ពណ៌ក្រហម ដែលមើលទៅបីដូចជា នារីតុបតែងខ្លួនដោយបំពាក់ខ្សែកយ៉ាងល្អប្រណិតអីចឹង។ អាត្មាភាពមានការទុកចិត្ត នៅពេលមើលឃើញអាការស្លូតបូត និងស្និទ្ធស្នាលនៅក្នុងកែវភ្នែករបស់សត្វទាំងគូនេះ។ មួយរំពេចក្រោយមក ពួកវាចាប់ផ្តើមហោះទៅខាងមុខបន្តបន្ទាប់គ្នា ដោយទទះស្លាបព្រមៗគ្នានៅលើអាកាសវេហាយ៉ាងសង្ហារអស្ចារ្យ។

អាត្មាភាពបានប្រញាប់ប្រញាល់ទៅកាន់បណ្ណាល័យ ដើម្បីស្រាវជ្រាវវចនានុក្រមហើយក៏បានរកឃើញថា សត្វស្លាបប្រភេទនេះគឺជាសត្វក្រៀលពណ៌ក្រហម ដែលមានឈ្មោះអន្តរជាតិជា Sarus Crane។ សត្វនេះមានកម្ពស់មធ្យម១.៧០ម៉ែត្រ និងមានទម្ងន់ប្រមាណ៩គីឡូក្រាម។

សត្វក្រៀលប្រភេទនេះ គឺជាសត្វស្លាប ដែលមានកម្ពស់លើសសត្វស្លាបដទៃលើពិភពលោក ហើយពួកវាចូលចិត្តរស់នៅជាគូ។ នេះពិតជារូបភាពនៃសុភមង្គល និងជានិមិត្តនៃភាពសម្របសម្រួលនៃជីវិត។

អាត្មាភាព បានចាប់ផ្តើមធ្វើការទាក់ទងជាមួយនឹងអង្គការការពារបរិស្ថាននានា ហើយក៏បានសិក្សាច្បាស់ថា សត្វស្លាបប្រភេទនេះកម្រមានណាស់ ហើយវាក៏កំពុងតែបាត់ពូជបណ្តើរៗទៅហើយ។ ផលប្រយោជន៍

ជាដំបូងដែលអាត្មាភាពទទួលបាន ពីការបង្ហាញខ្លួនរបស់សត្វក្រៀល គឺអាត្មាភាព បានមានឱកាសបើកទូលាយ នូវទំនាក់ទំនងមិត្តភក្តិក្នុងមជ្ឈដ្ឋានអង្គការការពារបរិស្ថានពិភពលោកនានា ហើយនេះក៏ជាហេតុផលដែលបាននាំអោយពួកគេមកកាន់**លុម្ពិនីវ័ន្ត**នេះដែរ។

អាត្មាភាពបានធ្វើការសិក្សាស្រាវជ្រាវ ហើយក៏បានដឹងថា នៅពិភពលោកយើងនេះ ពពួកសត្វក្រៀលមានប្រមាណ១៥ប្រភេទខុសៗគ្នា។ ឧបមាដូចនៅតាមប្រទេសចិន គឺមានសត្វក្រៀលក្បាលក្រហមប្រកបដោយរោមស្រួចចំពីលើក្បាល។ នៅតាមបណ្តាប្រទេសអាហ្វ្រិកដូចជា **តូហ្គូ, ហ្សាយរេ តង់ហ្សានីយ៉ា** គឺមានសត្វក្រៀលកពណ៌ខ្មៅ និងប្រភេទសត្វក្រៀលរោមក្បាលពណ៌ក្រហម មានវត្តមាននៅកុងហ្គោ និងអាហ្វ្រិកខាងត្បូង។ ម៉្យាងទៀត នៅតាម**តំបន់ស៊ីបេរី** គឺមានសត្វក្រៀលពណ៌ស ដែលតែងតែនាំគ្នាហោះមកកាន់ប្រទេស**នេប៉ាល់** និង **ឥណ្ឌា**ជារៀងរាល់ឆ្នាំ ដើម្បីចៀសវាងធាតុអាកាសត្រជាក់យ៉ាងខ្លាំងនៅទីនោះ។ នៅភាគខាងត្បូងនៃប្រទេស**កាណាដា** គេបានឃើញសត្វក្រៀលមានរោមពណ៌ដីខ្សាច់ ប្រកបដោយស្នាមអុចៗយ៉ាងលម្អិតដូចគ្រាប់ខ្សាច់ ពួកសត្វទាំងនេះបានជម្លៀសខ្លួនទៅកាន់**រដ្ឋផ្លរីដា** (Florida) ដើម្បីទទួលយកនូវធាតុអាកាសកក់ក្តៅ។ នៅកម្ពស់ពី៦០០០ ដល់៧០០០ម៉ែត្រក្នុងតំបន់**ភ្នំហិមពាន្ត** គេបានឃើញប្រភេទសត្វក្រៀលដែលមានក្បាលពណ៌ខ្មៅ។

នៅប្រទេស**វៀតណាម** គឺមានសត្វក្រៀលក្បាលពណ៌ក្រហម ដែលអាត្មាភាពយល់ថា នេះជាសត្វក្រៀល Sarus Crane នៅប្រទេស**វៀតណាម**។ សត្វប្រភេទនេះ ពុំមានកម្ពស់ដូចគ្នានឹងសត្វក្រៀលដែល កំពុងតែរស់នៅឯ**លុម្ពិនីវ័ន្ត**ឡើយ។ អាត្មាភាព ក៏តែងតែហៅសត្វនេះថា ក្រៀលក្រហមវៀតណាម ដើម្បីបង្ហាញនូវមោទនភាពអំពីវត្តមាន របស់សត្វនេះនៅវៀតណាម ទោះបីសត្វប្រភេទនេះ ពុំដែលមានកំណើតនៅប្រទេសវៀតណាម ដោយសារធាតុអាកាស និងបរិស្ថានមិនអំណោយផលក៏ដោយ។ តាមធម្មតាសត្វក្រៀលប្រភេទនេះ គ្រាន់តែបង្អាក់ដំណើរមួយរយៈពេលយ៉ាងខ្លីនាពេលរដូវទឹកស្រកនៅ**តំបន់ត្រាំជីម** (Tram Chim)នៃ**ខេត្តដុងថាប** តែប៉ុណ្ណោះ ហើយពួកវា នឹងបន្តដំណើរហោះទៅកាន់ប្រទេស**កម្ពុជា**នៅរដូវទឹកឡើង។

ក្រោយរយៈពេលធ្វើដំណើរជុំវិញពិភពលោកជាច្រើនឆ្នាំ ដើម្បីស្វែងយល់អំពីសត្វក្រៀល អាត្មាភាពក៏បានយល់ច្បាស់ នូវលក្ខណៈពិសេសនៃប្រភេទសត្វក្រៀលនីមួយៗផងដែរ គឺអំពីរបៀបហោះហើរ ការចុះមកលើដី និងសំឡេងស្រែកមានលក្ខណៈខុសៗពីគ្នា។ ដោយឡែកសត្វក្រៀល Sarus Crane មិនត្រឹមតែ ជាប្រភេទសត្វស្លាបខ្ពស់ជាងគេបង្អស់លើពិភពលោកប៉ុណ្ណោះទេ គឺវាថែមទាំងមានបញ្ញាប្រកបដោយភាពឈ្លាសវៃជាងសត្វស្លាបដទៃទៀតដែរ។

ភាគច្រើនសត្វក្រៀលក្បាលពណ៌ក្រហម តែងតែធ្វើជម្រកនៅតាម

ទីកន្លែងដែលមានទឹករាក់ និងរស់នៅលើដីសើម។ អ្នកខ្លះបានវាយតម្លៃពុំត្រឹមត្រូវអំពីផលប្រយោជន៍នៃតំបន់ដីលិចទឹក ដោយគ្រាន់តែសន្មត់ថាតំបន់ដីលិចទឹកទាំងនេះបានបង្កនូវភក់ជ្រាំ និងក្លិនស្អុយតែប៉ុណ្ណោះ។ ការពិតគឺតំបន់នេះ បានដើរតួនាទីយ៉ាងសំខាន់ចំពោះបរិស្ថាននៃផែនដី វាបានសម្រួលដល់ភាពប្រក្រតីនៃធាតុអាកាស និងធម្មជាតិ។ តាមការស្រាវជ្រាវរបស់អាត្មាភាព គឺចំនួន៧០%នៃប្រភេទត្រី ត្រូវបានបង្កើតនៅឯតំបន់លិចទឹកបន្ទាប់មកទើបពួកវាបានជម្លៀសខ្លួនចេញទៅឯទន្លេ និងសមុទ្រ។ អាស្រ័យហេតុនេះ បានជាយើងត្រូវមានគម្រោងកម្មវិធីថ្នាក់ជាតិ និងអន្តរជាតិសម្រាប់ការពារតំបន់ដីលិចទឹក ដែលកំពុងតែត្រូវបាត់បង់ជាបណ្តើរៗទៅហើយ។

# ប្រធានសមាគមន៍ការពារសត្វបក្សាបក្សី

ចាប់តាំងពីពេល សត្វក្រៀលមានវត្តមាននៅឯ**លុម្ពិនីវ័ន្ត** គឺក្រៅពីការងារមមាញឹកប្រចាំថ្ងៃ អាត្មាភាពថែមទាំងត្រូវទទួលយកនូវកិច្ចការមួយផ្សេងទៀតនោះ គឺការពារសត្វបក្សាបក្សីនេះឯង។ អាត្មាភាពបានបង្កើតផ្នែកមួយ សម្រាប់ទទួលតែការងារការពារសត្វក្រៀល ក្នុងនោះអាត្មាភាពក៏ជាសមាជិកមួយយ៉ាងសកម្មផងដែរ។

ដោយបានពិនិត្យមើលសត្វក្រៀលរាប់ឆ្នាំកន្លងមក អាត្មាភាពក៏អាចប្រាប់បានច្បាស់ថា សត្វណាមួយជាឈ្មោល សត្វណាមួយជាសត្វញី បានយ៉ាងងាយដែរ។ សត្វនេះមានលក្ខណៈខុសប្លែកពីមនុស្ស តាមធម្មតានារីភេទតែងតែមានរូបរាងស្អាតជាងបុរសភេទ ផ្ទុយទៅវិញ សត្វក្រៀលឈ្មោលមានពណ៌សម្បុរយ៉ាងឆើតឆាយ និង មានរូបរាងយ៉ាងសង្ហាជាងសត្វក្រៀលញី ជាពិសេសសត្វក្រៀលឈ្មោល មានរោមស្លាបរលោងជាងសត្វក្រៀលញី ម្យ៉ាងទៀត រង្វង់ពណ៌ក្រហមនៅជុំវិញករបស់វាក៏ធំជាងសត្វក្រៀលញីដែរ។ នៅពេលមើលឃើញ ក្រៀលឈ្មោលមកចែចង់ក្រៀលញី គឺយើងនឹងឃើញនូវអាការទន់ភ្លន់ ថ្នាក់ថ្នម ប្រៀបបីដូចជាមាណពមួយរូប មកចែចង់ស្រីគ្រប់លក្ខណ៍អ៊ីចឹងណា៎! ។

ក្រៀលឈ្មោលត្រដាងស្លាបហោះក្រឡឹងលើអាកាស ដើម្បីបង្ហាញ

ភាពសង្ហារបស់ខ្លួន ក្នុងខណៈនោះ ក្រៀលញីបានបង្ហាញនូវភាពអឹមអៀន ដោយមិនបញ្ចេញអាការតបត វាគ្រាន់តែផ្ទៀងក្បាល ងើយមើលដោយអាការស្ងើចសរសើរតែប៉ុណ្ណោះ។ ក្រោយពេល ពួកគេបានយកជាគ្នារួចហើយ គឺសត្វក្រៀលមួយគូនោះ ទៅណាមកណាក៏ទៅជាមួយគ្នាដែរ គឺពុំខុសពីមនុស្សឡើយ។ នៅពេលហោះហើរទៅណាក្តី គឺសត្វឈ្មោលតែងតែហោះមុននាំមុខ ព្រមទាំងការពារសត្វញីប្រៀបដូចសុភាពបុរសអ៊ីចឹង!។

ជារៀងរាល់ឆ្នាំពេលរដូវភ្លៀងមកដល់ ក្នុងអំឡុងពេលខែ៦ គឺជារដូវសត្វក្រៀលពង។ សត្វក្រៀលទាំងគូនេះ បានជ្រើសរើសកន្លែងល្អយ៉ាងហ្មត់ចត់សម្រាប់ធ្វើជាសំបុករបស់ខ្លួន។ សត្វទាំងគូនេះ បានហោះហើរទៅមកជាច្រើនដងនៅលើកន្លែងណាមួយ ដើម្បីពិនិត្យមើលតំបន់ជុំវិញហើយនឹងហោះចេញទៅមួយរំពេច បើសិនជាវាឃើញអសុវត្ថិភាពនៅទីនោះ។ ប្រៀបដូចនឹងមនុស្សដែរ នៅពេលណា ដែលជីវិតត្រូវជួបនឹងការគំរាមកំហែងគឺ យើងនឹងត្រូវស្វែងរកវិធីទប់ទល់ ហេតុនេះហើយបានជាសត្វក្រៀលតែងតែរៀបចំសំបុកនៅច្រើនកន្លែង ដែលតាមការគិតឃើញរបស់អាត្មាភាព វាធ្វើដូចនេះ គឺដើម្បីបំភាន់ភ្នែករបស់អ្នកគំរាមកំហែងដល់ពួកវា។ ទោះបីយ៉ាងនេះក្តី អាត្មាភាពនៅតែអាចប៉ាន់ស្មានយ៉ាងត្រឹមត្រូវនូវសំបុកណាមួយដែលសត្វក្រៀល នឹងធ្វើការជ្រើសរើសសម្រាប់ក្រាបពងនៅពេលខាងមុខ។ ប្រការនេះបានញ៉ាំងអោយពួកអ្នកស្រុក និងបងប្អូននៅក្នុង

ព្រះវិហារជាមួយអាត្មាភាព ដែលបានប្រកបការងារការពារ សត្វស្លាបនោះ មានការងឿងឆ្ងល់យ៉ាងខ្លាំង។

អាត្មាភាពគ្រាន់តែយកចិត្តទុកដាក់តាមដាន សត្វក្រៀលមួយគូណាមួយ មើលច្បាស់នៅកន្លែងណា ដែលពួកវាតែងតែទៅមកយ៉ាងញឹកញាប់ ដោយបញ្ចេញអាការអាឡោះអាល័យ ជាពិសេសគឺការត្រៀមរៀបចំកន្លែងសំបុករបស់វាយ៉ាងហ្មត់ចត់នោះហើយ គឺ ប្រាកដជាកន្លែងដែលពួកវានឹងជ្រើសរើសយក សម្រាប់ក្រាបពងនៅថ្ងៃក្រោយជាពុំខាន។

ក្រៀលឈ្មោល តែងពាំចំបើងមករៀបនៅពីក្រោមសំបុក ដើម្បីក្រៀលញីបានក្រាបពងនៅលើកន្លែងស្ងួត។ ជាពិសេស ក្រៀលឈ្មោលបានជ្រើសរើសសរសៃចំបើងយ៉ាងហ្មត់ចត់ ដោយប្រើចំពុះរលាស់សរសៃចំបើងជាច្រើនដងអោយជ្រុះអស់ដង្កូវ ឬ កំទេចសំរាមដែលនៅជាប់នឹងចំបើងមុនពេលវាជ្រើសយកមកប្រើប្រាស់ធ្វើជាសំបុក។

ក្នុងអំឡុងពេល ក្រាបពងសត្វក្រៀលមួយគូនេះ បានស្ថិតនៅក្នុងស្ថានភាពអសុវត្ថិភាពពិតមែន។ ពេលខ្លះអាត្មាភាព បានគន់មើលពីចម្ងាយនូវសត្វក្រៀលមួយគូ ដែលសម្លឹងមើលពងរបស់វាដោយក្តីបារម្ភ ប្រហែលជាពួកវាភិតភ័យនឹងការបាត់បង់កូនរបស់ខ្លួន ហើយមើលទៅ!។ ក្នុងរយៈពេលក្រាបពង បើសិនជាពងរបស់វា ត្រូវសត្វព្រៃមកស៊ីបំផ្លាញ ឬត្រូវមនុស្សមកលួចទៅបាត់ សត្វក្រៀលមួយគូនេះនឹងត្រូវរងនូវសេចក្តីសោកសៅ

យ៉ាងខ្លាំងជាពុំខាន។ ភ្នែករបស់ពួកវានឹងពោរពេញទៅដោយក្ដីទុក្ខព្រួយ ហើយបានបន្លឺសំឡេងយំស្រែកគួរអោយអាណោចអាធ័ម រួចក៏ឱនក្បាលចុះក្រោមស្លាប ដោយអាការសោកសៅយ៉ាងអស់សង្ឃឹម។

អាស្រ័យហេតុនេះ ក្រោយពេលក្រៀលញី បានពងរួចហើយ អាត្មាភាពចាត់ចែងមនុស្សម្នា អោយសាងសង់ខ្ទមស្បូវមួយជាបន្ទាន់ ដែលមានចម្ងាយប្រមាណប្រាំពីរ ឬ ប្រាំបីម៉ែត្រពីសំបុករបស់វា ហើយបានចាត់អោយមានអ្នកយាមទាំងយប់ទាំងថ្ងៃ។ ក្រុមការងាររបស់អាត្មាភាព បានដំណើរការយ៉ាងរួសរាន់ ដើម្បីបន្ថយនូវកង្វល់របស់ពួកសត្វក្រៀលទាំងនេះ។ ក្រោយពេលការសាងសង់ខ្ទមស្បូវបានបញ្ចប់រួចរាល់ និងការយាមកាមត្រូវបានរៀបចំនៅក្បែរពួកវា សត្វក្រៀលមួយគូនេះបានបង្ហាញចេញនូវភាពទុកចិត្តជាបណ្ដើរៗ។

ហេតុការណ៍នេះក៏មិនខុសប្លែកពីមនុស្ស ដែលត្រូវស្ថិតនៅក្នុងសង្គមមួយប្រកបដោយអស្ថេរភាព ប្រជាជននឹងមានការភិតភ័យ។ បើសិនជាបរិយាកាសរស់នៅមានភាពជ្រួលច្របល់ គឺមនុស្សម្នាពុំដែលមានសេចក្ដីសុខឡើយ។ ក្នុងគ្រួសារមួយក៏យ៉ាងដូចនេះដែរ ល្គឹកណាគ្រួសារប្រកបដោយរបៀបរៀបរយក្នុងការរស់នៅ ល្គឹកនោះកូនចៅទាំងអស់ក៏ទទួលនូវសេចក្ដីសុខសាន្តខាងស្មារតីដែរ។

សត្វក្រៀលពងយ៉ាងច្រើនបានពីរក្នុងមួយរដូវ ក្រោយពេលបានពង

រួចហើយ ក្រៀលញីនឹងក្រាបពងនៅក្នុងសំបុក រីឯក្រៀលឈ្មោលវិញគឺវាដើរជុំវិញទីនោះ ដើម្បីការពារមេ និងកូនរបស់វា ហើយបានត្រៀមខ្លួនជានិច្ចសម្រាប់ការតទល់យ៉ាងប្ដូរផ្ដាច់ ល្មីកណាមានសត្វមកបៀតបៀននៅក្បែរនោះ។ នៅពេលណាក្រៀលញី ងើបដើរចេញមកក្រៅ (អាត្មាភាពយល់ថាប្រហែលជាវានឿយហត់ និងស្ពឹកជើងយ៉ាងវែងរបស់វា) គឺក្រៀលឈ្មោលបានដើរចូលទៅក្រាបពង ជំនួសអោយក្រៀលញីវិញម្ដង។ ជាការគួរអោយចាប់អារម្មណ៍ គឺក្រៀលឈ្មោលមានលក្ខណៈស្រដៀងនឹងមនុស្សប្រុស គឺវាចូលមកជំនួសក្រៀលញីដោយបង្ខំចិត្ត នៅពេលក្រៀលញីដើរចេញពីកន្លែងដើម្បីស្វែងរកចំណីអាហារ ក្រោយពេលក្រាបពងជាច្រើនម៉ោង។ ពេលទើបតែឃើញ ស្រមោលរបស់ក្រៀលញីវិលត្រឡប់មកវិញភ្លាមនោះក្រៀលឈ្មោល ក៏ស្ទុះចេញពីសំបុកយ៉ាងរហ័សដើម្បី "ប្រគល់កន្លែង" ទៅអោយក្រៀលញីវិញ។ ហេតុការណ៍នេះ ក៏បានបង្ហាញអោយយើងឃើញថា សត្វណាមួយជាញី សត្វណាមួយជាឈ្មោល ដោយយើងគ្រាន់តែឈរមើលនៅពេលពួកវាក្រាបពងតែប៉ុណ្ណោះ។

ថ្វីត្បិតតែ ក្រៀលឈ្មោលមានការខ្ជិលច្រអូសក្នុង "កិច្ចការមេផ្ទះ" ក៏ដោយ វាក៏មានចរិតដូចបុរសល្អៗទាំងឡាយផងដែរ គឺវាមានស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះការការពារគ្រួសារជាទីស្រលាញ់របស់វាដែរ។ នៅពេលពួកវាត្រូវគេវាយលុក គឺក្រៀលឈ្មោលបញ្ចេញសម្រែកយ៉ាងខ្លាំង

រួចត្រដាងស្លាបដ៏ធំសម្រុកចូលទៅរកគូបដិបក្ខយ៉ាងសន្ធឹកសន្ធាប់ ក្នុងខណៈដែលក្រៀលញីឈរការពារកូនរបស់ខ្លួន។ របៀបការពារដូចនេះបណ្ដាលអោយសត្វព្រៃយ៉ាងកាចសាហាវ ដូចជាឆ្កែចចក ក៏ត្រូវដកខ្លួនថយដែរ ទោះបីការវាយលុកយ៉ាងជាក់ស្ដែងរបស់ឆ្កែចចក អាចនឹងយកជ័យជំនះទៅលើសត្វក្រៀលក៏ដោយ។ ចំពោះមនុស្សក៏ត្រូវប្រទះជួបដូច្នោះដែរ។ បើសិនជាមានអ្នកណាមកជិតកន្លែងរបស់សត្វក្រៀល គឺពួកវាតែងតែម្ចាស់ការត្រៀមប្រយុទ្ធយ៉ាងប្តូរផ្ដាច់ជាពុំខាន។ នៅមានរឿងគួរអោយចាប់អារម្មណ៍មួយផ្សេងទៀត គឺក្រោយពេលក្រៀលញីបានពងរួចហើយ គេតែងតែឃើញម្ដងម្កាលនូវសត្វក្រៀលមួយគូផ្សេងទៀត ហើរមកពីកន្លែងផ្សេងៗចុះមកទទះស្លាបព្រមៗគ្នា សំដែងចង្វាក់ដើរដូចរាំរបាំយ៉ាងល្អប្រណីត ព្រមទាំងបន្លឺសំឡេងយ៉ាងទន់ភ្លន់គួរអោយរីករាយពិតមែន។ អាត្មាភាពបានយល់ថានេះគឺជាការអបអរសាទររបស់មិត្តញាតិ ចំពោះកូនក្រៀលដែលទើបតែញាស់។ ក្រៀលមួយគូបានរាំរបាំអស់រយៈពេលប្រមាណប្រាំនាទី រួចក៏ត្រដាងស្លាបហោះទៅលើអាកាសក្រឡឹងពីរបីជុំ មុនពេលចាកចេញជាស្ថាពរ។ កូនក្រៀលនឹងញាស់ចេញពីពងក្នុងរយៈពេលពី២៨ថ្ងៃ ដល់៣៥ថ្ងៃ។ បន្ទាប់មកក្រៀលមួយគូនេះ នឹងត្រូវស្នាក់នៅកន្លែងរយៈពេល១សប្ដាហ៍ មុនពេលចាកចេញទៅរកជម្រកថ្មីមួយទៀត ដែលពួកវាយល់ថាមានសុវត្ថិភាពជាជាងទីនេះ។ ទិដ្ឋភាពសត្វក្រៀលបញ្ចុកចំណីអោយកូន គឺគួរអោយគយគន់

ពិតមែន។ ពួកក្រៀលទាំងនេះមានលក្ខណៈទៀតទាត់ពេលវេលាផងដែរ។ អាត្មាភាពបានតាមដាន ក្រៀលឈ្មោលចេញទៅរកចំណីអាហាររយៈពេល ១៥នាទី គឺបានវាវិលត្រឡប់មកវិញ។ បន្ទាប់មក ក្រៀលញីបានហើរចេញ ទៅរកចំណីអាហារអស់រយៈពេលប្រមាណ១៥នាទី ក៏វិលត្រឡប់មកដូច ក្រៀលឈ្មោលដែរ វាអាចនឹងខុសគ្នារយៈពេលយ៉ាងច្រើន គឺ១នាទីតែ ប៉ុណ្ណោះ។

ចំណីរបស់សត្វក្រៀល គឺមើមផ្លុង Water Chestnuts ឫសឈើ និងសត្វល្អិត។ ធម្មជាតិបានបង្កើតចេញសត្វស្លាប ដែលគួរអោយស្រឡាញ់ បែបនេះ ព្រមទាំងផ្តល់អោយពួកវានូវលទ្ធភាពរស់ដោយខ្លួនឯង ដោយ មិនរំខាន ឬជាបន្ទុកដល់មនុស្សលោកឡើយ។

ពេលទើបញាស់បានពីរបីថ្ងៃក្រោយមក កូនក្រៀលត្រូវបានមេបា របស់វាឆ្លាស់គ្នាបង្ហាត់បង្រៀនដូចគ្នានឹងមនុស្សដែរ។ នៅពេលបង្រៀន អោយកូនក្រៀលដើរ គឺក្រៀលឈ្មោលឈរម្ខាងរំពៃមើល រីឯក្រៀលញី បានណែនាំកូន អោយដើរតាមជំហានខ្លីមួយៗ។ ថ្ងៃបន្ទាប់មក ក្រៀលមេ បាននាំកូនដើរ កាន់តែឆ្ងាយជាងមុនជាលំដាប់ រហូតដល់ពេលកូនក្រៀល ត្រូវបានបង្ហាត់អោយចេះហើរ។

សត្វក្រៀលក៏មានវិធីយ៉ាងពិសេស សម្រាប់បង្ហាត់កូនអោយចេះហែល ដែរ។ ក្រៀលញីឈរយាមនៅលើមាត់ច្រាំង រីឯក្រៀលឈ្មោលចុះហែល

ក្នុងទឹកធ្វើជាគំរូអោយកូន១ហែលតាម។ ក្រោយពេលកូនក្រៀលបានអាយុជាង៣សប្តាហ៍ ក្រៀលមេ និងក្រៀលឈ្មោលបានបែងចែកការងារគ្នាថែរក្សាកូនរបស់ខ្លួនម្តងម្នាក់។

ក្រោយរយៈពេល៨ខែ ស្ថិតនៅក្រោមការថែរក្សាការពាររបស់មេបាកូនក្រៀលត្រូវបានធំធាត់យ៉ាងពិតប្រាកដ ហើយវាក៏បានត្រៀមខ្លួនចាកចេញពីទ្រនំ ដើម្បីស្វែងរកជីវិតរស់នៅដោយឯករាជ្យ នេះក៏ជាថ្ងៃសំខាន់បំផុតនៃជីវិតរបស់សត្វក្រៀលដែរ។ ការចាកចេញបែបនេះ តែងតែបណ្តាលអោយអាត្មាភាព ព្រមទាំងសិស្សមានការចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅប្រកបដោយភាពរីករាយ លាយឡំនឹងក្តីអាឡោះអាល័យក្រៃលែង។

នៅថ្ងៃនោះ សត្វក្រៀលមួយគូព្រមទាំងកូនរបស់វាបានរាំ និងបន្លឺសំឡេងយ៉ាងសប្បាយរីករាយ ជាទិដ្ឋភាពមួយប្រកបដោយសុភមង្គលដែលគួរអោយគយគន់យ៉ាងពន់ពេក។ បន្ទាប់មក សត្វក្រៀលទាំងបីបានទទះស្លាបហោះទៅលើអាកាសតាមទិសពីរខុសគ្នា កូនក្រៀល បានធ្វើដំណើរហោះហើរដោយឯកោឆ្ពោះទៅទិសផ្សេងពីមេបារបស់ខ្លួន ដើម្បីស្វែងរកជីវិតថ្មីរបស់វា។

សត្វក្រៀលមួយគូ១តែងមានដែនដីរៀង១ខ្លួន។ អាត្មាភាពមានការអស់សំណើចយ៉ាងខ្លាំង នៅពេលបានជួបយ៉ាងចៃដន្យ នូវទិដ្ឋភាពប្រយុទ្ធដោយការប្រចណ្ឌរបស់សត្វក្រៀល គឺនៅថ្ងៃមួយអាត្មាភាពបានប្រទះឃើញ

ការប្រយុទ្ធគ្នាយ៉ាងប្តូរផ្តាច់រវាងសត្វក្រៀលទាំងពីរ ការប្រយុទ្ធនេះត្រូវបានប្រព្រឹត្តឡើងដូចគ្នានឹងមាន់ពីរជល់គ្នាដែរ។ នៅក្បែរនោះ មានសត្វក្រៀលមួយឈរមើលការប្រយុទ្ធនេះ។ អាត្មាភាពមានការងឿងឆ្ងល់ដោយពុំដឹងច្បាស់ថា សត្វក្រៀលទីបីនេះមកពីទីណា ព្រោះអាត្មាភាពបានដឹងយ៉ាងច្បាស់ថា តំបន់ខាងជើងនេះ មានសត្វក្រៀលតែពីរក្បាលប៉ុណ្ណោះ។ នៅពេលពិនិត្យមើលដោយកែវយិតយ៉ាងហ្មត់ចត់ ទើបអាត្មាភាពបានយល់ច្បាស់ថាក្រៀលទាំងពីរដែលបានប្រយុទ្ធគ្នានោះ គឺជាសុទ្ធតែជាក្រៀលញីទាំងអស់។ ក្រោយការប្រយុទ្ធគ្នានឈ្នះចាញ់នោះ សត្វក្រៀលទីបីបានចាកចេញពីទីលានប្រយុទ្ធ។ អាត្មាភាពបានសាកសួរប្រជាជននៅជុំវិញតំបន់នេះ រួចគេបានអោយដឹងថាសត្វក្រៀលទីបីនេះ បានរស់នៅតែលតោលតែម្នាក់ឯងនៅតំបន់ទិសខាងត្បូង អស់រយៈពេលប្រមាណបីខែកន្លងមកហើយ។ អាត្មាភាពបានធ្វើការសន្មត់ថា សត្វក្រៀលនេះគឺជាតួអង្គទីបីនៅក្នុងរឿងប្រយុទ្ធគ្នាកាលពីថ្ងៃមិញ រួចអាត្មាភាពក៏យកចិត្តទុកដាក់តាមដានតទៅទៀត។

ជាការច្បាស់លាស់ណាស់ ពីរថ្ងៃក្រោយមក សត្វក្រៀលទីបីនេះបានមកដល់ទ្រនំរបស់សត្វក្រៀលមួយគូ ដែលរស់នៅតំបន់ភាគខាងជើង ក្នុងខណៈដែលក្រៀលញីបានចាកចេញទៅរកចំណីអាហារ។ ហេតុនេះក្រៀលញីឯកោដែលទើបមកដល់ មានឱកាសសប្បាយរីករាយជាមួយនឹងក្រៀលឈ្មោលម្តង។ ថៃ្ងជន្យអី ក្រៀលញីជាប្រពន្ធនោះបានវិលត្រឡប់មក ហើយ

បានប្រទះជួបដោយការភ្ញាក់ផ្អើល។ ភាគីទាំងពីរបានធ្វើការប្រយុទ្ធគ្នាយ៉ាងប្តូរផ្តាច់ រីឯក្រៀលឈ្មោលវិញគឺពុំហ៊ានចូលធ្វើអន្តរាគមន៍ឡើយ វាគ្រាន់តែរត់ជុំវិញ ព្រមទាំងបញ្ចេញសម្រែកយ៉ាងខ្លាំង ហាក់បីដូចជាស្រែកហៅអោយគេមកជួយអន្តរាគមន៍អ៊ីចឹង។

ទោះបីយ៉ាងណាក៏ដោយ នេះគ្រាន់តែជាករណីដោយឡែកមួយប៉ុណ្ណោះ។ តាមធម្មតា សត្វក្រៀលដែលជាប្តីប្រពន្ធនឹងគ្នានោះ មានភាពស្មោះត្រង់ជាមួយគ្នាណាស់។

ប្រៀបដូចគ្នានឹងមនុស្សដែរ សត្វក្រៀលតែងតែស្និទ្ធស្នាលជាមួយអ្នកណាដែលស្រលាញ់ ការពារពួកវា ផ្ទុយទៅវិញពួកវាក៏បញ្ចេញអាការកោងកាចជាមួយអ្នកណា ដែលមានគំនិតធ្វើបាបដល់ពួកវាដែរ។ សត្វក្រៀលតែងមកព្រះវិហាររបស់អាត្មាភាព ហើយពួកវាក៏បានបញ្ចេញអាការស្និទ្ធស្នាលជាមួយនឹងអាត្មាភាពផងដែរ។ ល្គឹកណាមានការគំរាមកំហែង គឺសត្វក្រៀលបានប្រញាប់ប្រញាល់ហើរ មកដល់ព្រះវិហាររបស់អាត្មាភាព ដែលមានចម្ងាយប្រមាណពីរគីឡូម៉ែត្រពីសំបុករបស់វា ដើម្បីស្វែងរកការការពារ ទោះបីស្ថិតនៅពេលយប់ក៏ដោយ។ គ្រាន់តែស្តាប់សំឡេងរបស់សត្វក្រៀល អាត្មាភាពក៏អាចប៉ាន់ស្មានបាន នូវអារម្មណ៍របស់ពួកវាដែរ។ ល្គឹកណាមានការសប្បាយចិត្ត ល្គឹកនោះសត្វក្រៀលបានបញ្ចេញសម្រែកយ៉ាងគ្រលួច។ ល្គឹកណាវាមានការព្រួយចិត្ត ល្គឹកនោះវាបានបញ្ចេញសម្រែកយ៉ាង

អាណោចអាធ័ម សម្រែកនៅពេលភ័យខ្លាចក៏មានការខុសប្លែកពីសម្រែកនៅពេលខឹងសម្បាដែរ។ សម្រែករបស់សត្វក្រៀលបានប្រកបដោយលក្ខណៈរួមគ្នា លុះត្រាណាសត្វក្រៀលមួយបានបន្លឺសម្រែក លុះត្រានោះសត្វក្រៀលមួយផ្សេងទៀត បានបញ្ចេញសម្រែកតបតទៅវិញ។ សត្វក្រៀលតែងតែបង្ហាញចេញយ៉ាងច្បាស់នូវភាពរីករាយ ឬក្ដីទុក្ខព្រួយពេលណាពួកវាសប្បាយចិត្ត គឺពួកវាសំកាំងស្លាបរាំរែកជាមួយគ្នា នៅពេលណាមានក្ដីទុក្ខព្រួយពួកវាត្បុលក្បាលចូលក្រោមស្លាបដោយស្ងៀមស្ងាត់ ជួនកាលវាបានបោះជំហានទៅមកដោយអាការអស់សង្ឃឹម ព្រមទាំងបានបំភ្លេចនូវការរកចំណីអាហារទៀតផង។ ពេលណាដែលសត្វក្រៀលមក ស្រែកឃំអោយមានការជួយសង្គ្រោះ អាត្មាភាពតែងបានចាត់ការជាបន្ទាន់ ដោយអោយគេជិះកង់ឬម៉ូតូទៅដល់កន្លែងកើតហេតុដើម្បីដោះស្រាយបញ្ហា។ ហេតុនេះហើយបានជាអាត្មាភាពមានវិទ្យុទាក់ទងជាច្រើន នៅឯព្រះវិហារ ដើម្បីងាយស្រួលក្នុងការទាក់ទងគ្នា។ បើសិនជា មានអ្នកស្រុកនៅទីនោះចូលមកលួចពងក្រៀល គឺអាត្មាភាពបានរាយការណ៍ ទៅដល់រដ្ឋអំណាចមូលដ្ឋាន ដើម្បីសុំអោយគេជួយអន្តរាគមន៍។

ការគំរាមកំហែងដ៏ធំមួយចំពោះសត្វក្រៀលនៅឯ**លុម្ពិនីវ័ន្ត** គឺខ្សែភ្លើងអគ្គិសនីប្រកបដោយថាមពលខ្ពស់ រាយខ្វាត់ខ្វែងនៅលើអាកាស។ទិដ្ឋភាពសត្វក្រៀលត្រដាងស្លាបចុះសន្សឹម១មកនោះ គឺជាទិដ្ឋភាពដ៏ស្អាតគួរអោយ

គយគន់ពេកក្រៃ ប៉ុន្តែការចុះមកទំនៅលើខ្សែភ្លើងនោះ គឺជាគ្រោះថ្នាក់ដល់ជីវិតរបស់សត្វក្រៀលមួយចំនួនដែរ។

នៅដើមខែមិថុនា ឆ្នាំ២០០០ មានសត្វក្រៀលមួយគូបានហោះមកធ្វើសំបុកនៅព្រះវិហាររបស់អាត្មាភាពនៅ**លុម្ពិនីវ័ន្ត**។ ជាការគួរអោយខ្លោចផ្សាពន់ពេក គឺនៅមុនពេលសត្វក្រៀលញីពង សត្វក្រៀលឈ្មោលត្រូវស្លាប់ដោយភ្លើងអគ្គិសនីឆក់ នៅពេលហោះចុះមកលើដី។ អាត្មាភាព និងពុទ្ធបរិស័ទ បានធ្វើពិធីបញ្ចុះសាកសពរបស់វាបីដូចជាមនុស្សដែរ។ ក្នុងរយៈពេលមួយសប្តាហ៍ក្រោយមក ជារៀងរាល់ព្រឹកក្រៀលញី បានមកដល់កន្លែងដែលក្រៀលឈ្មោលបានស្លាប់នៅទីនោះ ដើម្បីស្រែកយំ។ នៅពេលនេះហើយ ដែលអ្នកទាំងឡាយក្នុងព្រះវិហារមានក្តីសោកសៅដូចកំពុងកាន់ទុក្ខអីចឹង ជាពិសេសគឺនៅពេលបានឮដល់សំឡេងយំស្រែករបស់ក្រៀលញីដែលនៅកំព្រាម្នាក់ឯង គួរអោយអាណិតណាស់។ ចាប់ពីពេលនោះមកល្គឹកណាដែលក្រៀលញីចង់ហោះហើរចេញទៅ គឺវាតែងតែងោកក្បាលរត់ចេញអោយផុតពីកន្លែង ដែលមានខ្សែភ្លើងរាយដេរដាសពេញអាកាស រួចទើបហោះចេញទៅ។ ហេតុការណ៍នេះបញ្ជាក់យ៉ាងច្បាស់ថា សត្វក្រៀលមានភាពវាងវៃយ៉ាងវិសេសវិសាល ព្រោះវាបាន យល់ច្បាស់នូវហេតុបណ្តាលអោយគូរបស់វាស្លាប់ដោយអាណោចអាធ័ម។

អាត្មាភាពបានអំពាវនាវយ៉ាងអស់ពីចិត្ត ព្រមទាំងបានសង្ឃឹមថា នៅ

ពេលដែលសេដ្ឋកិច្ចរបស់ប្រទេសនេប៉ាល់មានការរីកចម្រើន គឺរដ្ឋអំណាចនៅមជ្ឈិម និងនៅតាមមូលដ្ឋាន នឹងមានផែនការផ្លាស់ប្តូរប្រព័ន្ធខ្សែភ្លើង ឬមួយបង្កប់ខ្សែភ្លើងនៅក្រោមដី។

❋❋❋❋❋

# ការពារសត្វក្រៀល

នៅក្នុងចំណោមការគំរាមកំហែងចំពោះសត្វក្រៀល គឺមនុស្សយើងបានក្លាយទៅជា គ្រោះថ្នាក់យ៉ាងធំបំផុតចំពោះពួកវា។ ចាប់ពីពេលសត្វក្រៀលមានវត្តមាននៅព្រះវិហារ **វៀតណាមហ្វីកវ៉ុកទី** ដែលស្ថិតនៅក្នុង **លុម្ពិនីវ័ន្ត** មនុស្សម្នាបាននាំគ្នាមកទស្សនាយ៉ាងកុះករ។ ប្រជាជនដែលរស់នៅតំបន់ជិតខាង ក៏បាននាំគ្នាមកយ៉ាងសន្ធឹក ក្រោយពេលបានឮថា មានសត្វស្លាបចម្លែកមករស់នៅក្បែរព្រះវិហារ។

ចៃដន្យអីមានពាក្យចចាមអារ៉ាម នៅក្នុងចំណោមអ្នកស្រុកថា បើសិនជាអ្នកណាបានហូបពងរបស់សត្វក្រៀលក្រហមនោះ គេនឹងរស់បានទៅដល់ ៥០០ឆ្នាំ ហើយបើសិនជាបានហូបសាច់ក្រៀល គឺរស់បានទៅដល់៧០០ឆ្នាំ។ ហេតុនេះហើយ ជីវិតរបស់សត្វជាទីស្រឡាញ់ និងស្លូតបូតទាំងនេះត្រូវបានគំរាមរាតត្បាតទៅវិញ។ មនុស្សមួយចំនួនបានលួចពងរបស់វា រួចក៏បានស្វែងរកវិធីបរបាញ់ទៀតផង។

ចាប់ពីពេលនោះមក អាត្មាភាព និងសិស្សមានការលំបាកវេទនាយ៉ាងខ្លាំង ក្នុងកិច្ចការពារសត្វក្រៀលទាំងនេះ។ ទាំងគ្រូ ទាំងសិស្សមានចំនួនត្រឹមតែជាងដប់នាក់ សម្រាប់ប្រឈមមុខតទល់នឹងមនុស្សរាប់រយនាក់ដែលលបពួនទាំងយប់ទាំងថ្ងៃ។ ល្កឹកណាមានសត្វក្រៀលក្រាបពង គឺក្រុម

របស់អាត្មាភាព  បានចាប់ផ្តើមលើកផែនការយាមកាមយ៉ាងស្អិតទាំងយប់ទាំងថ្ងៃ ទោះបីយ៉ាងនេះក្តី ក៏នៅតែមានការភ្លាត់ស្នៀតដែរ អោយតែអ្នកយាមដេកលក់ គឺចោរចូលមកលួចពងក្នុងមួយរំពេចពុំខាន។

កិច្ចការពារសត្វក្រៀលនេះ ត្រូវចំណាយពេលវេលាថវិកា និងកម្លាំងជាច្រើន។ អាត្មាភាព បានធ្វើការបំផុសរដ្ឋអំណាចមូលដ្ឋាន និងសារពត៏មានអោយគេបញ្ចូលសត្វក្រៀល នៅក្នុងប្រភេទសត្វដែលត្រូវបាន ការពារយ៉ាងពិសេស ព្រមទាំងបានស្នើអោយផ្សព្វផ្សាយ នូវច្បាប់ពិន័យយ៉ាងធ្ងន់ចំពោះជនដែលបានគំរាមកំហែង ដល់ជីវិតរបស់សត្វនេះ។ រដ្ឋអំណាចបានចេញសេចក្តីប្រកាសមួយ ដែលមានខ្លឹមសារថា "ជនទាំងឡាយណាដែលបរបាញ់សត្វក្រៀល គឺត្រូវបង់ប្រាក់ពិន័យយ៉ាងច្រើន និងអាចឈានទៅដល់ការទទួលទោសព្រហ្មទណ្ឌទៀតផង"។

ប៉ុន្តែការខិតខំទាំងអស់នេះ មិនបានសម្រេចដូចបំណងឡើយ ពងក្រៀលត្រូវបានគេលួចជាបន្តបន្ទាប់។ នៅពេលពងក្រៀល ត្រូវបានគេលួចម្តង១ គឺវាមិនខុសប្លែកពីរឿងចាប់ជីវិតឡើយ។ ក្រុមរបស់អាត្មាភាពបានសហការជាមួយប៉ូលិសទៅរុករកឆែកឆេរគ្រប់ទីកន្លែង ប៉ុន្តែពុំអាចរកឃើញភស្តុតាងបានឡើយ នៅពេលដែលពងក្រៀលនោះ ត្រូវបានលាក់ទុកដោយសុវត្ថិភាពនៅក្នុងក្រពះរបស់អ្នកលួច។ ជួនកាល យើងបានរកឃើញសំបក

ពងដែលត្រូវបានគេកប់នៅក្នុងដីតែប៉ុណ្ណោះ រីឯជនដៃដល់ គឺគ្មានអ្នកណាមួយ ដែលត្រូវគេសម្គាល់បានឡើយ។

ដោយសេចក្ដីស្រឡាញ់ធម្មជាតិ និងសត្វលោកទាំងឡាយ អាត្មាភាពពិតជាមានទុក្ខកង្វល់ក្នុងចិត្តពិតមែន។ នៅពេលអាត្មាភាព បានឮថាពងក្រៀលត្រូវបានគេលួចម្ដងៗ គឺពេលនោះអាត្មាភាព មានការព្រួយចិត្តដល់ស្រក់ទឹកភ្នែកទៀតផង។ សិស្សរបស់អាត្មាភាពមួយចំនួន បានពោលកំប្លែងថា អាត្មាភាពបានជំពាក់បំណុលចំពោះសត្វក្រៀល បានជាអាត្មាភាពត្រូវទទួលការលំបាកចិត្តជាច្រើនអំពីពួកវា។ នៅពេលនេះ សិទ្ធិអំណាចរបស់មនុស្សគ្មានប្រសិទ្ធិភាពទៀតឡើយ ទោះបីអ្នកលួចត្រូវបានគេចាប់ដាក់គុកក៏ដោយ នៅពេលពួកគេបានសេរីភាពវិញ គឺពួកគេនៅតែបន្តការបរបាញ់សត្វក្រៀលដដែល។

អាត្មាភាពមានជំនឿទៅលើភាពពិសិដ្ឋអស្ចារ្យ នៃទីកន្លែងកំណើតជាទីសក្ការៈរបស់ព្រះសម្មាសម្ពុទ្ធ ពីព្រោះនៅពេលមានរឿងបន្ទាន់ អាត្មាភាពតែងតែមកបួងសួងនៅទីនេះ។ អាត្មាភាពបានដើរប្រទក្សិណសសរសិលាចារឹកនៃ**ស្ដេចអសោក** ព្រមទាំងភាវនាបួងសួង សូមព្រះអង្គនិងវត្ថុស័ក្ដិសិទ្ធិទាំងឡាយថែរក្សា នឹងប្រទានមហិទ្ធិឫទ្ធិដល់អាត្មាភាព សម្រាប់ការពារសត្វក្រៀលទាំងនេះផង។

ក្រោយពេលបួងសួងយ៉ាងស្មោះអស់ពីដួងចិត្ត អាត្មាភាព បានវិលត្រឡប់

មកព្រះវិហារ ដើម្បីព្រាងសេចក្តីប្រកាសមួយ ជាភាសានេប៉ាល់ ដោយមានខ្លឹមសារថា : "សត្វក្រៀលដែលកំពុងមានវត្តមាននៅទីនេះ គឺជាប្រភេទសត្វប្រកបដោយឫទ្ធានុភាព គឺវាបាននាំមកសេចក្តីសុខសាន្តដល់កន្លែងដែលវាបានស្នាក់នៅ។ សត្វក្រៀលប្រភេទនេះ កម្រមាននៅលើពិភពលោក ហេតុនេះវត្តមានរបស់ពួកវានៅទីនេះ ក៏ជាប្រផ្នូលមួយយ៉ាងល្អប្រសើរសម្រាប់អ្នកស្រុកដែរ។ ហេតុនេះហើយ ចាប់ពីពេលនេះតទៅអ្នកណាបានបំផ្លាញដល់ជីវិតរបស់សត្វនេះ គឺអ្នកនោះត្រូវតែទទួលយកនូវ ការផ្តន្ទាយ៉ាងធ្ងន់ធ្ងរ គឺអ្នកណាហូបពងក្រៀល អ្នកនោះនឹងត្រូវកើតកមរមាស់ពេញខ្លួន អ្នកណាបានសម្លាប់សត្វក្រៀល អ្នកនោះនឹងត្រូវទទួលរងគ្រោះទាំងបីជាតិ"។

សេចក្តីប្រកាសនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងស្រុក ហើយក៏បានទទួលលទ្ធផលជាវិជ្ជមានដែរ មនុស្សជាច្រើនមានការជឿជាក់ ហេតុនេះការលួចយកពងក្រៀល ក៏ត្រូវបានថយចុះមួយកម្រិត ប៉ុន្តែនៅមានជនមួយចំនួនដែលពុំមានការជឿជាក់នោះ នៅតែបន្តអំពើចោរកម្មដដែល។

រយៈពេលពីរសប្តាហ៍ក្រោយមក ស្រាប់តែមាន កម្មករម្នាក់នៅឯព្រះវិហារជប៉ុន និងឈ្មួលម្នាក់នៅព្រះវិហារវៀតណាម បានកើតកមរមាស់ពេញដៃ។ អ្នកទាំងពីរនេះមានការភិតភ័យយ៉ាងខ្លាំង ហើយក៏បានមកជួបជាមួយព្រះតេជគុណ **ណាបាតាមេ** ដែលជាចៅអធិការព្រះវិហារជប៉ុន និង

អាត្មាភាព ដើម្បីទទួលសារភាព។ ពួកគេគឺជាអ្នកលួចពងក្រៀលពិតមែន។ ដំណឹងនេះក៏ត្រូវបានផ្សាយចេញក្រៅយ៉ាងរហ័ស ហេតុនេះហើយសភាពការណ៍មានភាពធូរស្រាលច្រើន។

ក្រោយមកមិនយូរប៉ុន្មានឡើយ ស្រាប់តែលេចចេញរឿងក្មេងៗនាំគ្នាទៅបាញ់សត្វក្រៀល។ អាត្មាភាពពិបាកទាំងកាយទាំងចិត្ត ក៏ធ្វើការពិភាក្សាជាមួយនឹងប៉ូលិសមូលដ្ឋាន ដើម្បីស្វែងរកវិធីទប់ទល់ ប៉ុន្តែការនេះពុំបានទទួលលទ្ធផលឡើយ។

អាត្មាភាព បានព្យាយាមពន្យល់អោយអ្នកស្រុកយល់ច្បាស់ថា សត្វក្រៀល បាននាំមកនូវសន្តិភាពសុខដុមរមនាសម្រាប់ស្រុកនេះ ។ ម្យ៉ាងទៀតអាត្មាភាពបានខិតខំអនុវត្តនូវវិធានការអប់រំ ដោយបញ្ចាំងខ្សែភាពយន្ត តាំងពិព័រណ៍ អត្ថាធិប្បាយ ព្រមទាំងរៀបចំការប្រឡងប្រណាំងគំនូរអំពីសត្វបក្សាបក្សី ដើម្បីឆ្លៀតយកឱកាសនេះធ្វើការអប់រំក្មេងៗអោយមានចិត្តស្រឡាញ់ធម្មជាតិ និងគោរពជីវិតរបស់សត្វទាំងពួង។ អាត្មាភាពបានណែនាំអោយប្រជាជនក្នុងស្រុកស្វែងយល់អំពីជីវិតរស់នៅរបស់សត្វក្រៀល ការនេះបានញ៉ាំងអោយគេមានការស្រឡាញ់រាប់អានដល់សត្វក្រៀល ម្ល៉ោះហើយការបរបាញ់សត្វក៏ត្រូវបានថយចុះជាបណ្តើរៗ ។

ពិតមែនហើយ សត្វក្រៀលគឺជាបេសកជនប្រកបដោយបំណងល្អប្រសើរបានញ៉ាំងអោយមនុស្សបែរមករកភាពស្និទ្ធស្នាលជាមួយនឹងធម្មជាតិ ។

ដោយសារសត្វក្រៀលទាំងនេះហើយ បានជាអាត្មាភាពមានឱកាសស្និទ្ធស្នាល ជាមួយនឹងក្មេងៗ ព្រមទាំងបានយល់ច្បាស់ស្ថានភាព នៃជនក្រីក្រនៅក្នុងស្រុកនេះផងដែរ។

មានពេលមួយ ក្រៀលញី និងក្រៀលឈ្មោលត្រូវពស់ចឹកស្លាប់ទាំងគូ ដោយបន្សល់ទុកនូវកូនក្រៀលកំព្រាមួយយ៉ាងអាណោចអាធ័ម អាត្មាភាពបានយកមកចិញ្ចឹមនៅឯព្រះវិហារ។ នៅពេលវាធំឡើង អាត្មាភាពក៏បានបង្ហាត់បង្រៀនវាអោយដើរ និងរបៀបហើរឡើងដែលអាត្មាភាពធ្លាប់ឃើញក្រៀលមេបង្ហាត់កូនយ៉ាងនោះដែរ។ ញាតិញោមបរិស័ទនៅក្នុងព្រះវិហារ ព្រមទាំងអ្នកស្រុករស់នៅជុំវិញ ពុំអាចទប់នឹងសំណើចរបស់ខ្លួនបាន នៅពេលឃើញអាត្មាភាពបង្ហាត់កូនក្រៀលដោយរត់ត្រឹកៗ នៅពីមុខកូនក្រៀល ព្រមទាំងលាតសន្ធឹងដៃទាំងពីរបក់ចុះឡើង ដើម្បីអោយកូនក្រៀល យកតម្រាប់តាម។ ទោះបីយ៉ាងណាក៏ដោយ វិធីបង្ហាត់របស់អាត្មាភាពក៏មានប្រសិទ្ធិភាពដែរ កូនក្រៀលក៏ចេះទទះស្លាប និងហើរទៅយ៉ាងឆ្ងាយ។

អ្នកស្រុកដឹងច្បាស់ថា អាត្មាភាពមានចិត្តស្រឡាញ់សត្វ ហេតុនេះនៅពេលពួកគេជួប កូនក្រៀលកំព្រាណាមួយ គេតែងតែនាំយកមកអោយអាត្មាភាពចិញ្ចឹមថែរក្សា អាត្មាភាពក៏បានផ្តល់ប្រាក់មួយចំនួនតូចជារង្វាន់ជូនដល់ពួកគេដែរ។

សរុបមក អាត្មាភាពចិញ្ចឹមកូនក្រៀលបាន១០ក្បាល នៅពេលណា

អាត្មាភាពមានការងារដែលត្រូវចេញទៅឆ្ងាយ គឺអាត្មាភាពពឹងពាក់អ្នកដទៃជួយមើលថែកូនក្រៀលពីរបីថ្ងៃ ហើយសងថ្លៃឈ្នួលដល់គេ។ សត្វក្រៀលទាំងអស់ដែលអាត្មាភាពបានថែរក្សានោះ សុទ្ធតែមានស្នាមសម្គាល់នៅលើជើងរបស់ពួកវា។ បច្ចុប្បន្ននេះ ចំនួនសត្វក្រៀលនៅ**លុម្ពិនីវ័ន្ត**បានឡើងដល់៤៤ក្បាល។ ពួកវាបានរស់នៅរាយប៉ាយនៅក្នុងតំបន់ រីឯគូក្រៀលនីមួយៗមានកន្លែងរៀងៗខ្លួន ដែលគូក្រៀលដទៃទៀតពុំអាចមកជិត ឬឈ្លានពានដល់កន្លែងរបស់វាឡើយ។

នារដូវវស្សាឆ្នាំ២០០៣ សត្វក្រៀលទាំងបីគូ បានមកធ្វើសំបុកនៅក្បែរព្រះវិហារវៀតណាមនៅ**លុម្ពិនីវ័ន្ត** ហើយបង្កើតកូនបាន៦ក្បាល។ នេះគឺជាក្តីរីករាយយ៉ាងធំធេង សម្រាប់អាត្មាភាព ព្រមទាំងញាតិញោមទាំងអស់នៃព្រះវិហារវៀតណាម ដែលមានចិត្តស្រឡាញ់ថែទាំសត្វក្រៀល។

នៅពេលថ្មីៗនេះ នាពេលព្រឹកព្រលឹមមួយ អាត្មាភាពត្រៀមចេញដំណើរទៅឆ្ងាយ ស្រាប់តែសត្វក្រៀលមួយហ្វូង មានចំនួនដប់ក្បាលបានលេចចេញមកហើរក្រឡឹងនៅលើព្រះវិហារជាច្រើនជុំ បង្កើតឡើងនូវទិដ្ឋភាពមួយយ៉ាងស្អាតអស្ចារ្យ ប្រៀបដូចជាក្នុងក្តីសុបិន្តពុំខុសឡើយ។ មនុស្សម្នានៅក្នុងព្រះវិហារ បានផ្អាកការងាររត់ចេញមកគយគន់ទាំងអារម្មណ៍រវើរវាយ ដោយពុំដឹងច្បាស់ថា ខ្លួនកំពុងនៅក្នុងលោកិយ ឬនៅលើស្ថានទេវលោកឡើយ។

អាត្មាភាពបានចេញដំណើរទាំងក្ដីអាឡោះអាល័យ រួចក៏ចោទសួរដោយខ្លួនឯងថា ប្រហែលពួកវាមកជូនដំណើរយើងហើយមើលទៅ? ឆ្លៀតឱកាសនេះ មានបងប្អូនខ្លះបានពោលកំប្លែងថា នៅពេលអាត្មាភាពសុគតទៅគឺសត្វក្រៀលនឹងហៅគ្នីគ្នាមក ដើម្បីជូនដំណើរចុងក្រោយជាពុំខាន។ ចំពោះអាត្មាភាព ហេតុការណ៍នេះគឺជានិមិត្តយ៉ាងល្អប្រសើរ ហើយអាត្មាភាពយល់ថា ប្រសិនបើពេលអាត្មាភាពសុគតទៅ សត្វក្រៀលមកចូលរួមពិធីបុណ្យយ៉ាងដូច្នេះមែន គឺវាពិតជាហេតុការណ៍មួយប្រកបដោយភាពអណ្ដែតអណ្ដូងនិយមជាពុំខាន។

ចាប់ពីពេលអាត្មាភាពបានយកចិត្តទុកដាក់ដល់សត្វក្រៀល អាត្មាភាពក៏បានរកឃើញសត្វស្លាបមួយប្រភេទទៀតនៅ**លុម្ពិនីវ័ន្ត** ហើយអាត្មាភាពបានដាក់ឈ្មោះអោយវាជា បក្សីសុភាព។ ពេលណាសត្វញីរៀបចំពង សត្វឈ្មោលប្រញាប់ប្រញាល់ធ្វើសំបុក ពិសេសគឺវាធ្វើសំបុករហូតដល់ទៅប្រាំបួនឬដប់សំបុក សម្រាប់គូរបស់វារើសយកតាមចិត្ត។ ពេលណាសត្វញីរើសយកសំបុកណាមួយ ដែលខ្លួនបានពេញចិត្តហើយ ពេលនោះសត្វឈ្មោលធ្វើការបំផ្លាញចោលនូវសំបុក ដែលនៅសេសសល់។ ក្រៅពីនេះ ជនជាតិឥណ្ឌានៅមានសត្វបក្សីយ៉ាងវិសេសវិសាលមួយប្រភេទទៀត ដែលគេហៅថា សត្វខ្លាចមេឃរលំ។ បក្សីប្រភេទនេះ មានការប្រុងប្រយ័ត្នយ៉ាងពិសេសពេលយប់ មុនពេលដេកវាតែងតែហោះក្រឡឹងជុំវិញសំបុករបស់ខ្លួន ដើម្បី

ពិនិត្យមើលសភាពការណ៍ លុះត្រាណាវាយល់ឃើញថា គ្មានបញ្ហាអ្វីទេនោះទើបវា ស្ងប់ចិត្តចូលមកដេកក្នុងសំបុករបស់វា។ នៅពេលកំពុងដេកស្រាប់តែទទះស្លាបហោះទៅ គឺយើងនឹងដឹងច្បាស់ថា មានរឿងអ្វីមិនស្រួលកើតមានឡើងនៅទីនោះមិនខាន។ បក្សីប្រភេទនេះ មានរបៀបដេកខុសពីគេឯង គឺវាដេកផ្ងារជើងទាំងពីរឡើងលើ ហាក់បីដូចជា យកជើងទ្រមេឃអីចឹង! ទើបជនជាតិឥណ្ឌា បានដាក់ឈ្មោះអោយមួយយ៉ាងចម្លែកដូចនេះឯង។

តំបន់នេះក៏មានក្រៀលស ប្រកបដោយរោម ស្លាបពណ៌សស្គុសយ៉ាងស្អាតអស្ចារ្យ។ នេះគឺជាបក្សីមួយប្រភេទ ដែលបានធ្វើដំណើរពី**តំបន់ស៊ីបេរី** មកស្នាក់នៅទីនេះក្នុងកំឡុងសិសិររដូវ ក្រោយពេលកើតកូនរួចវានាំគ្នាវិលត្រឡប់ទៅកាន់ស្រុកដើមរបស់ខ្លួនវិញ។

បច្ចុប្បន្ននេះ អាត្មាភាពកំពុងទាក់ទងជាមួយអ្នកបរិស្ថានវិទ្យា ដើម្បីធ្វើការស្រាវជ្រាវនូវដំណើរគោចររបស់ពួកវា ដោយសារឧបករណ៍វិទ្យុតូចមួយបិទជាប់ទៅលើខ្លួនរបស់វា។

រយៈពេលប៉ុន្មានឆ្នាំក្រោយពីសត្វក្រៀលមានវត្តមាន គឺប្រជាជននៅទីនេះមានចិត្តស្លូតបូតជាងមុន បន្ថយបាននូវការសម្លាប់សត្វ និងមានចិត្តស្រឡាញ់សត្វទាំងពួង។ នេះជាកុសលផល ដែលសត្វក្រៀលបាននាំមកអោយគេយ៉ាងពិតមែន។ ប្រហែលជាមកពីហេតុនេះ ទើបសាសនាមួយចំនួនបានធ្វើការគោរពបូជា ចំពោះសត្វក្រៀល ដូចគ្នានឹងគ្រូៗផងដែរ។

បើសិនជាមនុស្សម្នា នាំគ្នាយកចិត្តទុកដាក់ថែរក្សា សត្វបក្សីយ៉ាងកម្រទាំងនេះ គឺប្រាកដជាវានឹងមានការវិវឌ្ឍចម្រើនឡើង ហើយក៏នឹងនាំមកនូវសេចក្តីសុខសាន្ត ដល់មនុស្សយើងពុំខានឡើយ។

ធម្មជាតិពិតជាបានបង្កើតឡើងនូវទេសភាព ព្រមទាំងសត្វលោកទាំងឡាយយ៉ាងល្អប្រណីត ដែលយើងអាចនឹងយល់ឃើញច្បាស់ លុះត្រាណាយើងបានយកចិត្តទុកដាក់ និងរស់នៅយ៉ាងជិតដិតជាមួយនឹងធម្មជាតិ។ ការធ្វើដំណើរកំសាន្តមួយ ដែលត្រូវចំណាយប្រាក់ជាច្រើននោះ ក៏ពុំអាចផ្ដិតជាប់នៅក្នុងអារម្មណ៍របស់យើង ដូចជាការចំណាយពេលវេលាថែទាំពពួកបក្សីគួរជាទីស្រឡាញ់ ដែលអាចនាំមកអោយយើងនូវអនុស្សាវរីយ៍យ៉ាងរីករាយ និងបង្កើតឡើងនូវសេចក្តីមេត្តា ករុណា មុទិតា ឧបេក្ខា ក្នុងចិត្តរបស់យើងជាពុំខាន។

សត្វក្រៀលយ៉ាងស្អាតប្រណីតទាំងនេះ បាននាំអោយអាត្មាភាពមានសេចក្តីរីករាយក្នុងចិត្តឥតឧបមាឡើយ។ ពេលព្រឹកព្រលឹមស្រាងៗ មេឃនៅស្រអ័ព្ទដោយដំណាក់ទឹកសន្សើម អាត្មាភាពអង្គុយយ៉ាងស្ងៀមស្ងាត់នៅក្បែរពែងតែ រង់ចាំមើលហ្វូងសត្វក្រៀលហោះ ឆ្លងកាត់អាកាសវេហាឆ្ពោះទៅកាន់ជួរភ្នំព្រិលដែលបង្កប់ខ្លួនទៅក្នុងផ្សែងអ័ព្ទ អាត្មាភាពបានទទួលយកនូវអារម្មណ៍សុខសាន្តយ៉ាងចម្លែកម៉្លេះទេ នាពេលនោះ។ វាពិតជាទិដ្ឋភាពមួយយ៉ាងស្អាតអស្ចារ្យ ដែលខ្សែភាពយន្តទាំងឡាយពុំអាចឆ្លុះបញ្ចាំងឡើង

ដូចនេះឡើយ។ ម៉្លោះហើយ ពេលព្រះអាទិត្យអស្តង្គត ហ្វូងក្រៀលបាននាំគ្នាវិលត្រឡប់មកវិញទាំងអស់គ្នា។ ទិដ្ឋភាពពោរពេញដោយសេចក្តីសុខក្សេមក្សាន្តនៅទីនេះ បាននាំមកអោយជីវិតរស់នៅរបស់អាត្មាភាព ប្រកបដោយភាពកក់ក្តៅរីករាយយ៉ាងពន់ពេក។

# ស្ពានសេចក្ដីស្រឡាញ់

**ជនស្ទើរមរណៈ**

ក្រៅពីការនាំមកនូវភាពសប្បាយរីករាយដល់អាត្មាភាព សត្វក្រៀល ក៏បានជួយដល់អាត្មាភាព ក្នុងកិច្ចការជាកុសល ដែលមានប្រយោជន៍ដល់ សង្គមមនុស្សផងដែរ។

មានគ្រាមួយ ការសាងសង់ព្រះវិហារត្រូវបង្អាក់ ដោយសារខ្វះថវិកា ឆ្លៀតពេលទំនេរនេះ អាត្មាភាពបានទៅសួរសុខទុក្ខដល់ពួកក្រៀលទាំងអស់ រួចដាក់ឈ្មោះអោយពួកវា។ អាត្មាភាព បានចងចាំទីកន្លែងរបស់គូក្រៀល នីមួយៗ ហេតុនេះហើយ បានជាមនុស្សម្នាដាក់រហស្សនាមអោយអាត្មាភាព ជាវចនានុក្រមរស់អំពីសត្វក្រៀល។

ជារៀងរាល់ថ្ងៃ អាត្មាភាពបានចេញដំណើរគោចរនាពេលព្រឹកព្រលឹម ដោយយកតាមកែវយឺត ម៉ាស៊ីនថតរូប ព្រមទាំងចង្ហាន់សម្រាប់មួយថ្ងៃ ហើយនឹង វិលត្រឡប់មកវិញប្រមាណម៉ោង៦ល្ងាច អាត្មាភាពបានបោះ ជំហានមួយៗ ពិនិត្យមើលភាពស្រស់បំព្រងនៃធម្មជាតិ ព្រមទាំងយកចិត្ត ទុកដាក់មើលហ្វូងក្រៀល ពីចម្ងាយតម្រង់ម៉ាស៊ីនថតរង់ចាំថត នៅពេល ពួកវាលាតសន្ធឹងស្លាបរាំ។

ថ្ងៃមួយ អាត្មាភាពបានធ្វើដំណើរឆ្ពោះ ទៅភាគខាងកើតនៃ**លុម្ពិនីវ័ន្ត**

ស្រាប់តែ ជួបប្រទះនូវទិដ្ឋភាពមួយគួរអោយអាណោចអាធ័ម ព្រោះតែពេលនោះគឺជារដូវវស្សា ទឹកនៅលើ**ភ្នំហិមពាន្ត**បានហូរចុះមកជើងភ្នំ រួចហូរចាក់ចូលទៅក្នុងទន្លេយ៉ាងសន្ធឹក។ អាត្មាភាពមានការព្រួយចិត្តយ៉ាងខ្លាំង ពេលមើលឃើញស្ត្រី និងក្មេងៗកំពុងប្រថុយលុយទឹកឆ្លងស្ទឹងដ៏ជ្រៅ អាត្មាភាពមានក្តីអាណិតអាសូរយ៉ាងពន់ពេក ពេលនឹកឃើញថា ប្រជាជននៅលើដែនដីដ៏ពិសិដ្ឋនេះ នៅតែទទួលរងនូវទុក្ខវេទនាជាច្រើនបែបនេះ។ ពេលអាត្មាភាពសាកសួរ និងស្វែងយល់ថែមទៀតទើបបានដឹងថា ជារៀងរាល់ឆ្នាំ មនុស្សមួយចំនួនត្រូវបាត់បង់ជីវិតនៅក្នុងស្ទឹងនេះ។ នៅរដូវប្រាំងទឹកស្រក មនុស្សម្នាអាចឆ្លងកាត់ស្ទឹងយ៉ាងងាយស្រួល ប៉ុន្តែចូលដល់រដូវវស្សា គឺទឹកហូរគួចយ៉ាងខ្លាំង អ្នកដែលមានកម្លាំងខ្សោយអាចនឹងត្រូវលង់ទឹកយ៉ាងងាយគួរអោយអាណិតបំផុត គឺចំពោះគ្រួសារមានអ្នកជំងឺដែលត្រូវបញ្ជូនទៅព្យាបាលនៅឯទីក្រុង នៅពេលនោះហើយ គេពុំអាចនឹងឆ្លងកាត់ស្ទឹងបានឡើយ។ ដោយហេតុនេះហើយ បានជាអ្នកស្រុកនៅទីនេះតែងអោយឈ្មោះស្ទឹងនេះថា "**ស្ទឹងមរណៈ**"។

អាត្មាភាពមានចិត្តខ្លោចផ្សាយ៉ាងខ្លាំងនៅពេលឃើញ ស្ត្រីមានផ្ទៃពោះលុយទឹកឆ្លងស្ទឹងទាំងក្តីលំបាកវេទនា រីឯកុមារ និងនារីមួយចំនួនស្លៀកពាក់យ៉ាងស្អាត ក្រោយពេលបានឆ្លងស្ទឹងរួចហើយ ខោអាវក៏ត្រូវទទឹកជោកជាំអ្នកខ្លះរងារញ័រទទ្រើក គួរអោយអាណិតអាសូរក្រៃលែង។ យុវជនអាច

លុយទឹកដោយស្លៀកខោខ្លីខាងក្នុង ហើយស្លៀកខោវែងចូល នៅពេលគេបានឆ្លងស្ទឹងរួចរាល់ រីឯនារីភេទវិញគឺសម្លៀកបំពាក់ត្រូវទទឹក ហើយនៅតែបន្តទៅប្រកបការងារប្រចាំថ្ងៃរបស់គេ។

ថ្ងៃនោះ អាត្មាភាពលុបចោលកម្មវិធីទៅមើលសត្វក្រៀល រួចវិលត្រឡប់មកកាន់ព្រះវិហារវិញ។ រយៈពេលជាច្រើនថ្ងៃក្រោយមក អាត្មាភាពពុំអាចនឹងសិងយ៉ាងស្ងប់បានឡើយ គឺនៅពេលហៀបនឹងសិង រូបភាពទាំងឡាយនៅពេលនោះ បានលេចចេញមក ក្នុងអារម្មណ៍របស់អាត្មាភាពបណ្តាលអោយសិងពុំបានស្កប់ឡើយ។ អាត្មាភាពបានក្រោកឡើងពីសំណិងដើរចូលមកព្រះវិហារធំ ដើម្បីអុចធូបបួងសួង : សូមអោយព្រះអង្គប្រទានភាពងាយស្រួល សម្រាប់កសាងស្ពានមួយនៅតំបន់នេះ។

តាំងពីមុនមក អាត្មាភាពពុំដែលបានសន្យាអ្វីមួយដែលហួសពីសមត្ថភាពរបស់ខ្លួនឡើយ ព្រោះតែអាត្មាភាពមានការជឿជាក់ថា បើជ្រុលសន្យារួចហើយ ជាតិនេះធ្វើពុំបានសម្រេចទេនោះ ជាតិក្រោយត្រូវតែធ្វើបន្តទៀតជាពុំខាន។ ហេតុនេះហើយ បានជាអាត្មាភាពគ្រាន់តែលើកឡើងនូវបំណងប្រាថ្នារបស់ខ្លួនតែប៉ុណ្ណោះ ព្រមជាមួយនេះអាត្មាភាពក៏មានការខ្វល់ខ្វាយដោយពុំដឹងថាត្រូវធ្វើយ៉ាងដូចម្តេចឡើយ ក្នុងខណៈដែលថវិកាសម្រាប់សាងសង់ព្រះវិហារនៅមានការលំបាកនៅឡើយ។

ដោយទឹកចិត្តចង់ជួយដល់អ្នកស្រុកនៅទីនេះ ក្នុងស្ថានភាពគ្មានថវិកា

អាត្មាភាពអនុវត្តនូវសិល្បវិធីសម្ងាត់មួយ ដែលលោកគ្រូបានបង្រៀនពីមុន គឺអាត្មាភាពយកធូបទៀនមកអុចនៅមាត់ស្ទឹង រួចបួងសួងថា :

- អាត្មាភាពបានឃើញ អ្នកស្រុកនៅទីនេះ ជួបការលំបាកវេទនាយ៉ាងខ្លាំង ហេតុនេះហើយ អាត្មាភាពសូមបួងសួងដល់ទេវនាគម្ចាស់ទឹកម្ចាស់ដីបារមីនៅទីនេះ សូមអោយអាត្មាភាព បានជួបឱកាសដ៏ប្រសើរ សម្រាប់កសាងស្ពានមួយនៅទីនេះជូនប្រជាជនក្នុងពេលអាត្មាភាពស្នាក់នៅទីនេះ។

ពេលបួងសួងរួចហើយ អាត្មាភាពបានសូត្រមន្តគាថា រួចយកដៃទះទៅលើដីបីដង ដើម្បីសូមអោយព្រះធរណីធ្វើជាសាក្សី។

ក្រោយពេលវិលត្រឡប់មកព្រះវិហារវិញ អាត្មាភាពនឹកឃើញជានិច្ចនូវបញ្ហាសាងសង់ស្ពាន។ រយៈពេលបីសប្តាហ៍ក្រោយមក កូនសិស្សរបស់អាត្មាភាពមួយចំនួន ពីបស្ចិមប្រទេសមកទស្សនៈកិច្ចនៅ**លុម្ពិនីវ័ន្ត** និងមើលសត្វក្រៀល ក្រោយពេលពួកគេ បានឮអាត្មាភាពពោលអំពីបំណងចង់សាងសង់ស្ពាន គឺពួកគេមានការរំភើបចិត្តក្រៃលែង។

ភាគច្រើនពួកគេទាំងអស់គ្នាជាគ្រូបង្រៀន ពុំមែនជាអ្នកមានស្តុកស្តម្ភទេ ហេតុនេះមុនពេលវិលត្រឡប់ទៅកាន់ប្រទេសវិញ ពួកគេប្រមូលលុយគ្នាបានចំនួន៤២០ដុល្លាអាមេរិក រួចយកមកប្រគេនដល់អាត្មាភាព ជាដំបូងអាត្មាភាពស្មានថា នេះជាបច្ច័យសម្រាប់ព្រះវិហារ ប៉ុន្តែពួកគាត់បានជំរាប

ថា នេះគឺជាចំនួនប្រាក់ចូលរួមក្នុងការសាងសង់ស្ពាន ចាត់ទុកថាជាផ្ទាំងសិលាដំបូងគេបង្អស់ក្នុងការសាងសង់ស្ពានទៅចុះ។

អាត្មាភាពមានការរំភើបចិត្តក្រៃលែងដោយយល់ឃើញថា ភាពពិសិដ្ឋអស្ចារ្យបានកើតមានឡើងហើយ ។ បទពិសោធន៍ក្នុងជីវិតរបស់អាត្មាភាពបានដឹងយ៉ាងច្បាស់ថា បច្ច័យជាទក្ខិណាទានតាមសទ្ធាជ្រះថ្លានោះ តែងតែនាំមកនូវផលសម្រេចកិច្ចការទាំងពួងជាពុំខាន ផ្ទុយទៅវិញអ្នកដែលមានលុយច្រើន ប៉ុន្តែការបរិច្ចាគរបស់គេដោយសទ្ធាពុំជ្រះថ្លាទេ នោះផលសម្រេចនឹងមិនបានដូចបំណងឡើយ មកពីហេតុនេះហើយនៅពេលអាត្មាភាពទទួលបានប្រាក់មួយចំនួនតូច ដោយទឹកចិត្តជ្រះថ្លារបស់បងប្អូន អាត្មាភាពសម្រេចចិត្តចាប់ផ្តើមការសាងសង់តែម្តង។

ជាដំបូងអាត្មាភាពបានលើកយកការងារនេះទៅពិភាក្សាជាមួយរដ្ឋអំណាចមូលដ្ឋានមន្ត្រីមួយរូប គឺលោក **ផាតារ៉ាយ** មានសេចក្តីត្រេកអរយ៉ាងខ្លាំង ដោយចាត់ទុកថាជាព្រឹត្តិការណ៍សំខាន់ក្នុងស្រុកនេះ អាត្មាភាពក៏មានក្តីសប្បាយរីករាយ ដោយឃើញការងារនេះ មានភាពងាយស្រួលមួយចំនួន ។

ក្រោយអង្គប្រជុំសមាជិកទាំងអស់បានឈានទៅដល់ការឯកភាពគ្នាយ៉ាងល្អប្រសើរ រដ្ឋអំណាចមូលដ្ឋានក៏រៀបចំពិធីលៀងភោជនាហារអបអរសាទរការងារនេះដែរ។ យើងទាំងអស់គ្នា បានយល់ព្រមចែករំលែក

ថវិកាសាងសង់ស្ពានជាពីរភាគ រដ្ឋអំណាចមូលដ្ឋាន ចេញថវិកាពាក់កណ្ដាល រីឯអាត្មាភាពវិញ គឺបំពេញថវិកាដែលនៅខ្វះពាក់កណ្ដាល ប៉ុន្តែប្រការនេះគ្រាន់តែយល់ព្រមសំដីប៉ុណ្ណោះ ពុំទាន់មានការចុះហត្ថលេខាលើលិខិតស្នាមអ្វីឡើយ។

អាត្មាភាពមានទម្លាប់មួយ គឺនៅពេលចាប់ផ្តើមកិច្ចការអ្វីមួយយ៉ាងសំខាន់ អាត្មាភាពតែងតែធ្វើចិត្តអោយស្ងប់ដោយសមាធិកម្មដ្ឋាន ដើម្បីរំពៃមើលថា ដំណើរការនៃកិច្ចការទាំងនោះ មានភាពលំបាកឬងាយស្រួលយ៉ាងដូចម្ដេច?

ក្រោយរយៈពេលធ្វើសមាធិជាច្រើនលើក អាត្មាភាពបានឃើញថា កិច្ចសហប្រតិបត្តិការនេះជួបនូវការលំបាកជាច្រើន ហាក់បីដូចជាពុំអាចសម្រេចបានឡើយ។ អាត្មាភាពមានការងឿងឆ្ងល់យ៉ាងខ្លាំង ព្រោះតែកិច្ចការនៅពេលដំបូងមើលទៅហាក់បីដូចជា មានភាពងាយស្រួលច្រើនដោយមានការគាំទ្រពីរដ្ឋអំណាចនៅមជ្ឈិម និងរដ្ឋអំណាចមូលដ្ឋាន ហេតុអ្វីក៏អាត្មាភាពបានមើលឃើញការលំបាកទៅវិញ? អាត្មាភាពសម្រេចចិត្តសាកល្បងម្តងទៀត ដោយចេញទៅសូត្រមន្ត និងគង់សមាធិនៅក្បែរសសរសិលាចារឹកនៃ **ស្តេចអសោក**នៅទីប្រសូតរបស់ព្រះសម្មាសម្ពុទ្ធ ពេលនោះអាត្មាភាពក៏បានឃើញនូវការលំបាកដដែល។

អាត្មាភាព មានការបារម្ភយ៉ាងខ្លាំងទើប សូមអោយរដ្ឋអំណាចមូលដ្ឋាន

រៀបចំអង្គប្រជុំមួយ ពេលនោះអាត្មាភាពពោលចំពោះតំណាងស្រុក និងសង្កាត់ថា អាត្មាភាពនៅតែរក្សាពាក្យសន្យាកសាងស្ពាន ប៉ុន្តែសូមលើកឡើងនូវវិធីពីរជាក់ស្តែង ដូចតទៅ :

- ទីមួយ គឺរដ្ឋអំណាចមជ្ឈិម និងមូលដ្ឋានចេញមុខកសាងស្ពានរីឯអាត្មាភាពវិញ គឺចូលរួមថវិកាចំនួនពាក់កណ្តាល ។
- ទីពីរ គឺអាត្មាភាពទទួលការកសាងដោយខ្លួនឯង ដោយមិនធ្វើតាមវិធីសហការ ម្ខាងចេញថវិកាពាក់កណ្តាលឡើយ ។

សំណូមពរនេះត្រូវជួបនឹងការប្រឆាំងយ៉ាងខ្លាំង សូម្បីតែមន្ត្រីដែលធ្លាប់គោរពចំពោះអាត្មាភាព ក៏បែរជាប្រឆាំងព្រមទាំងចោទថា អាត្មាភាពមិនរក្សាពាក្យសន្យា។ អាត្មាភាពបានបញ្ជាក់សាជាថ្មីទៀតថា : អាត្មាភាពនៅតែរក្សាពាក្យសន្យាថា នឹងចូលរួមថវិកាពាក់កណ្តាលនៃចំនួនសរុបដោយមានលក្ខខណ្ឌមួយ គឺពួកគេត្រូវធ្វើក្រដាសស្នាមសាងសង់អោយបានចប់សព្វគ្រប់ ក្នុងរយៈពេលណាមួយយ៉ាងច្បាស់លាស់។ ពួកមន្ត្រីរដ្ឋអំណាចពុំបានយល់ព្រមនឹងសំណើនេះ ខ្លះក៏តិះដៀលដល់អាត្មាភាពដែរ អង្គប្រជុំត្រូវបានដំណើរការក្នុងស្ថានភាពតានតឹង ហើយក៏ត្រូវបញ្ចប់ក្នុងសភាពអាក់អន់ចិត្តយ៉ាងខ្លាំង ពីសំណាក់អ្នកមូលដ្ឋាន ចំពោះការម៉ឹងម៉ាត់ដាច់ខាតរបស់អាត្មាភាព។

ពីរបីខែកន្លងទៅ ដោយគ្មានសកម្មភាពអ្វីសោះពីរដ្ឋអំណាចមូលដ្ឋាន

អាត្មាភាពសម្រេចចិត្ត ទៅសុំច្បាប់អនុញ្ញាតសាងសង់ស្ពានដោយខ្លួនឯង។ ពេលនោះហើយអាត្មាភាព ត្រូវជួបប្រទះការលំបាកសព្វបែបយ៉ាងអំពីរបៀបរបបរដ្ឋបាល អាត្មាភាពចង់ធ្វើតាមពាក្យប្រៀនប្រដៅរបស់ចាស់ទុំ គឺធ្វើតាមលទ្ធភាពជាក់ស្តែង អាត្មាភាពមានគំនិតកសាងគ្រឹះស្ពានយ៉ាងសាមញ្ញរួចក្រាលដើមឫស្សីនៅលើផ្ទៃស្ពានអោយគេដើរឆ្លងកាត់តែប៉ុណ្ណោះ ប៉ុន្តែការងារនេះ ក៏ត្រូវទាមទារអោយមានគម្រោងប្លង់សាងសង់ដែលគូរដោយវិស្វករខាងស្ពានផ្តល់ ថ្នាក់មហាវិទ្យាល័យនៅនេប៉ាល់ដែរ ម្យ៉ាងទៀតលិខិតស្នាមត្រូវបានចុះហត្ថលេខាពីថ្នាក់មជ្ឈិម គឺក្រសួងគមនាគមន៍ដឹកជញ្ជូនរហូតដល់ថ្នាក់មូលដ្ឋាន អាត្មាភាពនៅតែព្យាយាមសម្រេចរាល់តម្រូវការខាងលិខិតស្នាម ប៉ុន្តែពេលសម្រេចមួយហើយ ក៏ត្រូវលេចចេញនូវសំណូមពរផ្សេងៗជាបន្តបន្ទាប់។ ការងារទើបតែចាប់ផ្តើមស្រាប់ជួបប្រទះការលំបាកគ្រប់បែបយ៉ាង បណ្តាលអោយអាត្មាភាពមានការនឿយណាយយ៉ាងខ្លាំង ពេលខ្លះមានគំនិត ចង់ប្រគល់ប្រាក់ចំនួន៤២០ដុល្លារអាមេរិកទៅអោយម្ចាស់ដើម ព្រមទាំងសូមអភ័យទោសចំពោះពួកគាត់។

ចុងក្រោយ អាត្មាភាពក៏បានបញ្ចប់យ៉ាងសព្វគ្រប់នូវតម្រូវការទាំងឡាយខាងរដ្ឋបាល ដោយសារមានសប្បុរសជនមួយចំនួនជួយយ៉ាងស្ងៀមស្ងាត់។ ចប់ពីរឿងនេះហើយ បែរជាជួបនឹងបញ្ហាដីធ្លីទៅវិញ។ ស្ទឹងគឺជាកម្មសិទ្ធិរបស់រដ្ឋ រីឯដីនៅក្បាលស្ពានទាំងសង្ខាង ស្ថិតនៅក្នុងកម្មសិទ្ធិរបស់ម្ចាស់ដី

ទាំងបួននាក់ ពួកគេក៏នាំគ្នាបោះសំឡេងថា ក្រោយពេលស្ពានត្រូវបានសាងសង់រួចហើយ គឺពួកគេនឹងប្រមូលយកលុយអ្នកដែលដើរឆ្លងកាត់ស្ពាននេះ។ រឿងដូចនេះ ធ្លាប់កើតមានឡើងនៅកន្លែងខ្លះរួចហើយ អាត្មាភាពត្រៀមខ្លួនចរចាជាមួយពួកគេ បើសិនជាមិនបានសម្រេចទេនោះ ក៏ត្រូវតែត្រៀមលុយទិញដីដែរ។ បញ្ហានេះត្រូវដោះស្រាយក្នុងរយៈពេលអស់ពីរខែ អាត្មាភាពបានបញ្ចុះបញ្ចូលអោយប្រធានភូមិទាំង៧០នាក់ នៅតំបន់ជុំវិញមានការឯកភាពមិនយកប្រាក់ពីប្រជាជន ព្រមទាំងបានសម្រេចនូវការបញ្ចុះបញ្ចូលអោយម្ចាស់ដីកុំយកប្រាក់អ្នកដើរឆ្លងស្ពាន ការងារនេះត្រូវចំណាយពេលវេលាយ៉ាងច្រើន តែបានសម្រេចផលដូចបំណង។

ការសប្បាយចិត្តពុំទាន់បានពិតប្រាកដផង ស្រាប់តែត្រូវប្រឈមមុខនឹងរឿងផ្ទៃក្នុងទៅវិញ គឺក្រុមប្រឹក្សានៃព្រះវិហារ ក៏មានយោបល់ប្រឆាំងយ៉ាងតានតឹងដែរ អាត្មាភាពមានទស្សនៈមួយថាការកសាងស្ពាននោះគឺជាកិច្ចការចាំបាច់ជាបន្ទាន់ដើម្បីជួយដល់ជីវិតរបស់មនុស្ស រីឯការសាងសង់ព្រះវិហារវិញ គឺអាចពន្យារបន្តដល់ឆ្នាំក្រោយក៏បានដែរ។ យោបល់របស់អាត្មាភាពពុំបានទទួលស្គាល់គ្រប់ៗគ្នាឡើយ សមាជិកខ្លះចាត់ទុកថា អាត្មាភាពឱបក្រសោបការងារ និងស្រឡាញ់កេរ្តិ៍ឈ្មោះ ការងារសាងសង់ព្រះវិហារនៅស្មុគស្មាញច្រើន បែរជាទៅទទួលបន្ថែមការសាងសង់ស្ពានមួយទៀត។ អ្នកខ្លះបានផ្សាយដំណឹងថា អាត្មាភាពយកសម្ភារៈសាងសង់ព្រះវិហារទៅសាង

សង់ស្ថានទេវិញ រឿងនេះបណ្តាលអោយអាត្មាភាពមានការពិបាកចិត្តណាស់ ប៉ុន្តែដោយសារការប្តេជ្ញាចិត្តជួយដល់សត្វលោកហើយ អាត្មាភាព មិនត្រូវប្រកាន់យកពាក្យចចាមអារ៉ាមទាំងនោះទេ គឺចេះតែធ្វើអោយសំរេចនូវការងារចាំបាច់ជួយដល់មនុស្សតែប៉ុណ្ណោះ។

ឆ្លងតាមហេតុការណ៍ទាំងអស់នេះ អាត្មាភាពបានយល់យ៉ាងច្បាស់ថា នៅលើពិភពលោកនេះ ការធ្វើអំពើល្អនោះពុំមែនជាការងាយស្រួលណាស់ឡើយ ជួនកាលត្រូវឆ្លងកាត់ឧបសគ្គជាច្រើន ទើបបានសម្រេចគោលដៅនៅចុងក្រោយ។ ក្នុងពេលនោះ ការប្រកបអំពើអកុសលបែរទៅជាការងាយណាស់ទេវិញ សូម្បីតែ ខ្វះភាពម្ចាស់ការត្រួតពិនិត្យពាក្យសំដីដែលប៉ះពាល់ដល់អ្នកដទៃនោះ ក៏ជាអំពើបាបមួយជាស្រេចទៅហើយ។ ហេតុនេះហើយយើងអាចពោលថា បានកើតជាមនុស្សគឺជាភ័ព្វសំណាងមួយហើយ ប៉ុន្តែដើម្បីក្លាយទៅជាមនុស្សប្រកបដោយព្រហ្មវិហារធម៌ លះបង់ខ្លួនដើម្បីអានិសង្ស នោះមិនមែនជាការងាយស្រួលឡើយ។ ដោយឃើញ ការងារចេះតែជួបការលំបាកជាលំដាប់ អាត្មាភាពចេញទៅកន្លែងប្រសូតនៃព្រះអង្គ ធ្វើការថ្វាយបង្គំបួងសួងម្តងទៀត សំណាង និងបច្ច័យល្អៗនាំអោយអាត្មាភាពដោះស្រាយការងារជាបន្តបន្ទាប់ដែរ។

នៅពេលព្រឹកព្រលឹមមួយយ៉ាងស្រស់បំព្រង អ្នកចែកសំបុត្របានប្រគល់ជូនដល់អាត្មាភាព នូវសារលិខិតធានាមួយរបស់ពុទ្ធបរិស័ទយ៉ាងជិត

ជិតនៅអាមេរិក ក្នុងសារលិខិតនោះបានសរសេរថា : "សូមថ្វាយបង្គំព្រះតេជគុណ ខ្ញុំព្រះករុណាឮថា ព្រះតេជគុណមានបំណងសាងសង់ស្ពានមួយ សម្រាប់អោយប្រជាជនក្រីក្រនៅ**លុម្ពិនីវ័ន្ត** ហេតុនេះគ្រួសារខ្ញុំព្រះករុណា សូមចូលរួមបច្ច័យកសាងស្ពានទាំងមូលទុកជាបុណ្យកុសល"។

នេះពិតជាដំណឹងរីករាយ ហួសពីការស្មាន។ អាត្មាភាពទុកសំបុត្រចូលក្នុងថង់យាម រួចបោះជំហានមួយៗដើរជុំវិញព្រះវិហារប្រកបដោយក្តីរំភើបចិត្តហាក់បីដូចជាត្រូវឆ្នោតអីចឹង ប៉ុន្តែអាត្មាភាពពុំទាន់ឆ្លើយតបភ្លាមៗឡើយ នៅរង់ចាំមួយរយៈទៀតទើបជូនដំណឹងអោយបងប្អូនវិញ។ មិនយូរប៉ុន្មានឡើយ អាត្មាភាពក៏ទទួលបានសំបុត្រពីគ្រួសារមួយ នៅកាណាដាសំបុត្រនេះត្រូវបានផ្ញើចូលទៅក្នុងប្រអប់សំបុត្ររបស់អាត្មាភាព នៅឯមន្ទីរប្រៃសណីយ៍**ផាយរ៉ាហារ៉ា** ក្នុងសំបុត្រនោះបានសរសេរថា : "ខ្ញុំព្រះករុណាបានឮបងប្អូន ដែលវិលត្រឡប់មកពីការទស្សនៈកិច្ចនៅ**លុម្ពិនីវ័ន្ត** និយាយអំពីរឿងសាងសង់ស្ពាន ហេតុនេះគ្រួសាររបស់ខ្ញុំព្រះកុរណា ចង់ចូលរួមបច្ច័យសាងសង់ទាំងអស់ ដើម្បីវេរអានិសង្សនេះទៅជូន លោកឪពុកអ្នកម្តាយដែលបានចែកឋានទៅហើយ"។

ឥឡូវនេះអាត្មាភាព មានចំនួនប្រាក់នៅក្នុងដៃមិនត្រឹមតែគ្រប់នឹងសង់ស្ពានមួយប៉ុណ្ណោះទេ គឺសង់បានទៅដល់ស្ពានពីរឯណោះ! លើកនេះអាត្មាភាពពុំអាចទប់ក្តីរីករាយ សម្រាប់តែម្នាក់បានឯងទៀតទេ គឺត្រូវតែកោះ

ប្រជុំបងប្អូន ដើម្បីបង្ហាញសំបុត្រទាំងពីរនេះ មនុស្សម្នានាំគ្នាត្រេកអរខ្លះ បន្លឺសំឡេងទាំងក្ដីរំភើបឆ្ងល់ថា : "ពុទ្ធោអើយ ហេតុការណ៍អីក៏មហាអស្ចារ្យ ម្ល៉េះទេហ្ន៎!" បងប្អូនស្នើអោយអាត្មាភាព ទាក់ទងជាមួយនឹងសប្បុរសជន ដើម្បីគេផ្ញើប្រាក់មកអោយបានឆាប់។

ចំពោះភាពសំណាងយ៉ាងចម្លែកអស្ចារ្យនេះ អាត្មាភាពចង់តែរង់ចាំបន្ត មើលថា វានឹងមានអ្វីកើតឡើងតទៅទៀតឬទេ។ ដោយពុំឃើញអាត្មាភាព ឆ្លើយតបសំបុត្រ បានជាគ្រួសារទាំងពីរនៅអាមេរិក និងកាណាដាទូរស័ព្ទ មកអាត្មាភាពដើម្បីសំណូមពរ សុំលេខគណនីរបស់អាត្មាភាពនៅក្នុងធនាគារ សម្រាប់គេផ្ញើលុយចូល ប៉ុន្តែអាត្មាភាពឆ្លើយតបថា កុំអាលសិន ចាំអាត្មាភាព គិតមួយរយៈសិនណា៎។

រយៈពេលបីសប្ដាហ៍ក្រោយមក អាត្មាភាពបានទទួលសំបុត្រពីរទៀត ពីគ្រួសារដែលអាត្មាភាពទើបស្គាល់គេនៅបារាំង និងអង់គ្លេស ក្នុងសំបុត្រ ទាំងពីរនេះគេក៏បាន សុំស្នើអោយបានចេញបច្ច័យសាងសង់ស្ពានទាំងមូល ពេលនេះហើយ អាត្មាភាពមាននៅក្នុងដៃចំនួនប្រាក់ សំរាប់សង់ស្ពានដល់ ទៅបួនឯណោះ! មនុស្សម្នានាំគ្នាភ្ញាក់ផ្អើលក្រៃលែង ចំពោះហេតុការណ៍ ចម្លែកកើតមានជាបន្តបន្ទាប់។ បងប្អូនខ្លះ បានសំណូពរអាត្មាភាពទទួល យកប្រាក់ ពីគ្រួសារទាំងបួនតែម្ដងដោយគេមានទស្សនៈថា សាងសង់ស្ពាន មួយហើយ បន្តទៅសាងសង់ស្ពានមួយផ្សេងៗទៀត ចុងក្រោយបើសិនជា

ប្រាក់នៅសល់ គឺយកទៅប្រើសម្រាប់ការសាងសង់ព្រះវិហារវិញ។ ពេលនេះហើយ ទើបអាត្មាភាពបានយល់ច្បាស់ថា អ្នកនៅជុំវិញខ្លួនអាត្មាភាពខ្លះនៅមានចិត្តលោភលន់ ព្រមទាំងជំរុញអាត្មាភាពអោយចេះលួចទៀតផង។

ការប្រព្រឹត្តទៅនៃហេតុការណ៍ទាំងពួង នាំអោយអាត្មាភាពមានការជឿជាក់ទាំងស្រុងថា ព្រះតថាគត ព្រះពោធិសត្វ ទេវនាគ និងទេវតាការពារព្រះធម៌ទាំងឡាយ ព្រមទាំងបារមីថែរក្សាទឹកដីនៅទីនេះ បានបញ្ចេញមហិទ្ធិឫទ្ធិគាំទ្រដល់អាត្មាភាព ហេតុនេះហើយ អាត្មាភាពមានបំណងចែករំលែកកុសលផលបុណ្យដ៏ធំធេងនេះ ទៅអោយមនុស្សម្នាជាច្រើននាក់ ដោយមិនប្រមូលផ្តុំទៅលើ គ្រួសារមួយចំនួនតូចនេះឡើយ ម្យ៉ាងទៀត អាត្មាភាពមានការជឿជាក់ថា សមិទ្ធផលដ៏ធំមួយត្រូវការប្រមូលផ្តុំនូវការចូលរួមតាមសទ្ធាជ្រះថ្លាពីមនុស្សជាច្រើននាក់ ទើបសមិទ្ធផលនេះមានជោគជ័យ និងបានស្ថិតស្ថេរយូរអង្វែង។ ដោយយល់ឃើញដូចនេះ បានជាអាត្មាភាពសរសេរសំបុត្រឆ្លើយតបគ្រួសារទាំងបួន ដោយមានខ្លឹមសារដូចតទៅ :

- អាត្មាភាពសូមចម្រើនពរអរគុណដល់ញោមទាំងអស់ ដែលមានសទ្ធាជ្រះថ្លា ប៉ុន្តែការងារនេះជាអានិសង្សដ៏ធំធេង ហេតុនេះអាត្មាភាពសំណូមពរចែករំលែកទៅអោយមនុស្សជាច្រើននាក់ សូមអោយគ្រួសារនីមួយៗចូលរួមបច្ច័យកសាងស្ពានច្រើនបំផុត គឺ១០០១ ដុល្លារប៉ុណ្ណោះ។

តាមប្រពៃណីរបស់អ្នកស្រុក គេនាំគ្នាជឿជាក់ថា បច្ច័យដែលមានចំនួនលើសពីលេខគត់ នឹងត្រូវបានទទួលភ័ព្វសំណាង និងកុសលផលជាពុំខាន។ គ្រួសារទាំងពីរនៅកាណាដា និងអាមេរិកបានយល់ព្រមតាមសំណើ គ្រួសារមួយបានប្រគេនបច្ច័យ១០០០ដុល្លារ គ្រួសារមួយទៀតបានប្រគេនបច្ច័យ១០០១ដុល្លារ រីឯគ្រួសារទាំងពីរឯទៀតគឺមានការអាក់អន់ចិត្តយ៉ាងខ្លាំង គេបានសរសេរសំបុត្របន្ទោសថា អាត្មាភាពមានចិត្តចង្អៀតមិនផ្ដល់ឱកាសអោយគេធ្វើបុណ្យ ដោយកំហឹងនេះពួកគេក៏នាំគ្នាពុំចូលបច្ច័យសាងសង់ស្ពានឡើយ។ អាត្មាភាពសុខចិត្តទទួលយកពាក្យបន្ទោសនេះ ហើយធ្វើចិត្តអោយស្ងប់ ដើម្បីដំណើរការតាមគម្រោងរបស់ខ្លួន។

ក្រៅពីនេះ ញាតិញោមជាច្រើននៅទ្វីបអឺរ៉ុប និងអាមេរិកក៏បាននាំគ្នាផ្ញើបច្ច័យមកចូលរួមតាមសទ្ធារបស់ពួកគេ ប៉ុន្តែចំនួនប្រាក់នោះមិនបានលើកពីកម្រិតកំណត់ឡើយ។

## ការសាងសង់ស្ពានទៀតណាមនៃសេចក្ដីស្រឡាញ់

ចំពោះចំនួនទឹកប្រាក់ជាបច្ច័យ សម្រាប់ការសាងសង់ស្ពាននោះ អាត្មាភាពអាចនឹងមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ជួលវិស្វករ និងកម្មករ ប៉ុន្តែអាត្មាភាពក៏មានទស្សនៈដោយឡែករបស់ខ្លួនដែរ ពីមុនមកអាត្មាភាពតែងតែអនុវត្តនូវគោលការណ៍ភាគីទាំងពីរសហការគ្នា ដើម្បីអ្នកទទួលគ្មានការអឹមអៀនថាខ្លួនជាអ្នកសុំ រីឯអ្នកជូនវិញ ក៏គ្មានការក្រេងរអែងចិត្តថាជាអ្នកប្រទានដែរ។

អាត្មាភាពបានសំណូមពរអោយមន្ត្រីមូលដ្ឋាន ជួយបំផុសប្រជាជននៅទីនេះចូលរួមកម្លាំងអោយបានកុះករ អាត្មាភាពបានសន្យាផ្ដល់ជូនសម្ភារៈទាំងអស់ រីឯពួកគាត់គឺត្រូវចេញកម្លាំងធ្វើបែបនេះ ដើម្បីអ្នកស្រុកមើលឃើញថាស្នាដៃនេះពិតជារបស់ខ្លួន ហើយមានគំនិតការពារស្ពាននេះជាមិនខាន។

ក្រុមរបស់អាត្មាភាពបានធ្វើដំណើរពីភូមិមួយទៅភូមិមួយ ដើម្បីចាត់តាំងការជួបជុំគ្នា ទៅដល់ទីណាក៏អាត្មាភាពបានទទួលការស្វាគមន៍យ៉ាងអឹកធឹក និងការគាំទ្រយ៉ាងសកម្មពីរដ្ឋអំណាចមូលដ្ឋាន ព្រមទាំងប្រជាជននៅទីនោះ។ មកដល់ទីណាក៏ គេសន្យាផ្គត់ផ្គង់ដើមឫស្សីដើម្បីរៀបគ្រឿង និងកម្លាំងកម្មករដើម្បីសាងសង់។ លោក **ចាន់តាវ៉ាម** គឺជាអ្នកសកម្មបំផុត

គាត់ក៏ជាប្រធានសហភូមិ ពេលជួបគាត់ម្ដងៗ គាត់តែងតែអង្វរអញ្ជើញអាត្មាភាពទៅឆាន់បាយ នៅផ្ទះរបស់គាត់។

ពិធីបុណ្យបុកគ្រឹះ ចាប់ផ្ដើមការសាងសង់ស្ថាន ត្រូវបានចូលរួមយ៉ាងកុះករគ្រប់ជាន់ថ្នាក់ពីមជ្ឈិមរហូតមូលដ្ឋាន សូម្បីតែ តំណាងនានារបស់ព្រះវិហារទាំងឡាយនៅ**លុម្ពិនីវ័ន្ត** ក៏បានចូលរួមយ៉ាងរីករាយ និងផ្ដល់ជូនថវិកាមួយចំនួនផងដែរ ទោះបីយ៉ាងនេះក្ដី នៅតែមានតំណាងនៃប្រទេសមួយចំនួន មកផ្លាស់ប្ដូរយោបល់ផ្ទាល់ជាមួយអាត្មាភាព ដោយបង្ហាញចេញនូវអាការពុំទុកចិត្តថា ការងារនេះអាចនឹងសម្រេចបានដូចបំណងឡើយ។ ពិតមែននៅពេលចាប់ផ្ដើមសាងសង់ ដើមឫស្សីក៏គ្មាន កម្មករក៏ពុំឃើញ! ច្បាស់មែនហើយ ពាក្យសំដី និងការអនុវត្តតែងតែខុសគ្នាយ៉ាងឆ្ងាយបែបនេះ។ អាត្មាភាពព្រួយចិត្តយ៉ាងខ្លាំង ព្រមទាំងទទួលអារម្មណ៍ត្រូវចាញ់បោកគេ និងអស់ក្ដីសង្ឃឹម។

នេះពិតជាការសាកល្បងថ្មីមួយទៀត ព្រោះពេលនោះ អាត្មាភាពចង់ព្រលែងចោលការងារសាងសង់តែម្ដង ប៉ុន្តែអាត្មាភាពខំទប់អារម្មណ៍ និងប្ដេជ្ញាចិត្ត បន្តការងារដែលបានលើកឡើងរួចហើយ។ អ្នកស្រុកនៅទីនេះលើកសំណូមពរអោយគេមានប្រាក់ខែ បើសិនជាចង់អោយគេចូលរួម។ អាត្មាភាពខិតខំសម្របសម្រួល ចុងក្រោយ ពួកគេយល់ព្រមទទួលប្រាក់ខែពាក់កណ្ដាល មានអ្នកខ្លះក៏បានគិតគូរឡើងវិញ រួចស្ម័គចិត្តចូលរួមកម្លាំង

ទុកជាការសាងកុសលកម្ម។ ការងារសាងសង់ស្ពាន ពិតជាលំបាកមែន! រដូវទឹកជំនន់ជិតមកដល់ហើយ ក្រុមរបស់អាត្មាភាពត្រូវតែបង្វែរចរន្តទឹកអោយហូរទៅតាមទិសផ្សេង ដោយប្រឹងប្រែងលីសែងដុំថ្មធំៗ មកធ្វើជាទំនប់ស្ទឹង ការងារដឹកជញ្ជូននេះជួបប្រទះការលំបាកជាច្រើន ព្រោះដីភក់ជោកជាំ ពុំទាន់មានផ្លូវស្រួលបួលនៅឡើយ។ បន្ទាប់មកគេត្រូវជីកចុះទៅបាតស្ទឹងជម្រៅបួនម៉ែត្រដើម្បីគេចាក់គ្រឹះស្ពាន ពេលនោះទឹកចេះតែហូរចាក់ចូលមកកន្លែងជីក គេត្រូវប្រមូលកម្លាំងដងទឹកចាក់ចេញជាបន្តបន្ទាប់ ការងារនេះត្រូវធ្វើដោយកម្លាំងមនុស្សទាំងអស់ គ្មានម៉ាស៊ីនអ្វីជួយឡើយ។ យើងត្រូវជួលរទេះគោដឹកជញ្ជូនស៊ីម៉ង់ត៍ និងដែកថែបនៅលើកំណាត់ផ្លូវតិចជាងពីរគីឡូម៉ែត្រ តែត្រូវចំណាយពេលមួយម៉ោងកន្លះ ទើបអាចដឹកមកដល់កន្លែង។

នៅពេលឃើញមេឃងងឹតម្ដងៗ អាត្មាភាពមានការព្រួយបារម្ភយ៉ាងខ្លាំង ដៃទាំងពីរចេះតែលើកគ្រវី បណ្ដេញពពកនៅលើមេឃអោយរសាត់ទៅកន្លែងផ្សេង ដោយមើលឃើញនូវទឹកមុខព្រួយបារម្ភព្រមទាំងកាយវិការភិតភ័យរបស់អាត្មាភាព មនុស្សម្នា ពុំអាចទប់សំណើចរបស់ខ្លួនបានឡើយ គេនាំគ្នាសើចយ៉ាងលាន់ឮ ហាក់បីដូចជាការសប្បាយកំប្លែងមួយ សម្រាប់បន្ធូរភាពតានតឹងនៃការងារ។ អនុស្សាវរីយ៍មួយដែលពុំអាចបំភ្លេចបាន គឺពេលយប់អុចទៀនធ្វើការរហូតដល់ម៉ោងមួយ ឬម៉ោងពីរភ្លឺ ធ្វើការបណ្ដើរ

បួងសួងបណ្ដើរសូមអោយមេឃកុំភ្លៀង ព្រោះទឹកភ្លៀងបណ្ដាលអោយទឹកជន់លិចលង់បំផ្លាញអ្វីៗទាំងអស់ជាពុំខាន។ មានការលើកទឹកចិត្ត និងបន្ធូរបរិយាកាសការងារដល់នោះ គឺប្អូនៗកុមារក៏ចូលរួមយ៉ាងសកម្មដោយសែងថ្ម យកទឹក លីឥដ្ឋមកអោយអ្នករៀបចំ មានលោកយាយខ្លះបានយកផ្លែឈើព្រមទាំងនំចំណីដែលពួកគាត់ធ្វើផ្ទាល់ខ្លួន យកមកអោយបងប្អូន ដោយដាក់ចូលទៅក្នុងជម្រកលើមាត់ស្ទឹង ដែលក្រុមអាត្មាភាពសាងសង់សម្រាប់បងប្អូនឈប់សម្រាក និងទទួលទានអាហារខ្លះ។

ក្រោយសាងសង់ជើងស្ពានទាំងពីររួចហើយ ព្រះវិហាររបស់ប្រទេសមួយចំនួនក៏បានមកជួយជ្រោមជ្រែងដោយវិធីបញ្ជូនមេជាង វិស្វករមកជួយពីរបីថ្ងៃដែរ អ្នកខ្លះក៏ចូលជាបច្ច័យតិចតួច។ ទាំងអស់នេះ គឺសុទ្ធតែជាអនុស្សាវរីយ៍ដែលពុំអាចបំភ្លេចបាន ក្នុងអំឡុងពេលលំបាកសព្វបែបយ៉ាងនោះ។

បងប្អូនវៀតណាមមួយចំនួន ដែលមកធ្វើបុណ្យកុសលនៅឯព្រះវិហារនាពេលនោះ ក៏បានចូលរួមការសាងសង់ស្ពាននេះដែរ ប៉ុន្តែនៅពេលជួបប្រទះនូវការនឿយហត់យ៉ាងខ្លាំង បងប្អូនញាតិញោមនេះបែរទៅជាបន្ទោសអាត្មាភាពទៅវិញ ពួកគាត់បានចាត់ទុកថា ការងារនេះគ្មានពាក់ព័ន្ធអ្វីដល់ព្រះវិហារវៀតណាមសោះឡើយ អ្នកខ្លះក៏ខំស្វែងយល់ថា តើអាត្មាភាពមានផលចំណេញអ្វីពីការងារនេះឬទេ?។

ការពិត អាត្មាភាពគ្រាន់តែមានទស្សនៈមួយយ៉ាងសាមញ្ញ គឺតំបន់ដ៏

ពិសិដ្ឋនេះ ជាទីចាប់បដិសន្ធិនៃមហាព្រះបរមគ្រូជាព្រះសក្យមុនីសម្មាសម្ពុទ្ធ នៃមនុស្សលោក ហេតុនេះហើយការងារទាំងឡាយ ដែលអាត្មាភាពបានរួមចំណែកនៅទីនេះ គឺដើម្បីនឹករលឹកដល់ព្រះគុណូបការៈដ៏មហិមានៃព្រះអង្គតែប៉ុណ្ណោះ។ ម្យ៉ាងទៀត នៅពេលឃើញមនុស្សស្ថិតក្នុងស្ថានភាពលំបាកវេទនា អាត្មាភាពតែងតែជួយទំនុកបម្រុងក្នុងលក្ខខណ្ឌ ដែលអាចមានលទ្ធភាពជួយ ដោយមិនប្រកាន់ជាតិសាសន៍ថា អ្នកនោះជាជនជាតិឥណ្ឌា នេប៉ាល់ ឬវៀតណាម... ឡើយ។

អាត្មាភាពអោយគេសាងសង់ស្ពាន ដោយមានប្រវែងទទឹងមួយម៉ែត្រកន្លះ សម្រាប់អ្នកថ្មើរជើង កង់ ត្រីចក្រយានយន្តតែប៉ុណ្ណោះ ថ្វីត្បិតតែគ្រឹះស្ពានបានចាក់បេតុងយ៉ាងមាំ ដែលអាចទ្រទ្រង់រថយន្តឆ្លងកាត់ក៏ដោយ។ អាត្មាភាពគ្មានបំណងសាងសង់ផ្ទៃស្ពានអោយបានធំទូលាយ ព្រោះតែមិនចង់អោយយានយន្តមានទំហំធំៗឆ្លងកាត់ ដែលអាចបណ្ដាលអោយប៉ះពាល់ និងខូចខាតដល់ស្ពានដូចជាត្រាក់ទ័រ ឡានដឹកទំនិញជាដើម។

ជាការស្មានមិនដល់ លោកប្រធានសហភូមិ **ចាន់តារ៉ាម** ជាអ្នកមានត្រាក់ទ័រតែមួយគត់ក្នុងចំណោមជាងមួយពាន់គ្រួសារនៅក្នុងភូមិ គាត់បានសូកលុយពួកវិស្វករ ដើម្បីសាងសង់ស្ពានអោយបានធំទូលាយ សម្រាប់ត្រាក់ទ័ររបស់គាត់ឆ្លងកាត់ អាត្មាភាពបានដឹងរឿងនេះយ៉ាងចៃដន្យ រួចក៏ឃាត់ឃាំងអំពីរឿងនេះ។ ជាបន្តបន្ទាប់មក ប្រធានភូមិនានាក៏មកជួបអាត្មាភាពដើម្បី

សុំអោយពង្រីកស្ពានអោយធំ គេក៏បានសន្យាចូលរួមទាំងថវិកា និងកម្លាំងមនុស្ស ប៉ុន្តែអាត្មាភាពពុំព្រមចំពោះសំណូមពរនេះឡើយ។ បញ្ហានេះបង្កឡើងនូវភាពតានតឹង និងឧបសគ្គជាច្រើនរារាំងដល់ការងាររបស់អាត្មាភាព បណ្តាលអោយឧបការីជនជាតិភូមារបស់អាត្មាភាព គឺលោក **អ៊ូធន់តារា** (បច្ចុប្បន្នជាបណ្ឌិតសាស្ត្រាចារ្យ ព្រមទាំងជាអនុប្រធានគណៈកម្មាការនៃ**ព្រះវិហារភូមា**) វិលត្រឡប់មកព្រះវិហារវិញ ទាំងទឹកមុខសោកសៅជោកជាំដោយទឹកភ្នែក ដើម្បីសុំប្រាក់ពីអាត្មាភាពយកទៅទិញគ្រាប់រំសេវ អាត្មាភាពមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយក៏បានសួរថា : លោកទិញរំសេវដើម្បីអ្វី? លោកក៏ឆ្លើយទាំងអួលអាក់ក្នុងចិត្តថា : ទ្រាំលែងកើតហើយ ហេតុអ្វីក៏យើងខំជួយគេយ៉ាងលំបាក តែពួកគេបែរទៅជារកវិធីបំផ្លិចបំផ្លាញរហូតអីចឹង! អាត្មាភាពមិនអាចទប់នឹងសំណើចរបស់ខ្លួនឯងបានឡើយ រួចហើយក៏ខំលួងលោមលោក ប៉ុន្តែទឹកមុខលោកនៅតែមានភាពម៉ឺងម៉ាត់ អាត្មាភាពសន្យាជាមួយលោកថា : សូមអោយមានពេលគិតឡើងវិញសិន អាត្មាភាពក៏បានបន្ថែមទៀតថា រង់ចាំដល់ថ្ងៃសម្ពោធស្ពាន រួចដាក់មីនអោយផ្ទុះក៏មិនយឺតពេលដែរ!។

ក្រុមអាត្មាភាពជួបប្រទះឧបសគ្គជាបន្តបន្ទាប់ រហូតដល់ត្រូវបង្អាក់ការងារសាងសង់ស្ពានមួយរយៈ។ ពីរសប្តាហ៍ក្រោយមក ដោយឃើញអាត្មាភាពមិនព្រមចុះចាញ់ ថែមទាំងមានគម្រោងយកដើមឫស្សីមកក្រាលលើស្ពាន បានជា

ពួកអ្នកស្រុកបញ្ជូនតំណាងមកជួបអាត្មាភាព ដើម្បីសុំបន្តការងារដែលកំពុងបោះបង់ចោលនោះ។

រយៈពេលបីខែក្រោយមក ស្ពានត្រូវបានសាងសង់រួចជាស្ថាពរ សូម្បីតែអាត្មាភាពក៏ពុំអាចជឿជាក់ថា ស្ពានសាងសង់បានរហ័សដូចនេះឡើយ។ នៅពេលពិភាក្សាអំពីពិធីសម្ពោធមន្ត្រីមួយចំនួន បានស្នើសុំអោយមានការរៀបចំយ៉ាងអធិកអធម និងអញ្ជើញមន្ត្រីសំខាន់ៗ ដែលពួកគេស្គាល់មកកាត់ខ្សែបូរ។ អាត្មាភាពពុំសប្បាយចិត្តឡើយ ព្រោះនៅពេលសាងសង់យ៉ាងលំបាកវេទនានោះ គ្មានឃើញអ្នកណាមកទេ ពេលនេះមានមនុស្សមកច្រើននាក់ដើម្បីចែករំលែកស្នាដៃ ក្នុងចិត្តរបស់អាត្មាភាពវិញ គឺចង់តែអញ្ជើញអ្នកតំណាងកម្មករមានទាំងជាងកំបោរ ជាងឈើ និងវិស្វករមកកាត់ខ្សែបូរតែប៉ុណ្ណោះ ជាការថៃជន្ម អាត្មាភាពអញ្ជើញបានអ្នកសមរម្យសម្រាប់ពិធីនេះ។

ថ្ងៃមួយ អាត្មាភាពមានការងារត្រូវតែឡើងទៅទីក្រុង**កដ្ឋមណ្ឌ** ហើយក៏បានជួបលោក **ក្លូតអាំប្រសីយានី** ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅ**នេប៉ាល់** ជាមួយនឹងភរិយារបស់លោក ដែលទើបតែមកកាន់តំណែងនៅទីនេះបានពីរបីខែប៉ុណ្ណោះ លោកគឺជាមន្ត្រីដ៏សំខាន់មួយរូបនៃក្រសួងការបរទេសបារាំងជាពិសេសលោកបានយល់ច្បាស់អំពីប្រទេសវៀតណាម លោក និងលោកស្រីមានកូនប្រសារស្រីជាជនជាតិវៀតណាម។ ថ្វីត្បិតតែ ទើបជួបគ្នាជាលើកដំបូង តែដោយសារមានទំនាក់ទំនងយ៉ាងជិតដិត ទើបកិច្ចពិភាក្សាគ្នាមាន

ភាពស្និទ្ធស្នាលរីករាយយ៉ាងឆាប់រហ័ស ឆ្លៀតឱកាសនេះ អាត្មាភាពអញ្ជើញលោកទៅទស្សនៈកិច្ចនៅ**លុម្ពិនីវ័ន្ត** ព្រមទាំងធ្វើជាអធិបតីនៅក្នុងពិធីសម្ពោធស្ពានតែម្តង លោកក៏បានយល់ព្រមដោយក្តីរីករាយ។

អាត្មាភាពពុំបានជូនដំណឹងនេះទៅអោយមូលដ្ឋានទេ ដោយស្គាល់ច្បាស់នូវអត្តចរិតម៉ឺងម៉ាត់របស់អាត្មាភាព រដ្ឋអំណាចមូលដ្ឋានក៏យល់ថាមានតែអាត្មាភាពម្នាក់ឯងទេដែលកាត់ខ្សែបូ ហេតុនេះពួកគេពុំបានត្រៀមរៀបចំអ្វីឡើយ ប្រការនេះស្របតាមបំណងរបស់អាត្មាភាព គឺចង់អោយលោកឯកអគ្គរដ្ឋទូតនៃប្រទេសអឺរ៉ុប មកដល់ទីនេះជាលើកដំបូងបានឃើញនូវភាពជាក់ស្តែងដោយគ្មានការក្លែងបន្លំឡើយ ថ្ងៃនោះលោកឯកអគ្គរដ្ឋទូតព្រមទាំងភរិយាត្រូវដើរឆ្លងភក់យ៉ាងលំបាក ទើបមកដល់ស្ពាន លោកព្រមទាំងភរិយាមានការរំភើបចិត្តក្រៃលែង ពួកគាត់ដើរទៅដើរមកមើលស្ពានយ៉ាងផ្ចិតផ្ចង់ ហើយក៏បានស្ញើចសរសើរព្រមទាំងសន្យាថានឹងមានកម្មវិធីរួមចំណែកកែប្រែជីវភាពរបស់ប្រជាជននៅទីនេះ។

ក្នុងឱកាសដ៏មហោឡារិកនេះ អ្នកស្រុកទាំងអស់គ្នាបានប្រមូលផ្តុំរាំច្រៀងយ៉ាងសប្បាយ ភូមិនីមួយៗសុទ្ធតែមានអំណោយប្រគេនដល់អាត្មាភាព ទោះបីអំណោយតិចតួចក្តី វាក៏បង្ហាញនូវទឹកចិត្តស្រឡាញ់យ៉ាងស្មោះសររបស់គេដែរ។ ភូមិខ្លះប្រគេនចេកមួយស្ទង ភូមិខ្លះប្រគេនផលានុផលពិសេសរបស់ខ្លួន ភូមិឯទៀតយកទាំងមាន់ ត្រីល្អៗដែលគេមានមកប្រគេន ទោះបីពួកគេក៏

ដឹងច្បាស់ថា អាត្មាភាពឆាន់តែធញ្ញជាតិ និងបន្លែផ្លែឈើតែប៉ុណ្ណោះ ជាពិសេសប្រធានភូមិម្នាក់ទៀត អង្វរសុំអោយអាត្មាភាពទទួលយកគោមួយ និងពពែមួយ ដើម្បីវាផ្ដល់ទឹកដោះអោយអាត្មាភាពឆាន់ អាត្មាភាពប្រឹងប្រែង រកវិធីបដិសេធយ៉ាងលំបាក ដើម្បីកុំអោយគាត់ខឹងដល់អាត្មាភាពវត្ថុទានមួយ ដែលគួរអោយស្រឡាញ់ គឺសម្លៀកបំពាក់កាត់តាមបែបនេប៉ាល់ ឬឥណ្ឌា ដែលយាយៗបានកាត់ដេរដោយផ្ទាល់ដៃយ៉ាងផ្ចិតផ្ចង់។

អ្នកដែលមានក្ដីរីករាយជាងគេបំផុត គឺលោក **អ៊ូធន់តារា** អាត្មាភាព មានការរំភើបចិត្តណាស់ នៅពេលឃើញលោកសប្បាយចិត្ត គាត់មានទឹកមុខ រីករាយក្នុងចំណោមមនុស្សម្នាជុំវិញ ក្នុងនោះក៏មានអ្នកបង្កការលំបាកដល់ លោក ប៉ុន្តែពេលនេះគេក៏បានផ្លាស់ប្ដូរអាកប្បកិរិយា ហើយថែមទាំងយក អំណោយមកជូនដល់គាត់ទៀតផង ដោយឃើញស្ថានភាពហ្នឹងហើយ បានជា អាត្មាភាពដើរមកជិតលោក រួចសួរយ៉ាងស្ងាត់ថា : "តើលោកត្រូវការប្រាក់ សម្រាប់ទិញគ្រាប់រំសេវទៀតទេ?" លោក**អ៊ូធន់តារា** បញ្ចេញសំណើច យ៉ាងស្រស់រួចពោលថា : "ទូលព្រះតេជគុណ ខ្ញុំព្រះករុណាដឹងថា ខ្លួនខុស ហើយ ព្រោះនៅពេលនោះ ខ្ញុំព្រះករុណាភ្លេចនូវសង្ឃដីការបស់ព្រះតេជគុណ គឺជាការប្រកបអំពើជាកុសលទាំងឡាយ មិនមែនជាការងារទៀយ"។ គួរ អោយរំភើបចិត្តបំផុត គឺសេចក្ដីថ្លែងនូវចំណាប់អារម្មណ៍របស់អ្នកតំណាង ប្រជាជននៅទីនេះ គាត់បានថ្លែងអំណរគុណដល់ប្រជាជាតិវៀតណាម ថ្លែង

អំណរគុណដល់អង្គការពុទ្ធសាសនា និងអាត្មាភាពដែលបានសាងសង់ស្ពាន ដើម្បីជួយសង្គ្រោះដល់ជីវិតមនុស្សជាច្រើន។

ចាប់ពីពេលនោះមក អោយតែមានជនជាតិវៀតណាមណាមួយ ចូលមកដល់ភូមិទាំងនោះ គឺពួកគេត្រូវបានស្វាគមន៍ និងគោរពរាប់អានពីសំណាក់អ្នកស្រុក។

ស្ពាននេះត្រូវបានដាក់ឈ្មោះជា "**ស្ពានវៀតណាមនៃសេចក្តីស្រឡាញ់**" រីឯដងស្ទឹងកាលពីមុនមានឈ្មោះ "**ដងស្ទឹងមរណៈ**" បច្ចុប្បន្នត្រូវបានដូរទៅជា "**ដងស្ទឹងសុខសាន្ត**" ទៅវិញ។

អាត្មាភាពបានបំពេញលិខិត ប្រគល់ជូនរដ្ឋាភិបាលនេប៉ាល់ ក្នុងនោះរដ្ឋអំណាចមូលដ្ឋាន ជាអ្នកទទួលយកដោយមានការទទួលខុសត្រូវ និងថែទាំស្ពាននេះ។

ក្រោយមកបងប្អូនវៀតណាម ដែលបានធ្វើធម្មយាត្រាមកដល់ទឹកដីរបស់ព្រះអង្គ គេនាំគ្នាទៅមើលស្ពាន ដោយឃើញស្ពាននេះស្ថិតនៅលើវាលស្រែយ៉ាងល្ហល្ហេវ ពេលមេឃក្តៅខ្លាំង ឬពេលភ្លៀងធ្លាក់ ប្រជាជននៅទីនេះពុំអាចមានអ្វីផ្សេងជាជម្រក ទើបបងប្អូនស្នើអោយសង់បន្ថែមសាលាសំណាក់ទាំងសង្ខាងស្ពាន បច្ចុប្បន្នសាលាសំណាក់ទាំងពីរ ត្រូវបានសាងសង់រួចហើយ។

សរុបចំនួនទឹកប្រាក់សាងសង់ស្ពាន ដោយគិតទាំងចំណាយ សម្រាប់

ពិធីសម្ពោធគឺមានចំនួនជិត ៣៥.០០០ដុល្លារអាមេរិក ជាការចម្លែកមួយដែរ ចំនួនទឹកប្រាក់ដែលនៅសល់គឺ ៩៨.០០០ដុល្លារអាមេរិក មិត្តភក្តិមួយចំនួនបានស្នើដល់អាត្មាភាព សូមអោយបញ្ចូលចំនួនប្រាក់នៅសល់នេះទៅក្នុងខ្ទង់ថវិកាសម្រាប់សាងសង់ព្រះវិហារ ប៉ុន្តែអាត្មាភាពមិនព្រមជាដាច់ខាតព្រោះនេះ គឺជាប្រាក់ដែលគេបានចូលជាបច្ច័យសាងសង់ស្ពាន ប្រាក់ដែលនៅសល់នេះត្រូវតែប្រគល់ទៅអោយគេវិញ អ្នកខ្លះក៏សូមអោយអាត្មាភាពសរសេរសំបុត្រទៅអោយម្ចាស់ប្រាក់នេះ ដើម្បីស្នើអោយគេយល់ព្រមបញ្ចូលប្រាក់នេះទៅក្នុងថវិកាសាងសង់ព្រះវិហារ តែអាត្មាភាពក៏មិនយល់ព្រមវិធីនេះដែរ។ ទោះបីយ៉ាងណាក៏ដោយ អាត្មាភាពមិនចង់ប៉ះពាល់ដល់ចិត្តសទ្ធារបស់ពុទ្ធបរិស័ទឡើយ បច្ច័យសម្រាប់សាងសង់ស្ពានដែលគេបានចូលរួមនេះត្រូវតែប្រគល់សងម្ចាស់វិញ នៅពេលដែលប្រាក់នៅសេសសល់ មិនអាចយកទៅប្រើប្រាស់ សម្រាប់គោលដៅផ្សេងៗតាមចិត្តបានឡើយ។ ហេតុនេះហើយអាត្មាភាពត្រូវតែចំណាយពេលវេលា និងប្រាក់យ៉ាងច្រើន សម្រាប់បង្វែរប្រាក់ទៅសងម្ចាស់ដើមវិញ ពេលនោះហើយអាត្មាភាព ក៏ត្រូវទទួលនូវពាក្យបន្ទោសខ្លះៗថា អាត្មាភាពមិនត្រូវការប្រាក់ ដែលគេរកបានទាំងការលំបាក!។

ចាប់ពីពេលនោះមក ជារៀងរាល់ថ្ងៃ ប្រជាជនបានធ្វើដំណើរយ៉ាងងាយស្រួលឆ្លងកាត់ស្ពានស៊ីម៉ង់ត៍ដែលមានផ្ទៃរាបស្មើ ដោយគ្មានការព្រួយបារម្ភអំពីគ្រោះថ្នាក់ ដោយទឹកក្ដួចក្នុងស្ទឹងនេះទៀតឡើយ ជួនកាលនៅ

ពេលទំនេរ អាត្មាភាពដើរមកកន្លែងដែលពីមុនធ្លាប់អុចធូបបួងសួងនៅទីនោះ ដើម្បីសូមអោយបានសម្រេចនូវការសាងសង់ស្ពានមួយ ពេលនេះស្ពានក៏មានរូបរាងយ៉ាងពិតប្រាកដនៅចំពោះមុខអាត្មាភាពហើយ។ អាត្មាភាពទទួលបាននូវសុភមង្គលដ៏ធំធេង នោះគឺជារៀងរាល់សប្តាហ៍ ការប្រជុំលក់ដូរត្រូវធ្វើឡើងនៅថ្ងៃច័ន្ទ និងថ្ងៃសៅរ៍ អាត្មាភាពរំពៃមើលចរន្តមនុស្សទៅមកលក់ដូរយ៉ាងណែនណាន់តាន់តាប់ ជាពិសេស នៅពេលឃើញមនុស្សចាស់ទ្រុឌទ្រោម ឬអ្នកជំងឺឆ្លងកាត់ស្ពាន អាត្មាភាពទទួលអារម្មណ៍មួយយ៉ាងរំភើបដែលពុំអាចនឹងបរិយាយបានឡើយ ប្រការនេះបានបញ្ជាក់នូវបទពិសោធន៍មួយ គឺពេលយើងសម្រេចបាននូវអំពើជាកុសលណាមួយ យើងហ្នឹងហើយជាអ្នកទទួលបាននូវផលានិសង្សជាដំបូងបង្អស់ ព្រមទាំងសេចក្តីសុខដ៏ធំធេងផងដែរ។

ដោយឆ្លងកាត់ការលំបាកច្រើនបែបយ៉ាង ជាចុងក្រោយអាត្មាភាពក៏បានសម្រេចនូវប្រាថ្នារបស់ខ្លួនទាំងនេះហើយ ជាអនុស្សាវរីយ៍ដ៏ល្អផូរផង់ក្នុងជីវិតរបស់អាត្មាភាព។

❀❀❀❀❀❀

# មន្ទីរពេទ្យនៃសេចក្ដីស្រឡាញ់

មន្ត្រីមួយរូប ដែលមានសេចក្ដីរំភើបចិត្តចំពោះការកសាងស្ពាននេះ គឺលោករដ្ឋមន្ត្រីក្រសួងសុខាភិបាលនេប៉ាល់។ លោកព្រមទាំងភរិយា ចេះតែទទូចអញ្ជើញអាត្មាភាពទទួលទានអាហារជាមួយពួកគាត់ ដោយបដិសេធច្រើនដងមកហើយ បានជាអាត្មាភាពយល់ព្រមទទួលទានអាហារពេលព្រឹកម្ដងទៅចុះ។ ក្នុងពិធីជួបសំណេះសំណាល លោកបានពោលយ៉ាងស្មោះចំពោះអាត្មាភាពដូចតទៅ :

- ប្ដី ប្រពន្ធខ្ញុំព្រះករុណា មានចិត្តរំភើបចំពោះគុណបុណ្យរបស់ព្រះតេជគុណ។ ព្រះតេជគុណបានឈានមុខ ក្នុងការនិមន្តមកទីនេះ ហើយបានបើកឡើងនូវទំព័រប្រវត្តិសាស្ត្រថ្មីនូវការអភិវឌ្ឍ**លុម្ពិនីវ័ន្ត** មិនត្រឹមតែប៉ុណ្ណោះទេ ព្រះតេជគុណនៅបានកសាងស្ពាន សម្រាប់ជួយដល់ប្រជាជន។ យើងខ្ញុំសូមក្រាបថ្វាយបង្គំ ព្រមទាំងដឹងគុណចំពោះព្រះតេជគុណជាអនេកប្បការ។

អាត្មាភាពបានពោលទៅកាន់ពួកគេថា :

- នេះជាទង្វើផុសចេញពីទឹកចិត្តស្មោះសររបស់អាត្មាភាព លោក និងលោកស្រីមិនចាំបាច់ថ្លែងអំណរគុណអ្វីទេ ប៉ុន្តែអាត្មាភាពមានសំណូមពរមួយ ដោយតួនាទីជារដ្ឋមន្ត្រីក្រសួងសុខាភិបាល សូម

លោកមេត្តាស្វែង រកវិធីអំពាវនាវអោយមានការកសាងមន្ទីរពេទ្យមួយសម្រាប់ប្រជាជននៅទីនេះ ព្រោះពួកគេត្រូវការវាជាចាំបាច់ណាំ។

លោករដ្ឋមន្ត្រី បានបញ្ចេញនូវអាការស្ទាក់ស្ទើរ :

- សូមក្រាបថ្វាយបង្គំព្រះតេជគុណ សភាពការណ៍សេដ្ឋកិច្ចនៃប្រទេស **នេប៉ាល់**នាពេលបច្ចុប្បន្ននេះ មានការលំបាកយ៉ាងខ្លាំង ហេតុនេះការស្នើសុំថវិកា ពុំមែនជាការងាយស្រួលទេព្រះអង្គ!។

អាត្មាភាពនៅតែបញ្ជាក់ថា លោកអាចនឹងធ្វើទៅបាន ហើយកិច្ចការនេះពុំអាចនឹងខានបានឡើយ។ លោកព្រមទាំងភរិយាមានការរួញរា បន្ទាប់មកលោករដ្ឋមន្ត្រី បានពោលមកកាន់អាត្មាភាពថា :

- អ៊ីចឹងក៏បានព្រះតេជគុណ សូមព្រះអង្គបួងសួងជូន ព្រះពុទ្ធពរមួយផង ដល់ខ្ញុំព្រះករុណាផង។

អាត្មាភាពមានការសប្បាយចិត្ត ដោយពោលថា :

- អាត្មាភាពបួងសួង សូមអោយមានជោគជ័យដល់លោកមិនត្រឹមតែម្តងទេ គឺដល់ទៅមួយពាន់ដងណាំលោក!។

រយៈពេលពីរបីសប្តាហ៍ក្រោយមក ពេលដែលអាត្មាភាពកំពុងស្នាក់នៅឯទីក្រុងឡុងដ៍ ស្រាប់តែអាត្មាភាពទទួលបានទូរស័ព្ទពីលោករដ្ឋមន្ត្រី ក្នុងនោះលោកបានពោលទាំងក្តីរីករាយដូចតទៅ :

- ក្រាបថ្វាយបង្គំព្រះតេជគុណ ខ្ញុំព្រះករុណាមានដំណឹងល្អ ប្រគេនព្រះអង្គ ។

អាត្មាភាពសួរថា :

- ដំណឹងអ្វីទៅលោករដ្ឋមន្ត្រី?

លោកបានឆ្លើយតបថា :

- ដោយស្តាប់តាមការណែនាំរបស់ព្រះតេជគុណ ខ្ញុំព្រះករុណាបានលើកសំណូមពរកសាងមន្ទីរពេទ្យមួយនៅលើតំបន់ជិតស្ពាន ហើយសំណើនេះត្រូវបានអនុម័តដោយលោកនាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ហើយណាំព្រះតេជគុណ។

នេះពិតជាដំណឹងល្អមែន អាត្មាភាពបានស្នើអោយលោកដំណើរការជាបន្ទាន់ ចំពោះគម្រោងការរបស់លោកមកទល់នឹងបច្ចុប្បន្ននេះ មន្ទីរពេទ្យបានសម្ពោធ និងដំណើរការរួចហើយ។

ពិតជាអស្ចារ្យមែន អំពើកុសលយ៉ាងតូចមួយ ក៏អាចនាំមកនូវកុសលផលដ៏ធំធេងជាបន្តបន្ទាប់ផងដែរ។

ᨁᨁᨁᨂᨂᨂ

# មនុស្សគ្រប់រូបធ្វើអំពើល្អ

ថ្នាក់ដឹកនាំអង្គការពុទ្ធសាសនាពិភពលោក ព្រមទាំងមន្ត្រីរដ្ឋាភិបាល **នេប៉ាល់**ពីមជ្ឈិមរហូតដល់មូលដ្ឋាន សុទ្ធសឹងតែមានការរំជួលចិត្ត ចំពោះកិច្ចការទាំងឡាយ ដែលក្រុមរបស់អាត្មាភាពបានសម្រេចនៅលើតំបន់នៃ**លុម្ពិនីវ័ន្ត**នេះ។ ពិសេស ព្រឹត្តិការណ៍កសាងស្ពាននោះ បានក្លាយទៅជាគំរូផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយវាបានក្លាយទៅជាចលភាពមួយសម្រាប់មនុស្សប្រឡងប្រណាំង ប្រកបដោយកុសលកម្មគ្រប់ៗគ្នា។

មនុស្សរស់នៅក្នុងតំបន់នេះ តែងមានការបែងចែងវណ្ណៈ ប៉ុន្តែក្រោយពេលអាត្មាភាពកសាងស្ពានរួចហើយ គេក៏បានយកព្រឹត្តិការណ៍នេះ ធ្វើជាមេរៀនសម្រាប់អប់រំកូនចៅរបស់គេដែរ។ តាមទស្សនៈរបស់គេ ជនជាតិវៀតណាមម្នាក់ ដែលមកស្នាក់នៅលើទឹកដីរបស់អ្នកដទៃ ប៉ុន្តែមានចិត្តល្អកសាងកុសលផល សម្រាប់អោយពួកគេនៅទីនេះ ពួកគេក៏ត្រូវមានភារកិច្ចចំពោះភូមិផងរបស់ខ្លួនដែរ។ កាលពីមុនវណ្ណៈនីមួយៗ តែងធ្វើការទំនាក់ទំនងក្នុងមជ្ឈដ្ឋានវណ្ណៈរបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែហេតុការណ៍នេះក៏បានញ៉ាំងអោយពួកគេបង្ខិតមកជិតនឹងគ្នា។ សង្គមមនុស្សក៏មានភាពល្អប្រសើរ នៅពេលដែលមនុស្សគ្រប់រូបមានស្មារតីជួយគ្នាទៅវិញទៅមក ។

កិច្ចការទាំងឡាយ ដែលអាត្មាភាពបានធ្វើរួចមកហើយ មិនត្រឹមតែនាំ

មកនូវកិត្តិនាមសម្រាប់ប្រទេស**វៀតណាម**ប៉ុណ្ណោះទេ គឺសហគមន៍ពុទ្ធសាសនាទាំងមូល ក៏បានទទួលនូវកេរ្តិ៍ឈ្មោះដ៏ប្រសើរផងដែរ។ ប្រជាជនក្នុងតំបន់ (ភាគច្រើនកាន់សាសនាហិណ្ឌូ) កាលពីមុនមកតែងតែ ធ្វើការទិតៀនថា អង្គការពុទ្ធសាសនារបស់ប្រទេសមួយចំនួនមកទីនេះ ដណ្តើមយកដីដើម្បីសាងសង់វត្តអារាមតែប៉ុណ្ណោះ។ ការកសាងស្ពានបណ្តាលអោយអ្នកទាំងឡាយមានការរំជួលចិត្ត និងធ្វើអោយមានការផ្លាស់ប្តូរនូវទស្សនៈវិស័យរបស់គេ ការទិតៀនចំពោះសហគមន៍ពុទ្ធសាសនា ក៏ត្រូវថយចុះយ៉ាងខ្លាំងផងដែរ។

ការពិតប៉ុន្មានឆ្នាំដំបូង ប្រទេសនានាបាននាំគ្នាកសាងព្រះវិហាររបស់ខ្លួនអោយបានសម្រេចសិន ទើបមានពេលវេលាសម្រាប់គិតដល់កិច្ចការផ្សេងៗទៀតដូចជា ការជួយដល់អ្នកស្រុកជាដើម។ ការដើរឈានមុខក្នុងកិច្ចការសង្គមរបស់អាត្មាភាព បាននាំអោយប្រទេសមួយចំនួនចូលរួមយ៉ាងរហ័សរហួនដែរ។ ឧទាហរណ៍ដូចជា ព្រះវិហារកូរ៉េ តែងតែចែកជូនអង្ករក្នុងពិធីបុណ្យធំៗ ឬក្រុមវេជ្ជបណ្ឌិតបានមកដល់**លុម្ពិនីវ័ន្ត** ដើម្បីពិនិត្យជំងឺជូនប្រជាជនក្រីក្រដោយឥតគិតថ្លៃ។ ព្រះវិហារផ្សេងៗ ក៏បានទិញត្រីចក្រយានយន្តជូនប្រជាជនក្រីក្រសម្រាប់ធ្វើជារបររកស៊ីចិញ្ចឹមជីវិត។ ព្រះវិហារខ្លះក៏បានរៀបចំកម្មវិធីស្តីអំពីបរិស្ថាន និងបានផ្តល់អាហារូបករណ៍ជូនដល់សិស្សពូកែនៃគ្រួសារក្រីក្រ។ ដោយយល់ឃើញថា ទឹកនៅទីនេះគ្មានអនាម័យ បណ្តាលអោយប្រជាជនខ្លះរងជំងឺ អាត្មាភាពក៏រៀបចំការស្រាវជ្រាវប្រភពទឹកស្អាត បំផុស

ប្រជាជនជីកអណ្តូងប្រើប្រាស់ទឹកស្អាត។ អាត្មាភាពក៏មានកម្មវិធីផ្តល់ពូជដំណាំអោយប្រជាជនក្រីក្រ ដើម្បីគេអាចដាំដុះសម្រាប់ការចិញ្ចឹមជីវិត។ កម្មវិធីទាំងឡាយរបស់អាត្មាភាព ពុំទាមទារនូវថវិកាច្រើនឡើយ តែត្រូវការបំផុតគឺទឹកចិត្ត និងការព្យាយាមតាមដានថែទាំដល់ពួកគេប៉ុណ្ណោះ។

ថ្វីត្បិត អាត្មាភាពតែងតែជួយដល់មនុស្សគ្រប់ពេលពិតមែន តែអាត្មាភាពបានប្រកាន់យកទស្សនៈមួយ គឺជួយអំពីវិធីសាស្ត្រមុខជំនាញដើម្បីគេខិតខំធ្វើដោយខ្លួនឯង។ អាត្មាភាពចៀសវាងការផ្តល់ជាទឹកប្រាក់ ពីព្រោះនៅពេលដែលយើងពុំមានលទ្ធភាព ផ្តល់ទឹកប្រាក់ដល់គេបន្តទៅទៀត គឺពេលនោះហើយ គេនឹងអាចមានការអាក់អន់ចិត្តជាពុំខាន។ ឧបមាដូចជាក្រុមគ្រួសារមួយ មានសមាជិកពុំព្រមរកការងារធ្វើ បើសិនជាយើងផ្តល់ប្រាក់ចំនួនពីរបីរយដុល្លារ ដើម្បីជួយដល់គេជារៀងរាល់ខែ នៅពេលយើងពុំមានលទ្ធភាពផ្តល់បន្តទៅទៀត គឺពេលនោះគេច្បាស់ជាមានការសៅហ្មងក្នុងចិត្តជាពុំខាន។ ព្រះអង្គធ្លាប់មានពុទ្ធដីកាថា : "មេត្តាត្រូវមានបញ្ញា"។

ហេតុនេះហើយ បានជាអាត្មាភាពតែងតែបដិសេធនូវសំណូមពរជួយឧបត្ថម្ភណាមួយ ដែលពុំសមហេតុសមផល។ មានពេលមួយ អាត្មាភាពទើបតែវិលត្រឡប់មកពីការបង្រៀននៅឯប្រទេសអឺរ៉ុប ថ្ងៃបន្ទាប់មកនោះមានក្រុមប្រធានភូមិដល់ទៅជិត២០នាក់ ដែលតំណាងអោយភូមិនានាក្នុងស្រុកបានយកអំណោយគ្រប់ៗគ្នាមកប្រគេនអាត្មាភាព អាត្មាភាពមានក្តីរីករាយ

ដោយគិតក្នុងចិត្តថា អ្នកស្រុកមានមនោសញ្ចេតនាជ្រាលជ្រៅ ចំពោះអាត្មាភាពអីម្ល៉េះទេ។ ក្រោយពេលសួរសុខទុក្ខទៅមករួចហើយ អ្នកទាំងអស់បានបន្លឺឡើងនូវសំឡេងប្រកបដោយក្តីក្រែងរអែងថា : "ព្រះតេជគុណបានធ្វើបុណ្យសូមអោយធ្វើអោយចប់សព្វគ្រប់ផង គឺសូមអោយព្រះតេជគុណកសាងផ្លូវចម្ងាយពីរគីឡូម៉ែត្រពីស្ពានរហូតដល់ថ្នល់ធំ។ ពួកគេបានបន្ថែមទៀតថាបើសិនជាព្រះតេជគុណដឹកនាំការងារនេះ គឺរដ្ឋអំណាចមូលដ្ឋានច្បាស់ជាសហការជាពុំខាន"។

ដោយយល់ឃើញថា ពួកគេមានចិត្តពឹងផ្អែកទៅលើអាត្មាភាព បានជាអាត្មាភាពធ្វើពុតជាខឹងសម្បាដោយទះគូរួចពោលថា : "អីចឹងអស់លោកមកប្រើអាត្មាភាពអោយបម្រើអស់លោកទេតើ សូមជំរាបអស់លោកថាអាត្មាភាពជាជនជាតិវៀតណាម តែពុំទាន់បានជួយអ្វីដល់ប្រទេសខ្លួននៅឡើយអាត្មាភាពបានខំជួយកសាងស្ពានមួយរួចហើយ ឥឡូវនេះដល់ទៅផ្លូវថ្នល់ទៀតឬ? នេះមិនមែនជាការងារទេណា៎!"។

ដោយឃើញអាត្មាភាពមានការអាក់អន់ចិត្ត បានជាពួកគេដកថយចេញយ៉ាងស្ងៀមស្ងាត់។ រយៈពេលដប់ថ្ងៃក្រោយមក ពួកគេមួយចំនួនបានមកជួបអាត្មាភាពដោយយកមកជាមួយនូវវត្ថុទានខ្លះ ហើយគេក៏បានពោលថា :

- ថ្វាយបង្គំព្រះតេជគុណ យើងខ្ញុំព្រះករុណាមកទីនេះ ដើម្បីសូមព្រះតេជគុណអភ័យទោសចំពោះការរំខានដល់ព្រះអង្គ។ ការពិត

ទៅថ្ងៃនោះក្រោយពេលបងប្អូនវិលត្រឡប់ទៅវិញ គឺមានការខ្មាស់អៀន និងបានពិភាក្សាឯកភាពគ្នាធ្វើផ្លូវដោយខ្លួនឯង។ សូមប្រគេនដំណឹងនេះដល់ព្រះតេជគុណ សូមព្រះអង្គមេត្តាជូនព្រះពរដល់ពួកខ្ញុំព្រះករុណាសូមអោយបានសម្រេចការងារផង សូមព្រះតេជគុណកុំមានការអាក់អន់ចិត្តអីណា៎!។

ដូច្នេះបញ្ហាកសាងផ្លូវត្រូវបានបញ្ចប់ ដោយឡែកអំពីការកសាងសាលារៀន គឺរដ្ឋអំណាចមូលដ្ឋានផ្តល់ទីតាំង និងបានស្នើអោយអាត្មាភាពជួយសាងសង់សាលារៀនថ្មីមួយ សម្រាប់ជំនួសអោយសាលាចាស់ទ្រុឌទ្រោមយ៉ាងធ្ងន់ធ្ងរ អាត្មាភាពបានធ្វើការពិនិត្យទីតាំងរួចហើយ ប៉ុន្តែពុំទាន់សម្រេចចិត្តចាប់ផ្តើមកសាងនៅឡើយ។ អាត្មាភាពត្រៀមលក្ខណៈសាងសង់សាលារៀន ប៉ុន្តែពុំអាចទទួលការរ៉ាប់រងទាំងស្រុងទេ ក្រោយពេលសាងសង់សាលារួចឡើយ អាត្មាភាពបានស្នើអោយអ្នកស្រុកនៅទីនេះ ទទួលការគ្រប់គ្រងសាលារៀនដែលសង់សម្រាប់អោយពួកគេនោះ។ អាត្មាភាពបានប្រជុំពិភាក្សាជាមួយរដ្ឋអំណាចមូលដ្ឋានចំនួនជាងដប់លើកមកហើយ តែពុំទាន់ឈានដល់ការឯកភាពឡើយ។ បច្ចុប្បន្ននេះ ពួកគេសំណូមពរអោយអាត្មាភាពផ្តល់ប្រាក់បៀវត្សរ៍អោយគ្រូបង្រៀន ប៉ុន្តែអាត្មាភាពបានយល់ព្រមត្រឹមតែធ្វើជាទីប្រឹក្សាផ្នែកអប់រំតែប៉ុណ្ណោះ រីឯការងារគ្រប់គ្រងរដ្ឋបាល គឺអាស្រ័យទៅលើអ្នកស្រុកចាត់ចែង។

នៅមានការងារជាច្រើនដែលត្រូវធ្វើបន្តទៅទៀត ហេតុនេះហើយ អាត្មាភាពតែងតែសង្ឃឹមថា នឹងមានយុវជនជាច្រើន ដែលមានបំណងល្អ មកទីនេះ ដើម្បីជួយសហការជាមួយនឹងអាត្មាភាព។ អំពើមនុស្សធម៌មិនស្ថិត ទាំងស្រុងទៅលើការមានថវិកា ឬមានចិត្តប៉ុណ្ណោះទេ គឺថែមទាំងត្រូវ ទាមទារអោយមានការយល់ជ្រួតជ្រាប នូវចរិតលក្ខណៈរបស់អ្នកស្រុកព្រមទាំង ទំនៀមទម្លាប់ប្រពៃណីតាមតំបន់ដែលយើងចង់ជួយឧបត្ថម្ភផងដែរ។ ប្រទេសខ្លះជាអ្នកមានលុយ មកជួយលុយជាច្រើនដល់ប្រទេសក្រ ដោយ មានបំណងល្អប្រសើរប៉ុណ្ណោះ ប៉ុន្តែការប្រើប្រាស់លុយជាជំនួយដោយពុំបាន សមហេតុសមផលទេ នោះអាចនឹងនាំមកនូវផលវិបាកបំផ្លាញរបៀបរៀបរយ សង្គមនៅទីនោះជាពុំខាន។ ការជួយទំនុកបម្រុងយ៉ាងប្រសើរ គឺត្រូវធ្វើយ៉ាង ដូចម្តេចអោយគេចេះឈានឡើង យើងត្រូវណែនាំវិធីសាស្ត្រអោយគេខំធ្វើ ដោយខ្លួនឯង មិនមែនយើងធ្វើជំនួសគេឡើយ។ បទពិសោធន៍ជាក់ស្តែងនៅ **លុម្ពិនីវ័ន្ត** បានបង្ហាញអោយយើងឃើញយ៉ាងច្បាស់ថា ប្រទេសមួយចំនួន បានមកសាងសង់ព្រះវិហារនៅទីនេះ បានចំណាយលុយជាច្រើនពាសវាល ពាសកាល ដោយសារគេបានទទួលថវិកាសាងសង់យ៉ាងច្រើនលើសលប់។ នេះជាប្រការមិនប្រសើរ ដែលអាត្មាភាពធ្លាប់មានការឃាត់ឃាំង ហើយ មនុស្សម្នាក៏បាននាំគ្នាស្តាប់តាមជាបណ្តើរៗដែរ។ ឧទាហរណ៍ ដូចជាការ សងថ្លៃឈ្នួលកម្មករនេប៉ាល់គឺត្រូវធ្វើទៅ តាមកម្រិតទូទៅក្នុងស្រុក**នេប៉ាល់**

មិនត្រូវបង្ខូចទីផ្សារដោយសងកម្រៃឈ្នួល ច្រើនជាងកម្រៃធម្មតាពីពីរដល់បីដងបានឡើយ ព្រោះធ្វើដូចនេះនឹងនាំមកនូវផលវិបាកអសកម្មដែលសង្គម **នេប៉ាល់** ត្រូវទទួលរងក្រោយពេលការសាងសង់ព្រះវិហារត្រូវបញ្ចប់។

ដោយតួនាទីជា ប្រធានសហព័ន្ធពុទ្ធសាសនាពិភពលោក អាត្មាភាពតែងតែរំឭក និងដាស់តឿនដល់អង្គការពុទ្ធសាសនាបរទេសនៅទីនេះអោយគេចេះគោរពប្រពៃណីរបៀបរបបនៃប្រទេសនេប៉ាល់ ប្រការនេះបានញ៉ាំងអោយរដ្ឋអំណាចមូលដ្ឋាន ព្រមទាំងរដ្ឋអំណាចនៅមជ្ឈិមមានការគោរពចំពោះអាត្មាភាព។ ឧប្បត្តិហេតុមួយបានកើតមានឡើងនៅ**លុម្ពិនីវ័ន្ត**បណ្ដាលអោយបណ្ដាប្រទេស ដែលមកសាងសង់ព្រះវិហារនៅទីនេះមានការដកពិសោធរៀងៗខ្លួន។ សហព័ន្ធពុទ្ធសាសនារបស់ប្រទេសមួយបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍**លុម្ពិនីវ័ន្ត** ក្នុងនោះមានទាំងការងារស្ថាបនា និងជីកកកាយស្រាវជ្រាវវត្ថុបុរាណនៅទីនេះ ដោយមានការចំណាយថវិកាយ៉ាងច្រើន។ លោកប្រធានគណៈកម្មាធិការបុរាណវត្ថុវិទ្យារបស់ប្រទេសនោះ ត្រូវបានចាត់តាំងមកបំពេញកិច្ចការនៅឯ**លុម្ពិនីវ័ន្ត** ដោយទទួលយកប្រាក់បៀវត្សរ៍ដល់ទៅ១៧,០០០ដុល្លារអាមេរិកក្នុងមួយខែ។ លោកប្រធានរូបនេះបានចំណាយលុយដូចទឹក គាត់បានស្នាក់នៅសណ្ឋាគារផ្កាយប្រាំ **Hokke** ហើយជារៀងរាល់ចុងសប្ដាហ៍ គាត់បានរៀបចំពិធីលៀងភោជនាហារយ៉ាងអធិកអធមដោយមានសុរាខ្លាំងៗផឹកតាមចិត្ត។ អាត្មាភាពបានណែនាំ និងដាស់រំឭក

ខ្លះៗអំពីបញ្ហានេះ ប៉ុន្តែគាត់ពុំព្រមស្តាប់ ហើយថែមទាំងមានការអន់ចិត្ត ចំពោះអាត្មាភាពទៀតផង។

លោកបានជួលបុគ្គលិកក្នុងស្រុក ហើយផ្តល់ប្រាក់បៀវត្សរ៍អោយគេជាច្រើន ព្រមទាំងអោយផលកម្រៃផ្សេងៗថែមទៀតដែរ។ ក្រោយមក ដោយមិនពេញចិត្តចំពោះបុគ្គលិកមួយចំនួន គាត់បានបញ្ឈប់ការងាររបស់គេ ហេតុនេះបណ្តាលអោយពួកគេបាត់បង់តួនាទី និងផលប្រយោជន៍ ពួកគេកើតមានចិត្តគុំគួន និងស្វែងរកវិធីសងសឹកទៅវិញ។

នៅពេលនោះអាត្មាភាពបានវិលត្រឡប់មកពីបរទេស ក្រោយពេលដែលទៅបង្រៀនសិស្សនៅទីនោះ ពេលកំពុងជិះយន្តហោះ អាត្មាភាពអានកាសែតមួយដែលផ្សាយចេញពីទីក្រុង**កដ្ឋមណ្ឌុ** ក្នុងអត្ថបទដែលមានចំណងជើងដ៏ធំរត់ឆ្លងកាត់ទាំងប្រាំបីខ្ទង់នោះបានផ្សាយដំណឹងថា លោកប្រធានគណៈកម្មាធិការបុរាណវត្ថុវិទ្យារូបនោះរត់ពន្ធអាភៀន។ អាត្មាភាពគិតថា មានបញ្ហាមិនប្រក្រតីក្នុងរឿងនេះហើយមើលទៅ!។

ពេលបានឮថា អាត្មាភាពបានមកដល់ហើយ លោកឯកអគ្គរដ្ឋទូតរបស់អ្នករងគ្រោះនោះបានមករកអាត្មាភាពទាំងភ្ញាក់ផ្អើលភ័យ ព្រោះពុំដឹងថាត្រូវដោះស្រាយបញ្ហានេះ យ៉ាងដូចម្តេចឡើយ។ ពួកអ្នកបន្តុបរឿងនេះឡើងដើម្បីបំផ្លាញដល់លោកប្រធាន នោះគឺពួកគេបានជួលជនជាតិម្នាក់នៅតំបន់ព្រៃភ្នំ នាំយកថ្នាំញៀនហេរ៉ូអ៊ីនពីរគីឡូក្រាម មកបន្លំដាក់ចូលក្នុងបន្ទប់ធ្វើការ

របស់លោកប្រធាន រួចផ្តល់ដំណឹងទៅអោយប៉ូលីស។ ជាសំណាងមួយដែរ ដោយលោកប្រធានអត់បានមកធ្វើការ នាថ្ងៃនោះមានតែបុគ្គលិកនេប៉ាល់ម្នាក់ត្រូវគេចាប់ខ្លួន។

បន្ទាប់មកលោកអគ្គនាយកនគរបាលនៅ**លុម្ពិនីវ័ន្ត** បានមកជួបអាត្មាភាព ដើម្បីជំរាបជូនដំណឹងថា ពួកគេនឹងចេញដីកាចាប់ឃុំខ្លួន លោកប្រធាននៃគណៈកម្មាធិការបុរាណវត្ថុវិទ្យា។ ពេលនេះ អាត្មាភាពបានធ្វើការវិភាគយ៉ាងម៉ឺងម៉ាត់ជាមួយពួកគាត់ថា :

- នេះគឺជារឿងពិបាកនឹងជឿណាស់! ប្រាកដជាមានអ្នកណាមួយប្រឌិតរឿងនេះឡើង ដោយសារគំនុំបុគ្គលតែប៉ុណ្ណោះ ចូរលោកគិតមើលប្រាក់ខែរបស់លោកប្រធាននោះប៉ុន្មាន? គឺជាប្រាក់ខែយ៉ាងស្កុកស្កម្ភ ទើបគាត់រស់នៅយ៉ាងហ៊ឺហាដូច្នេះ អ្នកណាមួយក៏បានដឹងអំពីរឿងនេះ។ រីឯការរត់ពន្ធអាភៀន បើសិនជាគាត់ជាអ្នកប្រព្រឹត្តពិតមែននោះ គឺគាត់ច្បាស់ជាត្រូវឡើងទៅទាក់ទងជាមួយពួកអ្នកនៅឯទីក្រុងធំៗ មិនគួរណាស់គាត់មកលក់ដូរគ្រឿងញៀននៅទីកន្លែងស្ងាត់យ៉ាងតូចដូចនេះ ដែលមនុស្សម្នាគ្រប់ៗគ្នាអាចនឹងមើលឃើញច្បាស់ជាពុំខាន។ ចំពោះឧប្បត្តិហេតុនេះ បើសិនជាការដោះស្រាយមិនបានច្បាស់លាស់ត្រឹមត្រូវទេនោះ វានឹងនាំមកនូវផលវិបាកយ៉ាងធំជាពុំខានទេណា! អាត្មាភាពក៏សូមបញ្ជាក់

ថា បើសិនជាប្រធានគណៈកម្មាធិការបុរាណវត្ថុវិទ្យា ត្រូវចាប់ខ្លួនគឺប្រជាជននេប៉ាល់រាប់លាននាក់ ក៏ត្រូវខាតបង់ផលប្រយោជន៍ដែរ ពីព្រោះមិនត្រឹមតែប្រទេសរបស់គាត់បញ្ឈប់ជំនួយប៉ុណ្ណោះទេ គឺថែមទាំងសហគមន៍អន្តរជាតិទាំងមូល និងបញ្ឈប់ការផ្តល់ថវិកាសម្រាប់កម្មវិធីអភិវឌ្ឍន៍**លុម្ពិនីវ័ន្ត** ក៏ដូចជាអភិវឌ្ឍន៍ប្រទេស**នេប៉ាល់**និយាយរួមផងដែរ។ ហេតុនេះហើយ តាមគំនិតរបស់អាត្មាភាពវិញគឺយើងត្រូវតែស្វែងយល់ អោយបានច្បាស់លាស់នូវធាតុពិតនៃរឿងរ៉ាវនេះណា៎។ បើសិនជាអស់លោកបង្ខំចិត្តចាប់ខ្លួនគេនោះ យ៉ាងច្រើនគេត្រូវជាប់ឃុំឃាំងមួយរយៈ តាមច្បាប់រដ្ឋ**នេប៉ាល់** រួចគេនឹងវិលត្រឡប់ទៅស្រុករបស់ខ្លួនវិញ ប៉ុន្តែបើសិនជាការដោះស្រាយនេះ ត្រូវជួបការប្រឆាំងតវ៉ាពីរដ្ឋាភិបាលរបស់គេទៅវិញ គឺអស់លោកនឹងមានការស្មុគស្មាញជាពុំខាន។

ដើម្បីបញ្ចប់រឿងនេះ អាត្មាភាពបានពោលបន្ថែមទៀតថា : បើសិនកិច្ចការនេះ ពុំបានដោះស្រាយអោយស្រួលបួលទេនោះ អាត្មាភាពនឹងទៅជួបជាមួយស្តេចដើម្បីលើកយកបញ្ហានេះ ពិភាក្សានៅក្នុងអង្គប្រជុំរដ្ឋសភា**នេប៉ាល់**។ ក្រោយមកបញ្ហានេះ ត្រូវបានដោះស្រាយយ៉ាងល្អប្រសើរហើយ លោកឯកអគ្គរដ្ឋទូតរបស់គាត់ ក៏បានចូលរួមថ្វាយបង្គំថ្លែងអំណរគុណដោយ

ក្ដីរីករាយចំពោះអាត្មាភាព ក្រោយពេលព្រួយបារម្ភខ្វល់ខ្វាយក្នុងចិត្តអស់ពីរបីសប្ដាហ៍កន្លងមក។

ខាងលើនេះគឺជាបទពិសោធន៍មួយចំនួន ដែលអាត្មាភាពបានដកស្រង់ក្នុងរយៈពេលបានគង់នៅ និងប្រកបការងារនៅឯប្រទេស**នេប៉ាល់**។

❋❋❋❋❋

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងតាមរឿងសត្វក្រៀល អាត្មាភាពមានសេចក្តីសប្បាយរីករាយ ព្រោះតែការប្រកបកិច្ចការតូចៗ ដោយសារចិត្តមេត្តាស្រឡាញ់សត្វលោកនេះ បាននាំមកនូវឥទ្ធិពលយ៉ាងសកម្មសម្រាប់សង្គម។

ដោយចិត្តស្រឡាញ់សត្វក្រៀល អាត្មាភាពបានយកអស់កម្លាំងកាយចិត្ត ការពារពួកវារួចហើយ ក៏បានដឹងច្បាស់នូវទុក្ខវេទនារបស់អ្នកស្រុក ទើបពេលនោះ អាត្មាភាពមានប្រាថ្នាសាងសង់ស្ពានមួយអោយប្រជាជននៅទីនេះ។ ការសាងសង់ស្ពានបានសម្រេច ក៏នាំមកនូវការអភិវឌ្ឍនផ្លូវថ្នល់ មន្ទីរពេទ្យ និងសាលារៀនមួយ។ ទៅអនាគតយើងឃើញយ៉ាងច្បាស់ថា សេចក្តីស្រឡាញ់យ៉ាងស្មោះសរ ដោយពុំគិតដល់ប្រយោជន៍ផ្ទាល់ខ្លួនបានរីកសាយភាយយ៉ាងខ្លាំង។ សំខាន់ជាងនេះទៅទៀត គឺគំរូការងារដែលអាត្មាភាពព្រមទាំងសិស្សបានធ្វើកន្លងមក បាននាំអោយមនុស្សម្នាប្រឡងប្រណាំងធ្វើអំពើល្អ។ ឥទ្ធិពលនេះក៏បានទៅដល់ថ្នាក់ដឹកនាំ រដ្ឋាភិបាលមជ្ឈិម និងរដ្ឋអំណាចមូលដ្ឋាន ក៏ដូចជាបណ្តាអង្គការពុទ្ធសាសនានៃប្រទេសមួយចំនួននៅទីនេះ។ មនុស្សនាំគ្នាស្រឡាញ់រាប់អានសត្វលោក ការពារសត្វបក្សីអោយវាបានរស់នៅយ៉ាងសុខសាន្ត នាំយកការងារមកអោយអ្នកស្រុកក្នុង

តំបន់ សូម្បីតែអ្នកមានចិត្តព្រងើយកន្តើយ ក៏ត្រូវទទួលឥទ្ធិពលនាំអោយគេមានក្តីមេត្តាឆ្ពោះទៅរកអំពើល្អជាបណ្តើរៗផងដែរ។

នៅពេលមនុស្សគ្រប់រូបបានយល់ច្បាស់ នូវសតិសម្បជញ្ញៈភ្លឺស្វាងរបស់ខ្លួន គេមិនផ្តោតសំខាន់ទៅលើការនិយាយតែទ្រឹស្តីប៉ុណ្ណោះទេ សំខាន់គឺបញ្ជាក់ទង្វើយ៉ាងស្មោះស្ម័គ្រ នៅពេលនោះហើយ គេបានរួបរួមគ្នាដោះស្រាយបញ្ហាលំបាកបំផុត ព្រមទាំងផ្តល់ថវិកាផ្ទាល់ខ្លួនផងដែរ។ ភាពអស្ចារ្យនេះបានញ៉ាំងអោយអាត្មាភាពមើលឃើញនូវសច្ចៈមួយ គឺពេលណាដែលយើងមានឱកាសបំពេញកិច្ចការជាកុសលណាមួយ ដើម្បីជួយដល់មនុស្សយើងមិនគួរបោះបង់ចោលឱកាសនោះឡើយ ពីព្រោះឱកាសសម្រាប់យើងបញ្ចេញអំពើល្អនោះ បើសិនជាកន្លងផុតទៅហើយ គឺមិនវិលត្រឡប់មកវិញបានឡើយ។ បើសិនជា អាត្មាភាពមិនស្ម័គ្រចិត្តជួយដល់សត្វក្រៀលទាំងនោះទេ សមិទ្ធផលទាំងឡាយបន្ទាប់មកនោះ ក៏ពុំអាចចេញជារូបរាងបានដែរ។

ភាពជាក់ស្តែងទាំងឡាយនេះ បានបញ្ជាក់អោយយើងឃើញយ៉ាងច្បាស់ថា ក្នុងជីវិតរស់នៅ បើសិនជាយើងជួបឱកាសល្អសម្រាប់ធ្វើអំពើល្អនោះ យើងពុំគួរមានការស្ទាក់ស្ទើរឡើយ គួរតែបំពេញកិច្ចការនោះជាបន្ទាន់ ពីព្រោះកុសលកម្មយ៉ាងតូចមួយនៅគ្រាដំបូង មិនគ្រាន់តែនាំមកនូវប្រយោជន៍ចំពោះមុខប៉ុណ្ណោះទេ គឺវាថែមទាំងនាំមកនូវមនុញ្ញផលដ៏ធំធេងទៅថ្ងៃក្រោយទៀតដែរ។ ទង្វើល្អរបស់មនុស្សម្នាក់ មិនត្រូវបញ្ចប់នៅត្រឹមហ្នឹងទេ គឺវា

ត្រូវបានរីកសាយភាយទៅដល់អ្នកដទៃជាច្រើន ប្រៀបដូចនឹងសំឡេងមួយខ្ទរផ្សាយទៅកន្លែងផ្សេងៗដែរ។

សេចក្ដីស្រឡាញ់យ៉ាងស្មោះចំពោះសត្វក្រៀល បាននាំមកឱកាសល្អៗជាច្រើនសម្រាប់អាត្មាភាព បំពេញកិច្ចការប្រកបដោយប្រយោជន៍ដល់សត្វលោក ហេតុនេះអាត្មាភាពបានធ្វើការសន្និដ្ឋានថា : បើសិនជា យើងមានសេចក្ដីស្រឡាញ់ចំពោះសត្វលោកទាំងឡាយ គឺយើងប្រាកដជាបានទទួលនូវកុសលផលបុណ្យយ៉ាងធំធេងជាពុំខាន។ នេះគឺជាភាពពិសិដ្ឋអស្ចារ្យមួយ ដែលអាត្មាភាពបានយល់បន្ថែមទៀតថា អំពើមួយ ទោះបីតូចតាចក្ដីក៏អាចនឹងនាំមកនូវផលល្អ ឬអាក្រក់យ៉ាងជាក់ស្ដែង សម្រាប់ជីវិតរបស់មនុស្សម្នាក់ ព្រមទាំងបានជះឥទ្ធិពលទៅដល់អ្នកដទៃទៀតដែរ។ យើងអាចនឹងមើលឃើញយ៉ាងច្បាស់ តាមរយៈការកសាងស្ពាននៃសេចក្ដីស្រឡាញ់របស់វៀតណាម។ ស្ពាននេះ បានជួយដល់ប្រជាជនក្នុងការធ្វើដំណើរឆ្លងកាត់ស្ទឹងដោយសុវត្ថិភាព ពិសេសគឺអ្នកជំងឺត្រូវបានបញ្ជូនដល់មន្ទីរពេទ្យយ៉ាងឆាប់រហ័ស មិនមែនរាំងស្ទះដោយអស់សង្ឃឹមដូចពីមុនទៀតឡើយ ។ ជួនកាលមើលទៅអនាគតឃើញថា ក្មេងៗដែលឆ្លងស្ពានទៅសាលារៀនទាំងនោះ អាចនឹងក្លាយទៅជាអ្នកប្រាជ្ញ ឬអ្នកល្បីល្បាញសម្រាប់ជួយដល់ប្រទេសជាតិ នៅថ្ងៃក្រោយក៏មានដែរ។

មានតែសេចក្ដីស្រឡាញ់បរិសុទ្ធ ដែលយើងផ្ដល់ជូនដោយមិនគិតដល់

ប្រយោជន៍ផ្ទាល់ខ្លួនទេ នោះបានធ្វើអោយជីវិតសត្វលោកបានប្រកបដោយភាពសុខដុមរមនា។ សូម្បីតែ នៅក្នុងគ្រួសារមួយក៏ដូចនេះដែរ បើសិនជាយើងបានយកចិត្តទុកដាក់ថ្នាក់ថ្នមអ្នកណាមួយនោះ គេគង់នឹងមានការតបស្នងវិញជាពុំខាន គ្រូបង្រៀនស្រឡាញ់សិស្ស សិស្សក៏មានសេចក្តីគោរពស្រឡាញ់ចំពោះគ្រូបង្រៀនរបស់ខ្លួនដែរ អ្នកដឹកនាំប្រទេសជាតិមានសេចក្តីស្រឡាញ់យ៉ាងស្មោះចំពោះប្រជាជន គឺប្រជាជនច្បាស់ជាមានការស្រឡាញ់រាប់អានដល់គេជាពុំខាន។ យើងក៏បានដឹងថា គ្រួសារមួយអាចមានកូនខិលខូច សិស្សសាលាក៏មានអ្នកពិបាកនឹងប្រៀនប្រដៅ ក្នុងសង្គមក៏មានអ្នកបោកប្រាស់ដែរ ប៉ុន្តែទាំងនេះគឺជាករណីដោយឡែក យើងពុំអាចទាមទារអោយមានភាពសុក្រឹតល្អទាំងស្រុងបានឡើយ។ សំខាន់គឺការប្រាស្រ័យទាក់ទងរបស់យើង ក្នុងសង្គមត្រូវមានភាពស្មោះត្រង់ ពិសេសពាក្យសំដីត្រូវដើរទន្ទឹមនឹងទង្វើរបស់ខ្លួន។

អ្នកខ្លះបានយល់ថា ភាពពិសិដ្ឋអស្ចារ្យនោះ គឺជាអ្វីមួយយ៉ាងសម្បើមណាស់ដូចជារឿងព្រេង ស្ត្រីនួវ៉ាមានឫទ្ធិយកថ្មប៉ះមេឃ ឬសិល្ប៍សាស្ត្រជិះពពកក្នុងរឿងទេពវាយោ។ ចំពោះអាត្មាភាពវិញ ភាពពិសិដ្ឋអស្ចារ្យ គឺជាការដែលយើងបានរកឃើញ សេចក្តីសុខសាន្តយ៉ាងពិតប្រាកដនៅក្នុងជីវិតនេះ គឺការប្រែក្លាយចំណេះដឹង ព្រមទាំងសេចក្តីស្រឡាញ់ដ៏បរិសុទ្ធរបស់ខ្លួនក្លាយទៅជាផលប្រយោជន៍សម្រាប់សត្វលោក។ នេះគឺជាទស្សនវិស័យយ៉ាង

សាមញ្ញសំរាប់ជីវិតដែលអាត្មាភាពបានរកឃើញ ហើយមានជំនឿថាអ្នកណាមួយយកទៅអនុវត្តក្នុងជីវិតរបស់ខ្លួន គឺគេនឹងទទួលបានលទ្ធផលយ៉ាងល្អប្រសើរជាពុំខាន។

អាត្មាភាពជឿជាក់ថា មនុស្សរាប់ពាន់រាប់ម៉ឺននាក់នៅលើពិភពលោកកំពុងប្រកបដោយអំពើជាកុសលយ៉ាងស្ងប់ស្ងៀមជារៀងរាល់ថ្ងៃ រាល់ពេលវេលា ហើយភាពពិសិដ្ឋ និងមនុញ្ញផលដ៏អស្ចារ្យក៏មានឡើង ចំពោះគេដូចគ្នានឹងករណីរបស់អាត្មាភាពដែរ។ អាត្មាភាពក៏មានបំណងបានស្តាប់រឿងប្រហាក់ប្រហែលរបស់អ្នកដទៃជាច្រើន ដើម្បីយើងទាំងអស់គ្នាបានចែករំលែកនូវភាពសុខសាន្តជាមួយគ្នា។

បច្ចុប្បន្ននេះ អាត្មាភាពនៅតែបន្តការទទួលយកនូវភាពពិសិដ្ឋអស្ចារ្យនៅក្នុងជីវិតរបស់ខ្លួន ហើយសង្ឃឹមថានឹងមានឱកាសល្អៗជាច្រើន ដើម្បីនិទានជូនមិត្តអ្នកអាន អោយបានយល់បន្ថែមអំពីផលានិសង្ស សម្រាប់ជីវិតរបស់យើងទាំងអស់គ្នា។

និទាឃរដូវ ព.ស. ២៥៤៨ — គ.ស. ២០០៤

**ទៀន យ៉ីច**

# ព្រះវិហារនៃពុទ្ធសាសនាអន្តរជាតិដំបូងបង្អស់
# នៅលើនគរព្រះ នាប្រទេសនេប៉ាល់

THE FIRST INTERNATIONAL BUDDHIST MONASTERY
ON THE BUDDHA'S LAND IN NEPAL.





សូត្រមន្តបួងសួងក្នុងពិធីបុកគ្រឹះ

Monks performing rituals in the ground-breaking ceremony

ព្រះសង្ឃភូមាបានជួយជ្រោមជ្រែង
ក្នុងការងារសាងសង់លើកដំបូង
Myanmar monks enthusiastically
give a helping hand





វត្តមានដោយចៃដន្យរបស់សត្វដំរីក្នុងពិធីពទ្ធសីមាសំរាប់ការសាងសងព្រះវិហារវៀតណាម ដើម្បីចំលងព្រះតេជគុណនិមន្តប្រទក្សិណ

Suddenly an elephant appeared. Later it walked leisurely round the plot of land reserved for the building of the Vietnam Buddhist Monastery the Superior Monk on its back reciting suttas and mantras.





មិត្តភ័ក្តឥណ្ឌាមកពីពុទ្ធគយាបានមកជួយការងារ
Indian friends from Bodh Gaya came to help.



គ្រាដំបូងនៃការសាងសង់ព្រះវិហារ
វៀតណាមនៅលុម្ពិនីវ័ន្ត

On the first days of the
construction of the Vietnam
Buddhist Monastery in Lumbini



ដណ្ដប់ភួយពេលអាកាសធាតុ
ត្រជាក់ខ្លាំង

Wrapping the body with
a blanket to put up with
the extremely cold weather



គង់នៅក្បែរជំរកគយគន់
ព្រះអាទិត្យអស្ដង្គត

Sitting by the tent
contemplating the sunset.



# ស្ពានវៀតណាមនៃសេចក្តីមេត្តា

## THE VIETNAM BRIDGE OF COMPASSION



សកម្មភាពវាស់វែងប្លង់ដី

Measuring the land



វត្តមានព្រះសង្ឃជាន់ខ្ពស់
ក្នុងពិធីបុកគ្រឹះ

Senior masters starting the ground-breaking ceremony



ការដឹកជញ្ជូនដោយរទេះគោ

Transport by ox carts



មនុស្សម្នាទាំងចាស់ទាំងក្មេងបាន
ចូលរួមយ៉ាងកុះករ

Everybody, adults and children alike, all gave a hand.



វិស្វករភូមាកំពុងប្រកបការងារសាងសង់

A Myanmar engineer working on the project.



ស្ពាននៃសេចក្តីមេត្តាបានសាងសង់រួចដោយពិសិដ្ឋភាព

The Bridge of Compassion was completed by a miracle.



ពិធីសម្ពោធស្ពាននៃសេចក្តីមេត្តា  នៅលុម្ពិនីវ័ន្ត

Celebrating the completion of the Bridge of Compassion in Lumbini, Nepal

# ទីណាសុខសាន្ត បក្សាបក្សីស្នាក់អាស្រ័យ

## WHERE THERE IS GOOD LAND, THERE ARE BIRDS' ROOSTS



ការមកដល់ជាលើកដំបូងរបស់សត្វក្រៀលមួយគូដែលមានរូបរាងខ្ពស់ធ្វើឱ្យអាត្មាភាពមានការភ្ញាក់ផ្អើលជាខ្លាំង ។

I was surprised and frightened when I saw for the first time a pair of tall and big birds that appeared in front of my tent.



សមាជិកថ្មីពីរូបនៃគ្រួសារក្រៀល

Two new- born members of the crane family.



ប្រធានសមាគមការពារបក្សាបក្សី

President of the bird Guardians Association



សត្វក្រៀលមកឱ្យជួយនៅពេលព្រាត់កូន

Having lost its baby, a crane came to ask for help.



ពង្រាងសេចក្តីប្រកាសហាមបៀតបៀនដល់សត្វក្រៀល

Preparing an announcement requesting people not to harm the sarus cranes.



សត្វក្រៀលមួយគូ ដែលមកលេងព្រះវិហារវៀតណាម ។

A couple of cranes paid a visit to the Vietnam Buddhist Monastery.



ក្តីត្រេកអរដោយភាពជោគជ័យ
ក្នុងការថែរក្សារសត្វក្រៀល

The great pleasure brought about by success in protecting the sarus cranes.

# សកម្មភាពផ្សេងៗក្នុងការចូលរួមសម្របសម្រួលឱ្យ មានសន្តិភាពនៅប្រទេសនេប៉ាល់

## CONTRIBUTION TO THE RECONCILIATION AND PEACE IN NEPAL



នេប៉ាលជាប្រទេសមួយដ៏ស្រស់បំព្រង
Nepal-a country of attractive beauty



ភាពរន្ធត់នៃសង្គ្រាមនៅប្រទេសនេប៉ាល់
Horrors of war in all roads of Nepal.



សង្គ្រាម និងភាពក្រីក្រ
War and poverty




ការជួបប្រជុំនៅកដ្ឋមណ្ឌ ជាមួយតំណាងយុវជន
ស្តីអំពីសន្តិភាពនៅ នេប៉ាល់

A meeting with youth representatives on peace for Nepal held in Kathmandu.




ការសន្ទនា អំពីការសម្របសម្រួលសន្តិភាពក្នុងសមាគម
អ្នកសារព័ត៌មាននៅនេប៉ាល់ (2004)

A talk about reconciliation and peace at the reporters club, Nepal (2004)



គណៈប្រតិភូពុទ្ធសាសនាអន្តរជាតិបួងសួងសុំសន្តិភាពសម្រាប់
ប្រទេសនេប៉ាល់ នៅព្រះវិហារវៀតណាម

International buddhist delegations praying for peace for Nepal
at the Vietnam monastery.



ព្រះតេជគុណ វៀនយីវ ជាមួយក្មេងៗ នេប៉ាល់នៅលុម្ពិនីវ័ន្ត

Ven. Huyen Dieu and Nepalese children in Lumbini

# ទេសភាពដ៏ត្រកាល នៅលុម្ពិនីវ័ន្តប្រទេសនេប៉ាល់

## BEAUTIFUL SCENERIES IN LUMBINI - NEPAL



ព្រះវិហារវៀតណាមមួយនៅលុម្ពិនីវ័ន្ត ប្រទេសនេប៉ាល់

Vietnam One-Pillar temple.-Lumbini, Nepal.



ទេសភាពពេលព្រះអាទិត្យអស្តង្គត

A scenery at dawn-Lumbini, Nepal



សត្វក្រៀលក្រហមនៅលុម្ពិនីវ័ន្ត ប្រទេសនេប៉ាល់

Sarus cranes-Lumbini, Ne al

# Foreword

*Miracles sometimes happen in our life unexpectedly and they are not always recognizable. Very often, miracles result from concrete good deeds that we do for the well - being of others.*

*If each of us always cherished the desire to do a good deed every day, every week, or every month, the effects brought about by our kind heart are sometimes beyond our expectations. And after some time we will realized how amazingly our lives have changed.*

*However, we should not concentrate only on doing things that have foreseeable good effects only. Just imagine one day you happen to see a little board with a rusted nail on it lying in the middle of the road. If you are thoughtful enough to spare a minute to remove the board from the middle of the road, you may help to prevent harmful things that might happen to some other people afterwards. It might happen that a man steps on the rusted nail by accident. A few days later the nail may cause an infection in his foot. The poor man might be killed by tetanus due to his lack of knowledge or having no access to medical care. The man might be survived by his helpless wife and young children.*

*His fatherless children are likely to grow up without acquiring adequate education. They might cause problems that their society will find it hard to solve.*

*It goes without saying that all these unfortunate things could not happen at all if someone cared to spare a minute to do something with the little board. Therefore we should never ignore a chance to do something good. This is an attitude about life that will certainly bring us positive effects. I myself have often experienced such things in my life. The following story about the sarus cranes is a typical example of my experiences.*

*Lumbini, Nepal, is an area of verdant land lying at the foot of the majestic Himalayas with their numerous constantly glittering snow-covered peaks. This is the place where the Lord Buddha was born over 2,600 years ago. Right from the first few days I stayed in Lumbini, I discovered that the sarus cranes, an extremely beautiful and rare species of birds, were in danger. Their lives were threatened severely by wild animals and humans as well. I immediately started to get to know about them and then sought ways to protect them. It was thanks to my effort that now, the cranes have found good land to make their home in Lumbini and the cranes population has multiplied. From a mere couple of cranes that came to live near the Vietnam Lumbini Buddhist Monastery ten years ago, you can now find 44 of them living safely in scattered places in Lumbini. It was through my efforts in protecting these rare birds that I have been able to have the chance to live closer and closer to nature and to develop a deep affinity with it.*

*And that was not the end of the story. The little good deed for the birds that I accomplished has been followed by many more interesting events that I'm going to tell you one by one in this book.*

*I firmly believe that if we dedicate ourselves to doing good things, we will have the chance to find miracles happen in our life. This is a marvelous thing I myself once experienced and have ever since applied throughout my life. And now I want to share the experience with all my dear readers.*

**Huyen Dieu**

*When the sarus cranes come....*
*and the miracles*

I feel most grateful to:

* *My motherland Viet Nam, where I was born.*
* *My parents.*
* *The Masters who have taught me the secret methods that have helped me succeed and live a happy and unperturbed life.*
* *The countries that have given me the opportunities to live and work in order to realized my dearest wish to do good deeds in life.*
* *My friends, acquaintances and students who have been helping me do good deeds.*
* *And finally the sarus cranes that have given me the opportunity to live closer to nature and hence the chance to do some more useful things for life.*

**HUYEN DIEU**

# The first International Buddhist monastery in the Buddha's Land

Although I have been living the greater part of my life abroad, I have always cherished in my heart a deep love for Viet Nam, my fatherland, and the dearest wish to do something for it. I want to show my gratitude to the country where I was born, to my parents, my master and my friends for what they have endured for my sake. This is the reason why I took a vow to concentrate all my efforts on the building of the Vietnam Buddhist Monastery in the Buddha's Land in India.

In our life we normally concentrate all our efforts on doing the only thing we are most interested in as we also have to spend our time on the numerous chores of our daily life. As for me, what I have been most interested in doing is to learn more, to travel, to go on pilgrimages to holy places and to do good deeds. However, Thanks to good lucks, I had the chance to build the second Vietnam Buddhist Monastery in Lumbini, Nepal, a holy place the name of which is constantly mentioned in Buddhist literature.

This area of land used to be the kingdom of King Suddhodana of ancient times and is the very place where prince Siddhatta, a descendent of the Sakya clan, was born almost 2,600 years ago.

In the memoirs of the great Chinese pilgrim and scholar Xuan Zhuang, this kingdom was described as an area of land of about 1,880km in perimeter and was located in the region of Terrai at the foot of the imposing Himalayas. In 563 B.C., when it was near the time of her childbirth, Queen Maya Devi left the royal palace, with the king's permission, to go back to her home town in the kingdom of Devadaha to give birth to their first child, in accordance with the customs and traditions of their country. When she was about 25 km from the capital city she was going across a garden in the village Lumbini, she gave birth to Prince Siddhatta under the Ashoka tree in this garden. In 250 B.C. the emperor Ashoka the Great and his escorts, on a pilgrimage to this sacred place, had a big stone pillar built there to consecrate the site. Unfortunately, this sacred area fell into forgetfulness after centuries of political and religious upheavals.

One day in early spring 1969, when I first arrived in Lumbini as a pilgrim, I was really shocked at the sight of the desolate ruins of the holy land. The ground around the stone pillar that was erected to mark the birthplace of the Lord Buddha was littered with human excrement. In deep sorrows, I walked around the place and prayed under my breath "May I have the blessing of seeing the place revived and developed before the end of my life if this is really the holy place where the Lord Buddha was born".

Since then I kept mentioning this concern of mine either in my teaching sessions of the Buddha's Dhamma to my disciples or in my lectures to my university students on the history of Asia and on international relations. I often made a comparison like this: the importance of Lumbini to Buddhism is exactly the same as Mecca to Islam, Vatican to Catholicism, Benares to Hinduism or Jerusalem to Judaism. Nevertheless, Lumbini was now sadly reduced to a mere derelict site.

Some of my students, who were working for international organizations, shared this concern with me and silently campaigned for over ten years for the revival of the holy Lumbini.

It was not until 1993 that their wholehearted efforts bore fruit: King Birendra and the Nepalese Royal Government agreed to grant me a plot of land in Lumbini so that I could build the second Vietnam Buddha Land Monastery, which is also the first international monastery that has ever been built at the place where the Lord Buddha was born.

# An adventurous decision

It was in 1987 that I started concentrating all my efforts on the construction of the Vietnam Buddhist Monastery in Bodh Gaya, India, the first Vietnamese monastery in the Buddha's land as an act of gratitude to the Lord Buddha as well as a spiritual gift offered to my native country. Not until I started the job did I realize I had embarked on a monumental task with tremendous complexities.

Bodh Gaya is located in the town of Gaya, in the state of Bihar, India. I knew many people here, local leaders as well as central government officials, and they were always ready to help me. However, the disadvantage of my relation with these people was when they came to visit me they were usually escorted by security agents and policemen, who unintentionally disturbed my peaceful daily life. Furthermore, due either to their affection for me or to the requirements of work between us, there were days when I was invited to have breakfast with seven different officials at seven different places. Besides that, I had to attend so many parties and receptions that I didn't have enough time for the building of the pagoda. With my whole mind concentrated I prayed under my breath, "May I be blessed by the Buddhas, the Boddhisatvas, the Dragon Deities, the Dhamma Protectors and the Holy Spirit of my country. I have come here to build a pagoda, but unfortunately many people are very fond of me and I'm invited to so many functions that I cannot bear going to any more.

I pray to you all for your support so that I can have someone to replace me at parties". Miraculously, a few months later Ven.U Pawara came to the pagoda to practice the Dhamma and accepted graciously to go to those functions on my behalf. (He holds now a Ph.D. degree in Buddhism and is a very well-known monk in Myanmar in the realm of education). One and a half year later came another monk, Ven. U Nynenda, who also had the kindness to replace me in the ever-increasing functions, so that I could be at work. (Ven.U Nyenda, a Doctor of History, is now Vice President of the Yangoon Buddhist University, Yangoon, Myanmar). Local custom dictated that guests were to be offered good food, money or gifts at those social affairs. It was not uncommon that they were even given airlines tickets to visit places. Thanks to these two monks, I managed to avoid wasting my time socializing with people and thus was able to concentrate all my time and efforts on building the pagoda, which was then half way through. I really appreciated the two distinguished monks for their bravery in accepting to be my substitute at social affairs.

An unexpected chance took me to the far-off Nepal. One morning when I was preparing to go out overseeing the construction work, I suddenly heard loud wailing of sirens. A police car was coming into the pagoda followed by other cars. I walked out to welcome the visitors, thinking that it was probably another group of important officials coming to visit the pagoda. To my amazement, the visitors were those who had practiced the Dhamma under my guidance a few years ago and had first contributed to the construction of the Vietnam Buddhist

Monastery here. Among the visitors were the police chief of Bihar and the minister in charge of India's Government Office. That was why they came under such heavy police escort.

I was really astonished at the unexpected appearance of my friends in such a big group of visitors as they had always informed me in advance whenever they wanted to pay me a visit. Knowing the reason of my bewilderment, they immediately explained:

"Master, we are here today because we have something very important to tell you. It's urgent so we didn't have time to inform you of our visit".

Then they asked me to allow them to go to the main hall for the worship of the Buddhas. After that when they were all seated at the table for a cup of tea, one of them stood up and spoke on behalf of others.

"Master, your dreams have now come true". He said in a solemn voice.

"In fact, my friends, I have several dreams. Which one are you talking about?" I asked.

He then explained, "Master, once more than ten years ago, when you took us to Lumbini on a pilgrimage to the place where the Lord Buddha was born, you said one of your most cherished dreams was to be able to see Lumbini developed to such a state as it deserved considering its historical uniqueness. Over the years, we have been working quietly towards that goal and now

King Birendra and the Prime Minister K.Prasad of the Nepalese government have agreed to grant you a plot of land in Lumbini. His Majesty the King also offered us this flight to Bodh Gaya to invite you to Nepal to receive the land". In our life there are things that happen beyond our expectations and imagination and when they happen we just do not have time to consider them carefully and react accordingly. That was exactly my situation at that time. I was so overwhelmed at what I had just heard that I did not know what to do. I tried to delay making a decision by saying:

"Now, I think you'd better go to visit the Bodhi Tree, under which the Lord Buddha attained Enlightenment. I myself have to go to the main hall to worship the Buddha so that I can regain calmness of mind and meditate to see whether this is going to be a good thing to do or not".

In fact, I intended to go out of the pagoda once they had gone to the Boddhi Tree. I wanted to be alone and calmly ponder over things. The construction work of the monastery in Bodh Gaya here was only half finished and dozens of workers were still working on the site. How could I leave all this at this stage to go to Lumbini? But my friends persisted in staying by my side saying that they had been to the Boddhi Tree before they arrived here. I felt even more embarrassed and did not know what to do. They kept persuading me:

"Master, please. This is urgent. Try to make arrangements so that you can leave with us right away because the good chance

will not come twice. Everything is ready in Nepal and they are waiting to welcome you there. You just can't refuse to go."
They earnestly requested me to go and these words finally did convince me:

"Master, please don't forget that the Lord Buddha Sakyamuni was born only once."
I barely had time enough to get back to my own room to pack my robe and a few things into my bag and then quickly got into the car with my friends. Only an hour had passed from the time they first arrived at the pagoda. It looked as if it were a "kidnap".

The Gaya airport was 12 Km away from Bodh Gaya. The airport had just been inaugurated recently and the plane I took that day was the first foreign plane that had ever landed at this airport.

Twenty minutes after leaving Bodh Gaya, the plane flew along the Himalayas. I had always been fascinated by the sight of snowy mountains and of the majestic Himalayas. However on that day, I did not care to cast a glance at the innumerable ranges of rolling mountains, all glittering brilliantly in the sun. In the airplane, I felt very restless. I was very much worried and at the same time I felt angry with my friends, who had somehow brought me into this difficult situation in which I found myself completely unprepared.

They later told me, "Master, that was the first time we had ever seen 'your body develop boddhi thorns' ". (This is a joking expression my friends and I usually use to mean "get angry", because everybody knows the boddhi tree actually has no thorn at all).

I was then very angry indeed, but I did not know what to do except clearing my throat to show them that I was upset. I was waiting for an opportunity that could be used as a reason to make them go back to Bodh Gaya. If they had done or said something indecently in this situation, it would have been reason enough for me to force them to go back. However they all kept perfectly quiet as they knew me thoroughly.

I was still in my angry mood when the plane landed at the international airport of Kathmandu. When the door of the plane opened, I saw red carpet already laid down below as if there were a formal welcome reserved for state visitors. Assuming that all this was intended for my friends, I hurriedly stepped aside to let them go first. But they told me it was for me, which made me more embarrassed. Nepalese high-ranking officials were waiting at the foot of the staircase. Among them I could see the Minister of Culture, with whom I had requested an audience but was refused. So I could not help but lead the delegation down the airplane, assuming a very bold manner. They offered each of us a wreath of flowers as was the Nepalese custom. After that came a welcoming ceremony in accordance with protocol. Michel, who was a former French student of mine and currently a member of Unesco Cultural Exchange Program, Whispered into my ears when standing behind me.

"Master, you look great when you walk except that your trouser legs are not of equal lengths". I looked down and saw that he was right. It might be that while we were on the plane, I was so upset that I unconsciously rolled one of the legs up. After the

formal welcoming ceremony, the two sides sat down and began the working session in a very joyous and open atmosphere, which helped to wipe out all my concerns without me knowing it. But at the end of the meeting, I felt tense again as the Nepalese reception committee made this announcement:

"His Majesty the King and His Excellency the Prime Minister would like to invite you to stay at the State Guest Residence".

"No. Thank you. Not for me. I'm just an ordinary person and I would like to stay somewhere else. These friends of mine, who work for international organizations, are guests of the government and they are to stay there. We will get in touch with each other by telephone. We will be fine."

The Nepalese did not agree and I did not give in either. A compromise was finally reached and arrangements were made for me to stay at the Yak Yati Hotel, a well-known five-star hotel in Kathmandu, which specially hosted state visitors of the Nepalese government. The hotel offered special services and was always securely guarded.

No sooner had the accommodation matter been resolved than another problem arose. My friends said, "The King is going to give you a private audience tomorrow afternoon, and after that there's going to be a ceremony. You are to officially receive the land grant documents. Representatives of mass media agencies are going to be invited to the ceremony".

Having heard this I felt very anxious because everything seemed to have reached a high level of importance. But all this was my friends' initiative. They wanted to give publicity to this event through local and international mass media. In this way they believed they could arouse the interest of the Buddhist Community in the world in the cause of safeguarding and developing the hallowed site of Lumbini. I was completely against this initiative, therefore I said to them, "I want to proceed quietly at this stage and we would give it publicity when we have accomplished it. We may have obstacles ahead of us. If we make a lot of noise about it right now we will lose face when we cannot overcome difficulties and fail. We may then be considered as liars".

We discussed an argued with each other for over three hours but failed to arrive at a consensus. However I came up with a proposal,

"All right, I agreed to meet the king but the signing formalities will be carried out between me and the representatives of the Nepalese government without the presence of the mass media people."

They finally agreed to my proposal. The next day, when the formalities had been completed I was taken on a special flight to Lumbini so that I could choose the plot of land I liked. I was so happy because although I had been to Lumbini several times before, this was the first time I could have a panoramic view from the air of the holy site where the Lord Buddha was born. I was so excited that I said to the pilot, "Would you please telephone and

ask your leaders if they could grant me this whole area of land? I would be able to transform Lumbini into a park of international standard."

The pilot was flabbergasted at my idea, "That is impossible, Sir. We have been told to help you choose a plot of land of not more than two hectares."

I had in fact expressed my desire I uncontrollable excitement. I was really more than happy with just two hectares of land. I then asked the pilot to fly low above the ground and make several rounds over the land so that I could have a close observation at the area below. In the end I decided to choose the piece of land near the sacred site where Lord Buddha was born. I though that in the future it would be convenient for the Buddhists who stayed at the Vietnam Monastery to go to the holy site to worship the Buddha. After that the pilot informed his commander by phone that the land had been chosen and its location marked on the map. He landed at the Bhairahawa airport of Lumbini.

I was then taken by jeep to the plot so that I could have a close look at it. Upon arriving, I was so disappointed and felt an unspeakable sorrow when I discovered that the piece of land I had chosen so carefully turned out to be an area of ponds and lakes! I walked back and forth round the place, letting out sighs of utter despair. I was thinking of asking them to allow me to choose a different plot but I dared not because I remembered that the pilot had reported to the land grant committee and necessary documents had probably been prepared. Seeing the sorrow on my

face, the pilot came near me and said, "Sir, you have chosen a very good plot of land". "How do you know it was good?" I was surprised and wanted to know. "There is plenty of water here and this is a sign showing that the Vietnam pagoda to be built here will have very good chance for development."

Upon hearing these words I suddenly felt happy and decided to give up the idea of asking for a change, which, if I had pursued, would very likely have made things more complicated.

Once we obtained the land, we had to think about building the pagoda as soon as possible as my friends suggested:

"We have to start building the pagoda the sooner the better. Because if we left the land unoccupied for a certain period of time the Nepalese government would take it back." But the biggest problem was where the finance would come from. My friends reassured me, "Don't worry, Master. We promise you we will try to find the way out when we return to our countries. We will send you the money within two month's time". Knowing my hesitation, they went on advising me, "You should organize the ground-breaking ceremony for the construction of the pagoda by all means. You had better invite representatives of different embassies and of the central government to attend the ceremony. This way they would know that the construction of the pagoda had already been officially started".

I agreed to their ideas and asked them to share the work with me.

"All right. I'll be the chief celebrant of the ceremony. Would you please send invitations to embassies, representatives of the Nepalese central and local governments as well as representatives of religious organizations?"

At that time this area was covered with trees and thick bushes. There were many lakes and ponds and furthermore, there was no tarred road. What was even worse was the weather. It rained continually for several days when it was near the time of the ceremony. If it kept raining until that day, I was afraid, it would be impossible to have offerings made and rituals performed. I was so worried that I burnt three incense sticks and started praying: "We are all people with our heart and soul devoted to the construction of a pagoda on this sacred site. May the Buddhas, the Boddhisatvas, the Dragon Deities, the Dhamma Protectors, please give us the blessings so that we can have fine weather for the ground-breaking ceremony?"

Amazingly my prayers brought about miraculous results and we had a few days of sunshine just before the ceremony. And the ceremony day was also a fine day with the ground all dry.

